សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច
UNIVERSITE ROYALE DE DROIT ET DES SCIENCES ECONOMIQUES
ROYAL UNIVERSITY OF LAW AND ECONOMICS

# សារណាបញ្ចប់ការសិក្សា

# ញាតិ

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **អ៊ុន ឈុនលី**
លោក **អ៊ុច ពេជ្រ**

សាស្រ្តាចារ្យណែនាំ
លោកជំទាវ **ប៊ួយ ធីតា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្រ្ត**
ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩
ឆ្នាំសរសេរសារណា ២០២៣

## **សេចក្ដីថ្លែងអំណរគុណ**

ខ្ញុំបាទឈ្មោះ **អ៊ុន ឈុនលី** ក្រុមL4C3 និង **អ៊ុច ពេជ្រ** ក្រុមL4A5 ជានិស្សិតឆ្នាំទី៤ ថ្នាក់នីតិសាស្ត្រ ជំនាន់ទី២៣ ឆ្នាំសិក្សា២០២២-២០២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

### **សូមធ្វើគារវកិច្ច និងកតញ្ញូតាធម៌យ៉ាងជ្រាវជ្រៅជាទីបំផុតជូន**

លោកអ្នកមានគុណទាំងពីរ ដែលលោកបានផ្ដល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សារូបកូនចាប់ពីបាតជើងក្រហមរហូតដល់កូនធំដឹងក្ដី និងប្រឹងប្រែងទាំងកម្លាំងកាយចិត្ត ធ្វើអ្វីៗសព្វបែបយ៉ាង ដើម្បីកូនចិញ្ចឹមរូបកូនដោយមិនគិតពីការនឿយហត់ ទោះបីមានឧបសគ្គយ៉ាងណាក៏ដោយ ក៏នៅតែខិតខំពុះពារដោយមិនរារែកឲ្យតែកូនបានសិក្សារៀនសូត្របានខ្ពង់ខ្ពស់នឹងគេ ជាពិសេសថែមទាំងចំណាយពេលវេលាផ្ដល់ដំបូន្មានប្រៀនប្រដៅប្រកបដោយព្រហ្មវិហារធម៌ និងពន្យល់ណែនាំរូបកូនឲ្យធ្វើអំពើល្អ ចេះគោរពចាស់ទុំ ខិតខំសិក្សារៀនសូត្ររហូតដល់កូនទទួលបានចំណេះដឹងយ៉ាងប្រពៃដូចពេលនេះ។

ឯកឧត្តម **បណ្ឌិត លុយ ចន្ណា** សាកលវិទ្យាធិការ លោក/លោកស្រី សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំងសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានខិតខំប្រឹងប្រែងទាំងកម្លាំងកាយចិត្ត កម្លាំងបញ្ញា ពន្យល់អប់រំណែនាំដល់ខ្ញុំទាំងពីរនាក់ តាំងពីថ្នាក់មូលដ្ឋានរហូតដល់ពេលបច្ចុប្បន្ន ហើយអាចយកចំណេះដឹងដែលទទួលបាន ទាំងនេះទៅចូលរួមចំណែក ក្នុងការអភិវឌ្ឍប្រទេសជាតិឲ្យមានការរីកចម្រើន។

ជាពិសេសលោកជំទាវ **ម៉ូយ ធីតា** ដែលជាសាស្ត្រាចារ្យណែនាំរបស់យើងខ្ញុំទាំងពីរ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ព្រមទាំងបានផ្ដល់នូវឯកសារ ផ្ដល់ដំបូន្មានល្អៗ ក្នុងការធ្វើសារណាបញ្ចប់ការសិក្សានេះទទួលបានជោគជ័យ។ ប្រសិនគ្មានវត្តមានលោកជំទាវ **ម៉ូយ ធីតា** រូបខ្ញុំទាំងពីរនាក់ក៏មិនអាចសម្រេចបាននូវស្នាដៃមួយនេះដែរ។

យើងខ្ញុំទាំងពីរនាក់សូមគោរពជូនពរ សូមលើកហត្ថាទាំងទ្វេបួងសួងដល់ទេវតា ដែលតាមថែរក្សាព្រះរាជាណាចក្រកម្ពុជាទាំងឡាយ សូមជួយថែរក្សាលោកអ្នកមានគុណទាំងទ្វេ ឯកឧត្តមសាកលវិទ្យាធិការ ឯកឧត្តម លោកជំទាវសាស្ត្រាចារ្យ លោក លោកស្រីសាស្ត្រាចារ្យ និងអ្នកដែលបានជួយទំនុកបំរុងក្នុងកិច្ចការស្រាវជ្រាវនេះឲ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ និងសូមទទួលជោគជ័យគ្រប់ភារកិច្ច។

# អារម្ភកថា

បន្ទាប់ពីបានសិក្សាយ៉ាងលំអិតអស់រយៈពេលបួនឆ្នាំលើផ្នែកនីតិសាស្ត្រ ក្រោមការបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ពីសំណាក់ លោក លោកស្រីសាស្ត្រាចារ្យ បណ្ឌិត ទាំងអស់ដែលមានវត្តមាននៅក្នុងក្រុមរបស់យើងខ្ញុំនាពេលកន្លងមក ឆ្នាំនេះជាឆ្នាំចុងក្រោយ ហើយជាឆ្នាំដែលរូបខ្ញុំទាំងពីរនាក់ត្រូវបានបញ្ចប់បរិញ្ញាបត្រនីតិសាស្ត្រ ពីសាកលវិទ្យាល័យនាពេលដ៏ខ្លីខាងមុខនេះ។ ដើម្បីឆ្លើយតបទៅនិងតម្រូវការរបស់សាកលវិទ្យាល័យ និងដើម្បីទុកស្នាដៃសម្រាប់ជំនួយដល់ការសិក្សារបស់និស្សិតជំនាន់ក្រោយ រូបខ្ញុំទាំងពីរនាក់បានសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយដែលនិយាយអំពី "**ញាតិ**" យកមកធ្វើការសិក្សាស្រាវជ្រាវដើម្បីចងក្រងជាសារណាបញ្ចប់ការសិក្សា ដែលទាក់ទងនិងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។

យើងខ្ញុំបានធ្វើបានបែងចែកមាតិកា ជាផ្នែកតូចៗ ដើម្បីមានភាពងាយស្រួល ក្នុងការស្រាវជ្រាវ និងស្វែងរកឯកសារបន្ថែម ក៏ដូចជាភាពងាយស្រួល ក្នុងការពន្យល់ និងលើកមកពិភាក្សាក្នុងគោលបំណងចងក្រងឲ្យបាននូវស្នាដៃមួយដ៏ល្អ។ លើសពីនេះទៀតយើងខ្ញុំបានប្រមូលផ្តុំនូវឯកសារមួយចំនួន និងបានសុំគំនិតយោលបល់ពីសាស្ត្រាចារ្យនានា ដើម្បីលើកមកធ្វើការពិភាក្សានៅក្នុងសៀវភៅមួយក្បាលនេះ។ ជាលទ្ធផលយើងខ្ញុំទទួលបាននូវស្នាដៃមួយនេះ ដើម្បីប្រគល់ជូនការិយាល័យស្រាវជ្រាវបានទាន់ពេលវេលាដែលកំណត់ក្នុងការត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងដាក់ពិន្ទុពីសំណាក់ លោក លោកស្រីសាស្ត្រាចារ្យដែលជាគណៈកម្មការ។

ទោះបីយើងខ្ញុំបានខិតខំប្រឹងប្រែង និងព្យាយាមយ៉ាងណាក៏ដោយ ក៏កិច្ចការនេះ ពិតជាអាចមាននូវកំហុសខុសឆ្គងខ្លះៗ ទាំងអចេតនា ឬ ចេតនាក្តី នៅត្រង់ចំណុចណាមួយជាមិនខាន។ អាស្រ័យហេតុនេះហើយ ក្នុងនាមយើងខ្ញុំជាអ្នកតាក់តែង សូមធ្វើការសូមអភ័យទោសជាមុននូវរាល់កំហុសឆ្គង និងការខ្វះខាតក៏ដូចជាទទួលនូវការរិះគន់ផ្សេងៗ ក្នុងគោលបំណងស្ថាបនាស្នាដៃមួយនេះ ឲ្យមានលក្ខណៈកាន់តែប្រសើរឡើយបន្ថែមទៀត។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ **១**

**ជំពូកទី១ សញ្ញាណទូទៅនៃ ញាតិ**

**១.១. ញាតិក្នុងន័យអក្សរសាស្ត្រ** ........ **៣**

១.១.១. និយមន័យ ........ ៣

១.១.២. ប្រភេទនៃញាតិ ........ ៥

ក. ញាតិខ្សែលោហិតផ្ទាល់ ........ ៥

ខ. សាខាញាតិ ........ ៥

គ. ញាតិពន្ធ ........ ៥

ឃ. ញាតិធម៌ ........ ៥

**១.២. របបគតិយុត្តនៃញាតិ** ........ **៥**

១.២.១. បទដ្ឋានគតិយុត្ត ........ ៥

ក. រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ........ ៦

ខ. ក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ ........ ៦

គ. ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ ........ ៨

ឃ. ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ........ ១០

ង. ច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ២០១៨ ........ ១០

**ជំពូកទី២ របបគតិយុត្តនៃការបង្កើតញាតិភាព**

**២.១. ខ្សែលោហិត** ........ **១៤**

ក. បុព្វញាតិ ........ ១៤

ខ. បច្ឆាញាតិ ........ ១៤

គ. សាខាញាតិ ........ ១៥

២.១.១. តំណពូជពីធម្មជាតិ ........ ១៥

ក. ទំនងទំនងរវាងម្តាយ និងកូន ........ ១៦

ខ. ទំនងទំនងរវាងកូន និង ម្តាយ ........ ១៦

គ. ទំនងទំនងរវាងឪពុក និង កូន ........ ១៧

ឃ. ទំនងទំនងរវាងកូន និង ឪពុក ......................................................................................... ១៧
**២.២. សហព័ទ្ធ......................................................................................................... ១៨**
២.២.១. កំជាប់ពាក្យ ........................................................................................................ ១៨
២.២.១.១. ការបង្កើតកំជាប់ពាក្យ ............................................................................................ ១៨
២.២.១.២. ការចែចូវ ......................................................................................................... ១៩
២.២.១.៣. ការស្ដីដណ្ដឹង ...................................................................................................... ១៩
២.២.១.៤. សេចក្ដីសន្យា ....................................................................................................... ២០
២.២.១.៥. ពិធីកំជាប់ពាក្យ ..................................................................................................... ២០
២.២.២. ល័ក្ខខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ ........................................................................... ២១
២.២.២.១. គោលការណ៍ស្ម័គ្រចិត្ត ............................................................................................. ២១
២.២.២.២. ភេទរបស់គូភាគី ...................................................................................................... ២២
២.២.២.៣. ល័ក្ខខ័ណ្ឌអាយុសម្រាប់រៀបអាពាហ៍ពិពាហ៍ ....................................................................... ២២
២.២.២.៤. ការហាមឃាត់មិនឲ្យមានទ្វេពន្ធភាព ............................................................................... ២៣
២.២.២.៥. អំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ......................................................... ២៣
២.២.២.៦. ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិ ................................................................ ២៤
ក. ការហាមឃាត់រៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិត..................................................................... ២៤
ខ. ការហាមឃាត់រៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ.......................................................................... ២៤
គ. ការហាមឃាត់រៀបអាពាហ៍ពិពាហ៍រវាងញាតិភាពតាមរយៈសុំកូន ....................................................... ២៥
២.២.២.៧. ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន ............................................................................. ២៥
ក. អនីតិជន និងនីតិជន......................................................................................................... ២៥
ខ. ជនដែលទទួលបានអត្តាធីនភាព .......................................................................................... ២៥
គ.ជននៅក្រោមអាណាព្យាបាលទូទៅ ....................................................................................... ២៦
២.២.២.៨. ឧបសគ្គក្នុងការរៀបអាពាហ៍ពិពាហ៍ ............................................................................... ២៧
ក. ការបាត់ខ្លួនលើសពី៥ឆ្នាំ ..................................................................................................... ២៧
ខ. ការបាត់ខ្លួនលើសពី១ឆ្នាំ ដោយឧបទ្វវហេតុ............................................................................... ២៨
២.២.៣. នីតិវិធីនៃការបង្កើតចំណងអាពាហ៍ពិពាហ៍............................................................................ ២៨
២.២.៣.១. នីតិវិធីមុនរៀបអាពាហ៍ពិពាហ៍រវាងជនជាតិខ្មែរ និង ជនជាតិខ្មែរ ............................................... ២៨

ក. ការដាក់ពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍ ..... ២៨
ខ. ការបិទប្រកាសលិខិតស្នើសុំរៀបអាពាហ៍ពិពាហ៍..... ២៩
គ. ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ..... ២៩
ឃ. ការចុះសំបុត្រអាពាហ៍ពិពាហ៍..... ៣០
ង. ការចេញសំបុត្រអាពាហ៍ពិពាហ៍..... ៣០
២.២.៣.២. នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងជនជាតិខ្មែរ និង ជនបរទេស ..... ៣១
ក. ការដាក់ពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍ ..... ៣២
ខ. ការបិទប្រកាសលិខិតស្នើសុំរៀបអាពាហ៍ពិពាហ៍..... ៣២
គ. ការចុះសំបុត្រអាពាហ៍ពិពាហ៍រវាង ជនជាតិខ្មែរ និង ជនជាតិបរទេស..... ៣៣
២.២.៤. អានុភាពនៃអាពាហ៍ពិពាហ៍..... ៣៣
២.២.៤.១. ការប្រើប្រាស់នាមត្រកូលរបស់ប្តីប្រពន្ធ ..... ៣៣
២.២.៤.២. ករណីយកិច្ចរបស់សហព័ទ្ធ..... ៣៣
២.២.៤.៣. សេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ និងសិទ្ធិចូលរួមសកម្មភាពសង្គម ..... ៣៤
២.២.៤.៤. សិទ្ធិ និងករណីយកិច្ចរបស់អ្នកមានអំណាចមេបា ..... ៣៤
២.២.៤.៥. ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ..... ៣៤
ក. ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា ..... ៣៤
ខ. ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់..... ៣៥
២.២.៤.៦. ទំនាក់ទំនងសហព័ទ្ធ និងញាតិ..... ៣៦
**២.៣. ញាតិពន្ធ ..... ៣៦**
**២.៤. ញាតិតាមរយៈការបង្កើតស្មុំកូន..... ៣៧**
២.៤.១. ស្មុំកូនធម្មតា ..... ៣៧
២.៤.១.១. សញ្ញាណទូទៅនៃស្មុំកូនធម្មតា ..... ៣៧
២.៤.១.២. លក្ខណៈពិសេសនៃស្មុំកូនធម្មតា..... ៣៨
២.៤.១.៣. ល័ក្ខខ័ណ្ឌនៃការបង្កើតស្មុំកូនធម្មតា ..... ៣៨
ក. អាយុរបស់ឪពុកម្តាយចិញ្ចឹម ..... ៣៨
ខ. អាយុរបស់កូនសុំ..... ៣៩
គ. ការចូលរួមរបស់សហព័ទ្ធ ..... ៣៩

ឃ. ការចូលរួមរបស់ឪពុកម្តាយបង្កើតរបស់កូនសុំ ........ ៤០
ង. មូលដ្ឋានវិនិច្ឆ័យដែលតុលាការ និង ពិចារណា ........ ៤១
២.៤.១.៤. អានុភាពនៃស្មុំកូនធម្មតា ........ ៤១
ក.បង្កើតញាតិភាពជាមួយឪពុកម្តាយចិញ្ចឹម ក្រោយបង្កើតស្មុំកូន ........ ៤១
ខ.ការបន្តញាតិភាពជាមួយឪពុកម្តាយបង្កើត ........ ៤២
២.៤.២. ស្មុំកូនពេញលេញ ........ ៤២
២.៤.២.១. និយមន័យ ........ ៤២
២.៤.២.២. ល័ក្ខខ័ណ្ឌនៃការបង្កើតស្មុំកូនពេញលេញ ........ ៤២
ក. លក្ខខណ្ឌចំពោះឪពុកម្តាយចិញ្ចឹម ........ ៤៣
ខ. លក្ខខណ្ឌចំពោះកូនស្មុំពេញលេញ ........ ៤៤
គ. លក្ខខណ្ឌផ្សេងៗ ........ ៤៤
២.៤.២.៣. អានុភាពនៃស្មុំកូនពេញលេញ ........ ៤៥
ក. ការកាត់ផ្តាច់ទំនាក់ទំនងញាតិ ........ ៤៥
ខ. ការបង្កើតទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹម ........ ៤៥
**ជំពូកទី៣ របបគតិយុត្តនៃការផ្តាច់ទំនាក់ទំនងញាតិ**
**៣.១.ចំពោះញាតិលោហិត ........ ៤៧**
**៣.២. ការកាត់កាល់ស្មុំកូនធម្មតា ........ ៤៨**
៣.២.១. មូលហេតុ និង ការវិនិច្ឆ័យនៃការកាត់កាល់កូនធម្មតា ........ ៤៨
៣.២.២. ពាក្យសុំឲ្យកាត់កាល់ស្មុំកូនធម្មតា ........ ៤៩
៣.២.៣. លក្ខខណ្ឌនៃការកាត់កាល់ស្មុំកូនធម្មតា ........ ៤៩
៣.២.៤.  អានុភាពនៃការកាត់កាល់ស្មុំកូនធម្មតា ........ ៤៩
**៣.៣. ការកាត់កាល់ស្មុំកូនពេញលេញ ........ ៤៩**
៣.៣.១. មូលហេតុនៃការកាត់កាល់ ........ ៥០
៣.៣.២. អ្នកដែលមានសិទ្ធិកាត់កាល់ ........ ៥០
ក. តំណាងអយ្យការ ........ ៥០
ខ. ឪពុកម្តាយបង្កើត ........ ៥១
គ. ភាគីកូនសុំ ........ ៥១

៣.៣.៣. អានុភាពនៃការកាត់កាល់ស្មុំកូនពេញលេញ ........ ៥១
**៣.៤. ការផ្តាច់ទំនាក់ទំនងញាតិតាមរយៈការលែងលះ ........ ៥១**
ក. ទំនាក់ទំនងប្តីប្រពន្ធ ........ ៥២
ខ. ការកាត់ផ្តាច់ទំនាក់ទំនងគតិយុត្តនៃញាតិពន្ធ ........ ៥២
**សេចក្តីសន្និដ្ឋាន ........ ៥៣**
**អនុសាសន៍ ........ ៥៥**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ប្រទេសកម្ពុជាយើង គឺជាប្រទេសមួយដ៏ចំណាស់ស្ថិតនៅក្នុងទ្វីបអាស៊ី ហើយជាប្រទេសមួយដែលសំបូរទៅដោយវប្បធម៌អរិយធម៌ដល់ល្អឆើតឆាយ និងសំបូរបែបដែលមានអាយុកាលយូរលង់ណាស់មកហើយ។ ប្រទេសយើង មានទំនៀមទម្លាប់ដ៏ល្អប្រពៃសម្រាប់អនុវត្ត ពីមួយជំនាន់ទៅមួយជំនាន់នៅក្នុងសង្គមខ្មែរយើង គឺការរាប់អានសាច់សាលោហិតព្រៀនលាន គឺជារឿងដ៏សំខាន់មួយសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ មិនថានៅសម័យមុន ឬ នៅពេលបច្ចុប្បន្ននេះ ប្រជាជនខ្មែរតែងតែប្រកាន់ភ្ជាប់និងរាប់អាន ព្រមទាំងរក្សាសាច់សាលោហិតព្រៀនលានទាំងឡាយដែលជាប់ខ្សែ ឬ ជាប់ស្រឡាយជាមួយគ្នា។ ហើយមួយវិញទៀតការដឹងពីប្រភពនៃញាតិនេះ ក៏អាចកំណត់អត្តសញ្ញាណនៃគ្រួសារនីមួយៗបានផងដែរ ថាមានប្រភព និងប្រវត្តិបែបណាដែរ។ នៅតាមតំបន់ខ្លះបងប្អូនប្រជាជនខ្មែរយើងបានរាប់អានខ្សែស្រឡាយវែងណាស់ ចាប់តាំងពីបងប្អូនជាទួតមួយ បងប្អូនជីលួតមួយ បងប្អូនជីលាមួយផងដែរ ដែលជាហេតុធ្វើឲ្យការរាប់អាន និងការគណនាខ្សែញាតិ មានលក្ខណៈពិបាកហើយស្មុគស្មាញផងដែរ។ ចាប់តាំងពីសម័យអាណានិគមនិយមបារាំង ប្រទេសកម្ពុជាយើងបានបង្កើតនូវក្រមរដ្ឋប្បវេណីជាលើកដំបូង ជាហេតុធ្វើឲ្យមានការកំណត់នៅនូវទំនាក់ទំនងញាតិបានបែងចែកយ៉ាងច្បាស់អំពីទំនាក់ទំនងញាតិ ដែលជាទំនាក់ទំនងគតិយុត្តមួយនេះមានលក្ខណៈស្មុគស្មាញ ហើយមានអានុភាពគតិយុត្តជាច្រើនដែលកើតចេញពីភាពជាញាតិនេះ។ ដោយក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់អត្ថន័យគតិយុត្តនៃញាតិនេះតាមល័ក្ខខ័ណ្ឌនៃទំហំ គឺញាតិសំដៅដល់បុគ្គលដែលជាញាតិលោហិតក្នុង៦ (ប្រាំមួយ) ថ្នាក់ សហព័ទ្ធ និងញាតិពន្ធក្នុង ០៣ (បី) ថ្នាក់ ហើយបុគ្គលក្រៅពីនេះមិនមែនជាញាតិតាមផ្លូវច្បាប់ឡើយ។ ញាតិលោហិតសំដៅដល់បុគ្គលដែលកើត ចេញពីតំណពូជតាមលក្ខណៈធម្មជាតិពីបុគ្គលម្នាក់ទៀត ដូចកូនដែលបានកើតចេញពីឪពុកម្តាយជាអាទិ៍ ហេតុនេះកូនគឺជាញាតិលោហិតរបស់ឪពុកម្តាយ រីឯសហព័ទ្ធ គឺជាប្តី ឬ ប្រពន្ធ ហើយចំណែកឯញាតិពន្ធគឺ សំដៅដល់ញាតិលោហិតរបស់សហព័ទ្ធខ្លួនដែលជាសាច់ថ្លៃជាដើម។ ហើយញាតិខ្សែផ្ទាល់ គឺជាទំនាក់ទំនងញាតិខ្សែលោហិតដោយផ្ទាល់ រីឯសាខាញាតិវិញ គឺជាទំនាក់ទំនងញាតិដែលបែកចេញពីបុព្វញាតិតែមួយដោយបុព្វញាតិ គឺជាញាតិជំនាន់មុន និងបុគ្គលជំនាន់ក្រោយហៅថា បច្ឆាញាតិ។ មួយវិញទៀត ថ្នាក់ញាតិ គឺជាឯកតាដែលបង្ហាញពីរូបភាពនៃទំនាក់ទំនងញាតិ និងលេខលំដាប់ថ្នាក់ញាតិកាន់តែតូច ទំនាក់ទំនងញាតិក៏កាន់តែជិតដែរ ដោយទំនាក់ទំនងញាតិ ត្រូវបានគណនាគិតចាប់ពីជននោះ ទៅកាន់បុព្វញាតិរបស់ខ្លួន។ លើសពីនេះទៅទៀត ទំនាក់ទំនងញាតិក៏អាចកើតឡើង តាមរយៈសុំកូនផងដែរ ដោយទំនាក់ទំនងនៃឪពុកម្តាយ និងកូនតាមច្បាប់ ត្រូវកើតឡើងរវាងឪពុកម្តាយ និងកូនសុំ ចាប់ពីថ្ងៃបង្កើតសុំកូន ហើយទំនាក់ទំនងញាតិលោហិតពីកំណើតក៏នៅបន្តដដែល លើកលែងតែករណីសុំកូនពេញលេញ ដែលទំនាក់ទំនងញាតិលោហិតរបស់កូនសុំពេញលេញ និងឪពុកម្តាយបង្កើតត្រូវរលត់។ ដោយឡែក ទំនាក់ទំនងញាតិលោហិត

ដែលកំណត់ដោយច្បាប់ តាមរយៈសុំ នឹងត្រូវចាត់ទុកដូចគ្នាញាតិលោហិតពីកំណើតផងដែរ ប៉ុន្តែដោយសារ របបសុំកូននេះ គឺជាប្រព័ន្ធញាតិដែលកំណត់ដោយច្បាប់ ដែលនាំឲ្យញាតិលោហិតប្រភេទនេះ នឹងត្រូវរលត់ទៅវិញ ដោយការកាត់កាល់។ ហើយការកាត់កាល់នេះ មិនត្រឹមតែរលត់ញាតិលោហិតរវាងឪពុកម្ដាយ ចិញ្ចឹម និងកូនចិញ្ចឹមតែប៉ុណ្ណោះនោះទេ ប៉ុន្តែវាក៏រលត់រវាងកូនចិញ្ចឹមនិងញាតិលោហិតខ្សែផ្ទាល់របស់ឪពុកម្ដាយចិញ្ចឹមនោះផងដែរ ដោយរាប់បញ្ចូលទាំងសហព័ទ្ធរបស់កូនចិញ្ចឹម បច្ចាញាតិផ្ទាល់របស់កូនចិញ្ចឹម ជាអាទិ៍។ ផ្ទុយទៅវិញ ចំពោះសុំកូនពេញលេញដែលត្រូវបង្កើតឡើង ដើម្បីសុខមាលភាពរបស់កូនចិញ្ចឹមដែលជាអនីតិជន ហេតុនេះ ការកាត់កាល់នឹងអាចអនុញ្ញាតឲ្យធ្វើទៅបាន ក្នុងតែករណីសកម្មភាពណាមួយដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់កូនចិញ្ចឹមពីសំណាក់ឪពុកម្ដាយចិញ្ចឹម ឬ ឪពុកម្ដាយបង្កើតមានលទ្ធភាពមើលថែរក្សាកូននោះវិញបានតែប៉ុណ្ណោះ។ ចំណែកឯទំនាក់ទំនងញាតិពន្ធ អាចនឹងរលត់នៅពេលមានការរំលាយនូវទំនាក់ទំនងអាពាហ៍ពិពាហ៍ដោយសារការលែងលះ ឬ សហព័ទ្ធណាម្ខាងទៀតទទួលមរណភាពតែប៉ុណ្ណោះ។ ប៉ុន្តែការរលត់ទំនាក់ទំនងញាតិពន្ធដោយសារការទទួលមរណភាពរបស់សហព័ទ្ធណាម្ខាង គឺមានលក្ខណៈខុសគ្នាពីការរលត់ដោយសារការលែងលះ ព្រោះក្នុងករណីដែលសហព័ទ្ធណាម្ខាងបានទទួលមរណភាព ដើម្បីបញ្ចប់ទំនាក់ទំនងញាតិពន្ធ សហព័ទ្ធដែលនៅរស់ត្រូវធ្វើការបង្ហាញឆន្ទៈ ក្នុងការបញ្ចប់ទំនាក់ទំនងញាតិពន្ធនេះទៅតុលាការតាមរយៈពាក្យសុំរបស់សាមីខ្លួន លើកលែងតែសហព័ទ្ធដែលនៅរស់បាន រៀបអាពាហ៍ពិពាហ៍ជាថ្មីម្ដងទៀតដែលនាំឲ្យទំនាក់ទំនងញាតិជាមួយនឹងសហព័ទ្ធថ្មីនិងកើតឡើងជាដើម។

ដើម្បីឆ្លើយតបជាមួយសារៈសំខាន់នៃប្រធានបទនេះ នឹងសង្ឃឹមថាអាចគ្រប់គ្រងខ្លឹមសារជាសារវ័ន្តដែលមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីនៃគន្ថីទី ៧ ស្ដីពីញាតិ ខ្ញុំនឹងធ្វើការបែងចែកប្រធានបទនេះ ជាបីជំពូក :

ជំពូកទី ១ : សញ្ញាណទូទៅនៃ ញាតិ

ជំពូកទី ២ : របបគតិយុត្តនៃការបង្កើតញាតិភាព

ជំពូកទី ៣ : របបគតិយុត្តនៃការផ្ដាច់ទំនាក់ទំនងញាតិ

# ជំពូកទី១

# សញ្ញាណទូទៅនៃ ញាតិ

# ជំពូកទី១

# សញ្ញាណទូទៅនៃ ញាតិ

ពាក្យថាញាតិមានអត្ថន័យពីរយ៉ាង គឺញាតិក្នុងអត្ថន័យអក្សរសាស្ត្រ និងញាតិតាមការកំណត់នៃច្បាប់។

## ១.១. ញាតិក្នុងន័យអក្សរសាស្ត្រ

### ១.១.១. និយមន័យ

ដោយយោងតាមវចនានុក្រមខ្មែរ ដែលជាស្នាព្រះហស្តរបស់សម្តេចព្រះសង្ឃរាជជួន ណាត បានពន្យល់និងឲ្យនិយមន័យទៅលើញាតិថា៖

ញាតិ គឺអ្នកដែលរួមខ្សែលោហិតនឹងគ្នាខាងមាតា ឬ ខាងបិតា ដែលហៅថា ញាតិ ៧ សន្តាន ឬ ញាតិ៧ជួរនោះ តាមន័យក្នុងគម្ពីរពុទ្ធសាសនាលោកឲ្យរាប់ថ្នាក់ខាងលើ ៣ ជាន់ គឺថ្នាក់មាតាបិតា១ ថ្នាក់ជីដូនជីតា១ ថ្នាក់យាយទួតតាទួត១ ថ្នាក់ខាងក្រោមខ្លួន ៣ជាន់ទៀត គឺថ្នាក់កូន១ ថ្នាក់ចៅ១ ថ្នាក់ចៅទួត១ រួមជា ៦ថ្នាក់ ជា ៧ ថ្នាក់នឹងខ្លួនយើងមនុស្សទាំងប៉ុណ្ណេះហៅថា ញាតិ ៧ សន្តាន។[1]

តាមន័យក្នុងច្បាប់ក្រមរដ្ឋប្បវេណីខ្មែរឲ្យរាប់ដូច្នេះថា អ្នកដែលកើតចេញមកពីគោត្រតែមួយ ហៅថា ញាតិ មាន ២ ពួក គឺ ញាតិជួរខ្សែផ្ទាល់ មួយពួក, សាខាញាតិ មួយពួក ញាតិជួរខ្សែផ្ទាល់នោះ គឺអ្នកដែលកើតតគ្នាពី ១ ទៅ ១ តាមលំដាប់គឺឪពុក, កូន, ចៅ, ចៅទួត ។ ល ។

រហូតដល់ជាន់ទី៧, ញាតិជួរនេះតាមតែថ្នាក់ណា ឬ ក្នុងថ្នាក់ណាក៏ដោយ ច្បាប់ហាមមិនឲ្យយកគ្នាជាប្តីប្រពន្ធឡើយ។ ឯសាខាញាតិនោះ គឺអ្នកដែលកើតចេញពីគោត្រជាមួយគ្នាដែរ តែបែកទៅជាមែកដទៃ ដូចយ៉ាងបងប្អូនបង្កើត មាមីងនិងក្មួយ បងប្អូនជីដូនមួយ ជីទួតមួយចុះរៀងទៅ ញាតិទាំងពីរខាងនេះ ច្បាប់អនុញ្ញាតឲ្យយកគ្នាជាប្តីប្រពន្ធបាន ពីត្រឹមថ្នាក់ទី ៤ គឺពីត្រឹមបងប្អូនជីដូនមួយចុះរៀងទៅ ។

សព្ទនេះ បើរៀងភ្ជាប់ពីខាងដើមសព្ទដទៃទៀត អ.ថ. ញា-តិ ដូចជា៖

- ញាតិកម្ម( ក័ម; បា.; សំ. ជ្ញាតិកម៌ន៑ ) កិច្ចការ, មុខការរបស់ញាតិ។
- ញាតិកិច្ច ( កិច ; បា.; សំ. ជ្ញាតិក្ឫត្យ ) ការរវល់របស់ញាតិ។
- ញាតិគារវៈ ( គារៈវៈ; បា. ញាតិគារវ; សំ. ជ្ញាតិគៅរវ ) សេចក្តីគោរពចំពោះញាតិ គឺសេចក្តីយកចិត្តទុកដាក់គួរសម, ឱនលំទោន, កោតខ្លាចញាតិតាមជាន់ តាមថ្នាក់។
- ញាតិដោយសារ (ញាតដោយសា) ម. ព. ញាតិពន្ធ ឬ ញាតិដោយពន្ធ។

---

[1] វចនានុក្រមខ្មែរ ទំព័រ២៩៣ ព.ស ២៥១១ គ.ស ១៩៦៧។

- ញាតិទាយាទ ( ញា-តិ-ទាយាត ) ទ្រព្យសម្បាច់របស់ញាតិ; អ្នកដែលត្រូវទទួលទ្រព្យសម្បាច់របស់ញាតិ កូនប្រុសស្រីរបស់ញាតិ។
- ញាតិធម៌ ( ញា-តិ ) ធម៌របស់ញាតិ; សេចក្ដីសង្គ្រោះដល់ញាតិ(អ្នកដែលបានធ្វើបុណ្យឧទ្ទិសផល ជូនដល់បុព្វបុរសទាំងឡាយឈ្មោះថាបានបំពេញញាតិធម៌ដ៏សមគួរហើយ)។
- ញាតិធីតា ( ធីដា; បា. ញាតិធីតុ > ញាតិធីតា; សំ. ជ្ញាតិទុហិត្ឫ ) កូនស្រីរបស់ញាតិ។
- ញាតិបុត្ត ឬ ញាតិបុត្រ ( បុត; បា. ញាតិបុត្ត; សំ ជ្ញាតិបុត្រ ) កូនប្រុសរបស់ញាតិ។
- ញាតិប្រេត ( ប្រែត; បា. ញាតិបេត, ញាតិប្បេត; សំ. ជ្ញាតិប្រេត ) ប្រេតដែលជាញាតិ; ញាតិដែលចែកឋានទៅកាន់បរលោកហើយ(ឧទ្ទិសចំណែកបុណ្យជូនទៅញាតិប្រេត)។
- ញាតិពន្ធ ឬ ញាតិដោយពន្ធ (ញាត-ពន់; បា. ញាតិ+ពន្ធ ) ជនដែលគេរាប់ថាជាញាតិ ដោយជាប់ទាក់ទងគន្លងគ្នា គឺញាតិដោយសារ ដូចយ៉ាង ម្ដាយក្មេក, ឪពុកក្មេក, កូនប្រសា, មាមីងក្មេក, បងថ្លៃ, ប្អូនថ្លៃ ( ខាងប្ដី ឬខាងប្រពន្ធ )។ល។
- ញាតិពលី ( ពៈលី; បា. ពលី; សំ. ជ្ញាតិ ) ពលីការដែលគេធ្វើដល់ញាតិ, ការសង្គ្រោះញាតិ ( ម. ព. ពលី, ពលីការ ផង )។
- ញាតិភេទ ឬ ញាតិសម្ភេទ ( ភេត ឬ សំភេត ) ការបែកបាក់នៃញាតិ, ដំណើរបែកខ្ញែកចាកញាតិ។
- ញាតិវង្ស ( វង់ ) តំណនៃញាតិ, ពួកញាតិ ( ប្រើជា ញាតិវង្សា, ញាតិពង្ស, ញាតិពង្សា ក៏មាន )។
- ញាតិវង្សានុវង្ស ( វង់-សា-នុ-វង់ ) តំណនៃញាតិដែលជាប់តវង្សត្រកូលគ្នាជាលំដាប់លំដោយមក។
- ញាតិវិវាទ ( វិវាត ) សេចក្ដីទាស់ទែងនៃញាតិ, ជម្លោះនៃពួកញាតិ ។ពាក្យផ្ទុយ ញាតិសាមគ្គី។
- ញាតិសង្គហៈ ឬ ញាតិសង្គ្រោះ ( សង់គៈហៈ ឬ សង់គ្រោះ ) ការទំនុកបម្រុងដល់ញាតិ, ការជួយដោះទុក្ខធុរៈញាតិ។
- ញាតិសន្តាន (ញាត-សណ្ដាន; បា. ញាតិ+សន្តាន; សំ. ជ្ញាតិ+ សន្តាន ) តំណ ឬ វង្សនៃញាតិ, ត្រកូលដែលជាប់ជាញាតិ ( ម. ព. ញាតិ និង សន្តាន ផង )។
- ញាតិសាមគ្គី (ញា-តិសាម៉ុក-គី ) សេចក្ដីព្រមព្រៀងរបស់ញាតិ ។ ពាក្យផ្ទុយ ញាតិវិវាទ។
- ញាតិសាលោហិត (ញា-តិ ឬ ញាតសា-លោហិត; បា.; សំ. ជ្ញាតិ+ ស្វលោហិត ) ញាតិដែលជាប់ខ្សែលោហិតជាមួយគ្នា. . . ( ម. ព. សាលោហិត ផង )។

### ១.១.២. ប្រភេទនៃញាតិ

#### ក. ញាតិខ្សែលោហិតផ្ទាល់

ញាតិខ្សែលោហិតផ្ទាល់ គឺអ្នកដែលកើតតគ្នាពី ១ ទៅ ១ តាមលំដាប់គឺឪពុក, កូន, ចៅ, ចៅទួត ។[2]

#### ខ. សាខាញាតិ

សាខាញាតិ គឺអ្នកដែលកើតចេញពីគោត្រជាមួយគ្នាដែរ តែបែកទៅជាមែកដទៃ ដូចយ៉ាង បងប្អូនបង្កើត, មាមីងនិងក្មួយ, បងប្អូនជីដូនមួយ ជីទួតមួយចុះរៀងទៅ។[3]

#### គ. ញាតិពន្ធ

ញាតិពន្ធ ឬ ញាតិដោយពន្ធ គឺជាជនដែលគេរាប់ថាជាញាតិ ដោយជាប់ទាក់ទងគន្លងគ្នា គឺញាតិដោយសារដូចយ៉ាង ម្ដាយក្មេក, ឪពុកក្មេក, កូនប្រសា, មាមីងក្មេក, បងថ្លៃ, ប្អូនថ្លៃ ( ខាងប្ដី ឬ ខាងប្រពន្ធ )។ល។[4]

#### ឃ. ញាតិធម៌

ញាតិធម៌ គឺជាញាតិមួយបែបដែលបានកើតចេញពីទំនាក់ទំនងរវាងបុគ្គលម្នាក់និងបុគ្គលម្នាក់ទៀតដែលមិនជាប់សាច់សាលោហិតនិងគ្នាឡើយ។ ជាទូទៅញាតិធម៌នេះ នៅក្នុងសង្គមខ្មែរយើងភាគច្រើន គឺកើតឡើងដោយផ្ដើមចេញពីទំនាក់ទំនងរវាងបុគ្គលនិងបុគ្គលដែលរាប់អានគ្នាជិតដិត ពីមួយថ្ងៃទៅមួយថ្ងៃ ដែលធ្វើឲ្យបុគ្គលនោះមានអារម្មណ៍ថា លើសពីមិត្តភាពប្រៀបបីដូចជាញាតិរបស់ខ្លួន ហើយបានវិវត្តពីមិត្តភាពមករាប់អានគ្នាជាញាតិទៅវិញ ទោះបីមានទុក្ខធុរៈលំបាកយ៉ាងណាក៏ដោយ គឺត្រូវជួយស្រោចស្រង់គ្នាជានិច្ច ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយត្រូវស្រលាញ់ នឹងចាត់ទុកគ្នាដូចជាញាតិរបស់ខ្លួន។ ក៏ប៉ុន្តែនៅតំបន់ខ្លះការរាប់អានគ្នាជាញាតិធម៌នេះ ក៏មានការរៀបចំជាពិធីបែបជំនឿផ្សេងៗផងដែរ ទៅតាមតំបន់នីមួយៗ។ ក៏ប៉ុន្តែញាតិធម៌នេះត្រូវបានគោរពអានប្រៀបបីដូចជាញាតិសាច់សាលោហិតពិតមែនក្ដី តែញាតិប្រភេទនេះគឺច្បាប់មិនទទួលស្គាល់នោះឡើយ គឺគ្មានសិទ្ធិនិងកាតព្វកិច្ចដូចជាញាតិដែលច្បាប់បានកំណត់នោះឡើយ ប៉ុន្តែញាតិធម៌នេះ អាចផ្ទេរ និងទទួលនូវសិទ្ធិព្រមទាំងកាតព្វកិច្ចទៅឲ្យគ្នាទៅវិញទៅមកបាន តាមរយៈការធ្វើជាបណ្ដាំមរតកជាដើម។

## ១.២. របបគតិយុត្តនៃញាតិ

### ១.២.១. បទដ្ឋានគតិយុត្ត

[2] កថាខណ្ឌទី ១ នៃវចនានុក្រមខ្មែរ ទំព័រ២៩៣ ព.ស ២៥១១ គ.ស ១៩៦៧។

[3] កថាខណ្ឌទី ២ នៃវចនានុក្រមខ្មែរ ទំព័រ២៩៣ ព.ស ២៥១១ គ.ស ១៩៦៧។

[4] កថាខណ្ឌទី ១៣ នៃវចនានុក្រមខ្មែរ ទំព័រ២៩៣ ព.ស ២៥១១ គ.ស ១៩៦៧។

### ក. រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ គឺជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា។ ចំពោះរដ្ឋធម្មនុញ្ញបានបញ្ញត្តិផងដែរ ចំពោះញាតិរវាងកូនជាមួយឪពុកម្តាយ ដែលត្រូវបំពេញកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក។

មាត្រា ៤៧ នៃរដ្ឋធម្មនុញ្ញ បានបញ្ញត្តិថា មាតាបិតាមានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឲ្យទៅជាពលរដ្ឋល្អ។[5]

ចំពោះកូនត្រូវមានករណីកិច្ចចិញ្ចឹម និងបីបាច់ថែរក្សាមាតាបិតា ដែលចាស់ជរា តាមទំនៀមទម្លាប់ខ្មែរ។[6]

### ខ. ក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០

ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ គឺជាច្បាប់ដែលអនុវត្តន៍កាលពីសង្គមចាស់ឆ្នាំ១៩២០។ ក្រមរដ្ឋប្បវេណីសង្គមចាស់នេះ បានបែងចែកជា ៣គន្ថី (គន្ថីទី១ អំពីបុគ្គល, គន្ថីទី២ អំពីទ្រព្យ, និងគន្ថីទី៣ អំពីកាតព្វកិច្ច) ដែលមាន ១៣៦៥មាត្រា។ ក្នុងគន្ថីទាំង៣នោះផងដែរ មិនបានបញ្ញត្តិអំពីទំហំនៃញាតិទេ ប៉ុន្តែក្រមនេះគ្រាន់តែបានបញ្ញត្តិអំពីការហាមមិនអោយរៀបអាពាហ៍ពិពាហ៍ជាមួយញាតិលោហិត ឬ ញាតិពន្ធនិងគ្នាតែប៉ុណ្ណោះ។

ដោយយោងតាមក្រមរដ្ឋប្បវេណីសង្គមចាស់ឆ្នាំ១៩២០ បានបង្ហាញថា អាពាហ៍ពិពាហ៍អាចរៀបចំឡើងរវាងបុគ្គលដែលមានភេទផ្សេងគ្នាដោយខាងប្រុស គឺមានអាយុដល់ ១៧ឆ្នាំ និងខាងស្រីមានអាយុដល់ ១៤ឆ្នាំ គឺអាចរៀបអាពាហ៍ពិពាហ៍យកគ្នាជាស្វាមីភរិយាបាន។[7] ហើយច្បាប់មិនអនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍រវាងបុគ្គលដែលជាប់ចំណងញាតិលោហិត ឬ ញាតិពន្ធនិងគ្នា ក្នុងក្រសែផ្ទាល់គ្រប់ថ្នាក់នោះទេ ទោះបីជាចំណងអាពាហ៍ពិពាហ៍នោះបានបង្កើតឡើងដោយមានខាន់ស្លាក្តី ឬ ដោយឥតខាន់ស្លាក្តី ឬ ញាតិដែលកើតឡើងដោយសារការសុំកូនមកចិញ្ចឹមក្តី។[8]

អាពាហ៍ពិពាហ៍រវាងសាខាញាតិទោះបីមានខាន់ស្លាក្តី ឥតខាន់ស្លាក្តី សាច់ចិញ្ចឹមក្តី រួមផ្ទៃក្តី គឺមានន័យថាឪពុកនៃកូននោះបានផ្តល់កំណើតឲ្យកូននោះទៅលើផ្ទៃម្តាយផ្សេងគ្នា ដោយហេតុថាឪពុកនោះបានទ្វេពន្ធភាពក្នុងការរួមសមគ្គសង្វាស ឬ សាខាញាតិដែលកើតឡើងដោយសាររួមម្តាយតែមួយគឺមានន័យថា កូននោះបានកើតឡើងនៅក្នុងផ្ទៃម្តាយតែមួយប៉ុន្តែមានឪពុកផ្សេងគ្នា ឬ ក្រសែផ្ទាល់ក្តី ដោយពន្ធក្តី រហូតដល់ថ្នាក់ទី៣

[5] មាត្រា ៤៧ កថាខណ្ឌទី១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

[6] មាត្រា ៤៧ កថាខណ្ឌទី១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

[7] មាត្រា ១១៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០។

[8] មាត្រា ១១៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០។

រាប់ទាំងថ្នាក់ទី៣ ផងដែរត្រូវបានហាមឃាត់មិនឲ្យរៀបការនោះឡើយ។ ហើយមិនត្រឹមតែប៉ុណ្ណោះថ្នាក់ញាតិទាំងនោះត្រូវរាប់ដោយបូកចំនួនជនតាដែលបានបែកចេញពីគល់តែមួយជាសាខានីមួយៗផងដែរ ។[9]

ប៉ុន្តែជនប្រុសស្រីដែលមិនទាន់ដល់អាយុកំណត់ ឬជាញាតិនឹងគ្នាមានប្រាថ្នានិងយកគ្នាជាប្តីប្រពន្ធហើយ ឬ បើជាអនីតិថិជន ឪពុកម្តាយ ឬ អាណាព្យាបាលយកសេចក្តីនោះក្រាបបង្គំទូលសូមរៀបការចំពោះមុខព្រះចៅក្រុង។ ព្រះចៅក្រុងកម្ពុជាធិបតីនឹងព្រះរាជទានអនុញ្ញាតឲ្យរួចផុតពីការកំណត់អាយុ និងកម្រិតញាតិលោហិត ឬ ញាតិពន្ធនេះបាន តាមយោបល់របស់គណៈរដ្ឋមន្ត្រីដែលជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានស្នើជូនមក[10] រីឯសេចក្តីអនុញ្ញាតនេះអាចឲ្យសាខាញាតិត្រឹមថ្នាក់ទី៣  និងសាខាញាតិពន្ធត្រឹមថ្នាក់ទី២ តែប៉ុណ្ណោះ អាចយកគ្នាបាន។[11] បើអនីតិជនជាកូនមានខាន់ស្លា ឬ កូនកំព្រាឥតឪពុក ឥតម្តាយបុព្វញាតិដែលជាថ្នាក់ជិតបំផុតជាងគេមានសិទ្ធិឲ្យអនុញ្ញាតរៀបអាពាហ៍ពិពាហ៍បាន។ តែបើបុព្វញាតិមានថ្នាក់ស្មើគ្នាទាំងពីរ ត្រូវបុព្វញាតិខាងឪពុកនៃកូននោះមានសិទ្ធិឲ្យអនុញ្ញាតជាង។ បើមានការខ្វែងគំនិតគ្នា ត្រូវឲ្យជីតាជាអ្នកអនុញ្ញាត បើជីតាទទួលមរណៈភាព ត្រូវឲ្យជីដូនជាអ្នកអនុញ្ញាត[12] ហើយបើបុព្វញាតិដែលត្រូវបានអនុញ្ញាតឲ្យរៀបការនោះ មានសតិបញ្ញាមិនប្រក្រតី សិទ្ធិនេះទៅធ្លាក់ទៅលើបុព្វញាតិម្នាក់ទៀតទៅតាមលំដាប់ថ្នាក់។

ហើយអាពាហ៍ពិពាហ៍នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ នេះគឺបានចែងអំពីអាពាហ៍ពិពាហ៍មានពីរយ៉ាង[13] គឺអាពាហ៍ពិពាហ៍មានខាន់ស្លាទីមួយ និងអាពាហ៍ពិពាហ៍មានខាន់ស្លាទីពីរ។ ដោយបុរសមួយអាចយកប្រពន្ធបានច្រើននាក់[14] ក៏ប៉ុន្តែស្ត្រីម្នាក់អាចយកប្តីបានតែមួយតែប៉ុណ្ណោះ[15]។ ដោយសមគ្គសង្វាសជាធម្មានុរូប ដែលបុរសរៀបការជាដំបូងត្រូវទុកជាអាពាហ៍ពិពាហ៍ដែលមានខាន់ស្លាទីមួយបង្គស់ជាមួយនិងភរិយាដើម ហើយសមគ្គសង្វាសបន្តបន្ទាប់ត្រូវបានចាត់ទុកថាជាខាន់ស្លាទីពីរដែលរៀបអាពាហ៍ពិពាហ៍ជាមួយនិងភរិយាចុង។ ប៉ុន្តែប្រសិនបើ អាពាហ៍ពិពាហ៍ជាមួយនិងភរិយាដើមនោះបានចប់ដាច់ស្រេចហើយ ប្តីអាចរៀបអាពាហ៍ពិពាហ៍មានខាន់ស្លាទីមួយទៅនិងប្រពន្ធថ្មី ឬ ក៏ប្តីអាចលើកយកប្រពន្ធចុងណាម្នាក់ក្នុងចំណោមប្រពន្ធចុងដែលប្តីនោះមាន ធ្វើជាប្រពន្ធដើមបាន ប៉ុន្តែមុននិងលើកប្រពន្ធចុងណាម្នាក់ឲ្យធ្វើជាប្រពន្ធដើមនោះ បានលុះត្រាតែប្តីត្រូវនាំ

[9] មាត្រា ១១៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០។

[10] មាត្រា ១២១ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០។

[11] មាត្រា ១២៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០។

[12] មាត្រា ១២៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០។

[13] មាត្រា ១៣៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០។

[14] មាត្រា ១៤១ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០។

[15] មាត្រា ១៤០ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០។

សាក្សីចំនួនពីរនាក់ ទៅប្តឹងឲ្យច្បាស់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍របស់ខ្លួននិងប្រពន្ធចុងពីមុនថាខ្លួនលើកប្រពន្ធចុងម្នាក់នេះជាភរិយាទីមួយវិញ[16]។

ហើយចំពោះសិទ្ធិនិងករណីកិច្ចនៃប្តីប្រពន្ធ គឺប្តីប្រពន្ធត្រូវជួយនិងសង្គ្រោះគ្នាទៅវិញទៅមកព្រមទាំងប្តីត្រូវទំនុកបម្រុងប្រពន្ធទាំងឡាយ។[17] ហើយប្រពន្ធទាំងឡាយត្រូវទទួលស្គាល់ឱវាទប្តី និងត្រូវឱនលំទោនហើយស្លូតត្រង់ចំពោះប្តីផង។ ចំណែកឯប្រពន្ធចុងទាំងឡាយត្រូវស្តាប់បង្គាប់ និងកោតខ្លាចប្រពន្ធដើម[18] ហើយប្រពន្ធដើមត្រូវមានសិទ្ធិ និងករណីកិច្ចបាននៅលំនៅដ្ឋានជាមួយនិងស្វាមី[19] ។

កូនមានខាន់ស្លា[20]គឺជាកូនដែលបានកើតចេញពីផ្ទៃរបស់ម្តាយដែលស្ថិតនៅក្នុងវេលាដែលឪពុក និងម្តាយនៅជាប់អាពាហ៍ពិពាហ៍ជាមួយនិងគ្នា គឺសន្មត់ថាមាននៅពេលអាពាហ៍ពិពាហ៍នោះត្រឹមរយៈពេលលើសពី ១៨០ថ្ងៃដែលគិតចាប់ពីថ្ងៃដែលបានរៀបអាពាហ៍ពិពាហ៍មក និងក្នុងរយៈពេល៣០០ថ្ងៃ ចាប់ពីថ្ងៃដែលដាច់អាពាហ៍ពិពាហ៍នោះ។ រីឯកូនឥតខាន់ស្លា[21]គឺជាកូនដែលកើតចេញអំពីមាតាបិតាដែលចងពន្ធនិងគ្នា ដោយមិនបានរៀបការ។ ក៏ប៉ុន្តែកូនឥតខាន់ស្លាទទួលនូវធម្មានុរូបកម្មបាន[22] ដែលអាចគេទទួលស្គាល់ឡើងវិញកាលណាឪពុកម្តាយនោះបានរៀបការតាមច្បាប់ក្រោយ នោះកូនអត់ខាន់ស្លានឹងក្លាយជាកូនមានខាន់ស្លាវិញ។

### គ. ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩

ដោយយោងតាមច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារឆ្នាំ ១៩៨៩ មិនបានបង្ហាញពីដែនកំណត់នៃទំហំញាតិជាក់ច្បាស់នោះទេ ប៉ុន្តែច្បាប់នេះបានបង្ហាញអំពីបញ្ញត្តិដែលបានហាមឃាត់មិនឲ្យមានការកើតឡើងនូវការរៀបអាពាហ៍ពិពាហ៍រវាងបុគ្គលទាំងឡាយណា ដែលជាប់នូវចំណងសាច់សាលោហិតជាមួយគ្នានិងគ្នា ក្នុងនោះមានដូចជាញាតិលោហិតដែលមានដូចជាបុព្វញាតិ និងបច្ឆាញាតិ ញាតិពន្ធខ្សែផ្ទាល់គ្រប់ថ្នាក់ និងសាខាញាតិគ្រប់ថ្នាក់[23] ទោះបីចំណងនៃអាពាហ៍ពិពាហ៍នោះបានកើតឡើងដោយមានខាន់ស្លាក្តី ឥតខាន់ស្លាក្តី ឬ ក៏ជាកូនដែលសុំយកមកចិញ្ចឹមក្តី ជាញាតិដែលកើតឡើងដោយរួមម្តាយតែមួយក៏ដោយ(មានន័យថា កូនទាំងនោះបានកើតចេញពីផ្ទៃម្តាយតែមួយ ប៉ុន្តែមានឪពុកផ្សេងគ្នា ដោយហេតុថាម្តាយនៃកូននោះធ្លាប់មានចំណងបុត្រភាពជាមួយ

[16] មាត្រា ១៤៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០។

[17] មាត្រា ១៨៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០។

[18] មាត្រា ១៩០ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០។

[19]មាត្រា ១៩១ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ។

[20] មាត្រា ២៦៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០។

[21] មាត្រា ២៧៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០។

[22] មាត្រា ២៨៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០។

[23] មាត្រា ៧ នៃច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ,លេខ ៥៦ ក្រ. ២៦ កក្កដា ឆ្នាំ១៩៨៩។

និងអតីតស្វាមី ហើយក្រោយមកគាត់បានបង្កើតចំណងអាពាហ៍ពិពាហ៍ថ្មី និងបង្កើតកូនជាមួយនិងស្វាមីក្រោយទៀត) ការហាមឃាត់មិនឲ្យមានការរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិដែលរួមឪពុកជាមួយនិងគ្នា(គឺមានន័យថា ញាតិនេះបានកើតឡើងដោយសារតែឪពុកជាអ្នកផ្តល់កំណើតឲ្យកូននោះ ទៅកាន់ផ្ទៃម្តាយផ្សេងៗគ្នា ដោយហេតុថាឪពុកនៃកូននោះបានបង្កើតចំណងអាពាហ៍ពិពាហ៍ទាំងដោយមាននីតិសង្វាស ឬ អនីតិសង្វាសជាមួយនិងស្ត្រីផ្សេងៗគ្នា ទាំងដោយស្របតាមប្រពៃណីនិងច្បាប់ក្តី និងមិនស្របតាមប្រពៃណីនិងជាប់ក្តី ឬ យើងអាចនិយាយបានថា បុរសនោះគាត់មានភរិយាស្របច្បាប់រួចទៅហើយប៉ុន្តែគាត់លួចបង្កើតចំណងអនីតិសង្វាសជាមួយនិងនារីថ្មីដោយយកប្រពន្ធចុងបន្ថែម ឬ ករណីមួយទៀត គឺភរិយារបស់បុរសនោះបានទទួលមរណភាពហើយបុរសនោះបានយកនារីថ្មីមកធ្វើជាភរិយា និងបង្កើតនៅបុត្តភាពជាមួយនិងភរិយាក្រោយនោះ ) និងហាមឃាត់រហូតដល់ថ្នាក់ទី៣ ដោយរាប់ទាំងថ្នាក់ទី៣ នេះផងដែរនៃសាខាញាតិ។[24]

ប៉ុន្តែមានករណីពិសេសមួយចំនួនដែលបានច្បាប់បានចែង[25]ប្រសិនបើសហព័ទ្ធណាមួយទទួលមរណភាព គឺសហព័ទ្ធម្ខាងដែលរស់អាចបង្កើតចំណងអាពាហ៍ពិពាហ៍ដោយរៀបការជាមួយនិងសាខាញាតិពន្ធថ្នាក់ទី២ ឬ សាខាញាតិពន្ធថ្នាក់ទី៣ របស់សហព័ទ្ធខ្លួនបាន។ ក៏ប៉ុន្តែប្រសិនបើសហព័ទ្ធណាម្ខាងបានលែងលះគ្នាជាមួយនិងសហព័ទ្ធម្ខាងទៀត និងបានយកសាខាញាតិពន្ធថ្នាក់ទី២ ឬ ទី៣ របស់អតីតសហព័ទ្ធរបស់ខ្លួន មកធ្វើជាស្វាមី ឬ មួយក៏ភរិយាថ្មី គឺច្បាប់មិនបានអនុញ្ញាតឲ្យមានការបង្កើតឡើងនូវចំណងអាពាហ៍ពិពាហ៍នោះទេទោះបីជាចំណងអាពាហ៍ពិពាហ៍នោះមានខាន់ស្លាក៏ដោយ ឬ ឥតខាន់ស្លាក៏ដោយ ក៏ច្បាប់មិនអនុញ្ញាតឲ្យបុរសនារីនោះរួមនីតិសង្វាសជាមួយនិងគ្នាឡើយ។

ដោយយោងតាមច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារដដែល កូនសុំ គឺជាកិច្ចសន្យាដែលចងបុគ្គលពីរនាក់ដែលហៅថាឪពុក ឬ ម្តាយចិញ្ចឹម ម្នាក់ទៀតជាកូនចិញ្ចឹមឲ្យមានចំណងនិងគ្នាដូចបុត្តភាពមានខាន់ស្លាដែរ។ [26] ហើយឪពុកម្តាយដែលជាអ្នកសុំកូននោះត្រូវមានអាយុលើសពី ២៥ ឆ្នាំ និងត្រូវមានអាយុច្រើនជាងកូនចិញ្ចឹមនោះ ២០ ឆ្នាំ[27] ហើយកូនដែលសុំនោះអាចសុំបានតែ២ ប៉ុណ្ណោះ និងកូនចិញ្ចឹមនោះត្រូវមានអាយុយ៉ាងតិចត្រឹម ៨ ឆ្នាំ[28]។ បើកូនណាមួយស្លាប់ គឺឪពុកម្តាយចិញ្ចឹមអាចសុំកូនម្នាក់ទៀតមកចិញ្ចឹមបន្ថែមបាន។ ហើយការសុំកូនយកមកចិញ្ចឹមនេះអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតដែលជាស្វាមីគឺ

---

[24] មាត្រា ៨ នៃច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ,លេខ ៥៦ ក្រ. ២៦ កក្កដា ឆ្នាំ១៩៨៩។

[25] មាត្រា ៨ កថាខណ្ឌទី២ នៃច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ,លេខ ៥៦ ក្រ. ២៦ កក្កដា ឆ្នាំ១៩៨៩។

[26] មាត្រា ១០៨ នៃច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ,លេខ ៥៦ ក្រ. ២៦ កក្កដា ឆ្នាំ១៩៨៩។

[27] មាត្រា ១០៩ នៃច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ,លេខ ៥៦ ក្រ. ២៦ កក្កដា ឆ្នាំ១៩៨៩។

[28] មាត្រា ១១០ នៃច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ,លេខ ៥៦ ក្រ. ២៦ កក្កដា ឆ្នាំ១៩៨៩។

ភរិយា ទើបអាចសុំកូននោះយកមកចិញ្ចឹមបាន ហើយកូនដែលចិញ្ចឹមយកមកសុំនោះ ចាត់ទុកជាកូនចិញ្ចឹមរបស់សហព័ទ្ធម្ខាងទៀតផងដែរ[29]។

ហើយដើម្បីសុំកូននោះ មកចិញ្ចឹមបាន គឺត្រូវមានការព្រមព្រៀងពីឪពុកម្ដាយបង្កើត ឬ អ្នកអាណាព្យាបាលនៃកូននោះសិន។ ហើយប្រសិនបើជាទារកដែលត្រូវគេបំបោះបង់ចោល គឺត្រូវមានការយកព្រមពីរដ្ឋអំណាចឃុំសង្កាត់។ ហើយចំពោះកិច្ចសន្យាសុំកូននេះគឺត្រូវធ្វើជាអក្សរដោយមានបញ្ជាក់ពីគណៈកម្មាធិការប្រជាជនឃុំសង្កាត់នៅខាងលំនៅដ្ឋាននៃអ្នកសុំ ឬ ខាងកូនសុំ[30] ហើយសេចក្ដីនៅកិច្ចសន្យាសុំកូនមកចិញ្ចឹមនោះ ត្រូវចុះបញ្ជីអត្រានុកូលដ្ឋាន។ ហើយនាមត្រកូលនៃឪពុកម្ដាយកូនចិញ្ចឹម នោះត្រូវយកមកធ្វើជានាមត្រកូលរបស់កូនចិញ្ចឹមនោះ ហើយកូនដែលសុំនោះគឺមានសិទ្ធិ កាតព្វកិច្ច និងឋានៈដូចគ្នាទៅនិងកូនបង្កើតផងដែរ[31]។

**ឃ. ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧**

ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បង្កើតឡើងដោយគោលការណ៍ទូទៅចំនួនពីរ ដែលបានបញ្ញត្តិក្នុងក្រមនេះរួមមានទំនាក់ទំនងទ្រព្យសម្បត្តិ និង ទំនាក់ទំនងញាតិ។[32]

ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានកំណត់នៅទំហំញាតិយ៉ាងច្បាស់លាស់។ យោងតាមមាត្រា ៩៣៨ បានបញ្ញត្តិអំពីទំហំញាតិ ដោយត្រូវបានបែងចែកជាបី គឺ ញាតិលោហិតក្នុង ៦ ថ្នាក់ សហព័ទ្ធ និង ញាតិពន្ធ។[33]

ញាតិលោហិត សំដៅលើបុគ្គលដែលមានទំនាក់ទំនងសាច់សាលោហិតពីកំណើតជាមួយបុគ្គលម្នាក់ទៀត (ញាតិលោហិតពីកំណើត) ឬ បុគ្គលដែលត្រូវបានចាត់ទុកដោយច្បាប់ថា មានទំនាក់ទំនងសាច់សាលោហិតជាមួយបុគ្គលជាក់លាក់ម្នាក់ទៀតនោះ (ញាតិលោហិតដែលកំណត់ដោយច្បាប់)។

សហព័ទ្ធ គឺជាញាតិរបស់របស់សហព័ទ្ធម្ខាងទៀត ពីព្រោះក្រមនេះបានបញ្ញត្តិថា សហព័ទ្ធជាសន្តតិជនជានិច្ច។

ញាតិពន្ធ សំដៅលើទំនាក់ទំនងរវាងខ្លួនជាមួយនឹងញាតិលោហិតរបស់សហព័ទ្ធរបស់ខ្លួន ឬ ទំនាក់ទំនងរវាងញាតិលោហិតរបស់ខ្លួនជាមួយនិងសហព័ទ្ធរបស់ខ្លួន។

**ង. ច្បាប់ស្ដីពីសញ្ជាតិ ឆ្នាំ២០១៨**

សញ្ជាតិខ្មែរ សំដៅដល់ចំណងគតិយុត្ត និងនយោបាយដែលភ្ជាប់រូបវន្តបុគ្គលទៅនិងព្រះរាជាណាចក្រកម្ពុជា។

យោងតាមច្បាប់ស្ដីពី សញ្ជាតិ ឆ្នាំ២០១៨ ការទទួលបានសញ្ជាតិខ្មែរ អាចកើតឡើងនៅក្នុងករណី ៤ ធំៗ ៖

---

[29] មាត្រា ១១១ នៃច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ,លេខ ៥៦ ក្រ. ២៦ កក្កដា ឆ្នាំ១៩៨៩។

[30] មាត្រា ១១៣ នៃច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ,លេខ ៥៦ ក្រ. ២៦ កក្កដា ឆ្នាំ១៩៨៩។

[31] មាត្រា ១១៤ នៃច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ,លេខ ៥៦ ក្រ. ២៦ កក្កដា ឆ្នាំ១៩៨៩។

[32] មាត្រា ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[33] មាត្រា ៩៣៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

❖ ករណី១៖ ការទទួលបានសញ្ជាតិខ្មែរពីកំណើត

ការទទួលបានសញ្ជាតិខ្មែរពីកំណើត គឺកូនដែលបានកើតចេញពីឪពុក ឬ ម្តាយដែលមានសញ្ជាតិខ្មែរ គឺកូននោះត្រូវទទួលបានសញ្ជាតិខ្មែរពីកំណើត ទោះបីកូននោះកើតនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាក៏ដោយ ឬ ក៏នៅឯបរទេសក៏ដោយ។ ហើយកូនដែលឪពុកម្តាយមិនទទួលស្គាល់ ឬ បោះបង់ចោល ប្រសិនបើតុលាការបានចេញសាលក្រមថា កូននោះពិតជាកើតចេញពីឪពុកម្តាយជាជនជាតិខ្មែរ កូននោះត្រូវចាត់ទុកថាជាជនជាតិខ្មែរ និងទទួលបានសញ្ជាតិខ្មែរ។ ប៉ុន្តែប្រសិនបើកូននោះបានកើតចេញពីឪពុកម្តាយជាជនបរទេស បើកូននោះបានកើតនិងរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ កូនដែលកើតអំពីឪពុកម្តាយដែលបោះបង់ចោល និងកូននោះទើបនឹងកើតដែលគេរើសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានចាត់ទុកថាកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងត្រូវបានទទួលសញ្ជាតិខ្មែរផងដែរ។[34]

❖ ករណី២៖ ការទទួលបានសញ្ជាតិខ្មែរដោយសុំកូនពេញលេញ

កូនជនបរទេសដែលត្រូវបានសុំជាកូនសុំពេញលេញដោយសហព័ទ្ធជាពលរដ្ឋខ្មែរ ត្រូវទទួលបានសញ្ជាតិខ្មែរ នៅពេលដែលសុំកូនពេញលេញត្រូវបានបង្កើតឡើងស្របតាមច្បាប់ជាធរមាន។ ហើយកូនដែលជាជនបរទេសនោះត្រូវលះបង់សញ្ជាតិដើមរបស់ខ្លួន ទំនាក់ទំនងគ្រួសារជាមួយឪពុកម្តាយបង្កើតរបស់ខ្លួន ដើម្បីទទួលបានសិទ្ធិ និងកាតព្វកិច្ច ព្រមទាំងឋានៈស្មើនឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម។[35]

❖ ករណី៣៖ ការទទួលបានសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍

ស្ត្រី ឬ បុរសដែលយកប្តី ឬ ប្រពន្ធជាពលរដ្ឋខ្មែរដោយបានរៀបអាពាហ៍ពិពាហ៍ អាចទាមទារសញ្ជាតិខ្មែរបាន លុះណាតែស្ត្រី ឬ បុរសនោះបានរស់នៅជាមួយគ្នារយៈពេលបីឆ្នាំ ក្រោយចុះបញ្ជីអាពាហ៍ពិពាហ៍ និងបានស្នាក់នៅយ៉ាងហោចរយៈពេល ១២ខែ ពេញលេញ ក្នុងព្រះរាជាណាចក្រកម្ពុជា(យោងមាត្រា ១១ នៃច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ២០១៨)។ ត្រូវបានអនុញ្ញាតឲ្យសុំទាមទារសញ្ជាតិខ្មែរជាចង្កោមគ្រួសារចំពោះជនបរទេសជាម្តាយ ឬ ឪពុកដែលមានកូនជាអនីតិជន។[36]

យោងតាមមាត្រា ១២ នៃច្បាប់សញ្ជាតិឆ្នាំ២០១៨ ជនបរទេសដែលអាចសុំទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍បាន ត្រូវបំពេញល័ក្ខខ័ណ្ឌដូចតទៅ៖ (១) មានគំនិត មាយាទ និងសីលធម៌ល្អ (២) ពុំដែលមានទោសពីបទឧក្រិដ្ឋ ឬ បទមជ្ឈឹមណាមួយ (៣) មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅពេលដាក់ពាក្យសុំ

[34] មាត្រា ៩ នៃច្បាប់ស្តីពី សញ្ជាតិ ឆ្នាំ២០១៨។

[35] មាត្រា ១០ នៃច្បាប់ស្តីពី សញ្ជាតិ ឆ្នាំ២០១៨។

[36] មាត្រា ១១ នៃច្បាប់ស្តីពី សញ្ជាតិ ឆ្នាំ២០១៨។

ទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ (៤) ចេះនិយាយភាសាខ្មែរ ចេះអក្សរខ្មែរ និងយល់ដឹងប្រវត្តិសាស្ត្រខ្មែរខ្លះ (៥) មានបញ្ញា និងកាយសម្បទាដែលមិននាំឲ្យមានគ្រោះថ្នាក់ ឬ នាំឲ្យមានបន្ទុកដល់ជាតិ។[37]

បែបបទនិងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ ត្រូវកំណត់ដោយអនុក្រឹត្យ។ ការផ្តល់សញ្ជាតិខ្មែរ តាមករណីទាមទារសញ្ជាតិ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ។ ជាការកត់សម្គាល់ ច្បាប់បានបញ្ជាក់ថា នៅក្នុងករណីនេះ ប្រជាពលរដ្ឋខ្មែរមិនបាត់សញ្ជាតិខ្មែរ ដោយសារតែការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសឡើយ។

❖ ករណី៤៖ ការទទួលបានសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម

ជនបរទេសអាចសុំចូលសញ្ជាតិខ្មែរបាន ដោយសញ្ជាតូបនីយកម្ម ។ សញ្ជាតូបនីយកម្ម មិនមែនជាសិទ្ធិរបស់អ្នកសុំឡើយ គឺជាការអនុគ្រោះរបស់ព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ ។ ទោះក្នុងប្រការណាក៏ដោយ ពាក្យសុំនោះអាចត្រូវបដិសេធចោលតាមអំណាចឆន្ទានុសិទ្ធិ (មាត្រា ១៨ នៃច្បាប់ស្តីពី សញ្ជាតិ ឆ្នាំ២០១៨) ។

យោងទៅតាមច្បាប់ស្តីពីសញ្ជាតិថ្មី ជនបរទេស ជាគោលការណ៍អាចសុំចូលសញ្ជាតិខ្មែរបានដោយសញ្ជាតូបនីយកម្ម។ សញ្ជាតូបនីយកម្ម មិនមែនជាសិទ្ធិរបស់អ្នកស្នើសុំឡើយ គឺជាការអនុគ្រោះរបស់ព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ ក្នុងការសម្រេចឲ្យជនបរទេសណាម្នាក់ទទួលសញ្ជាតិខ្មែរ[38]។ ទោះក្នុងប្រការណាក៏ដោយ ពាក្យសុំនោះអាចត្រូវបដិសេធចោលបានតាមអំណាចឆន្ទានុសិទ្ធិរបស់ប្រទេសកម្ពុជាបាន។

ម្យ៉ាងវិញទៀត ជនបរទេសដែលមានសហព័ទ្ធ ឬ កូនជាអនីតិជន ដែលមានបំណងស្នើសុំចូលសញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម អាចដាក់ពាក្យស្នើសុំជាចង្កោមគ្រួសារ ។ លើសពីនេះទៀត ជនបរទេសអាចសុំដូរផ្លាស់ឈ្មោះជាខ្មែរបាន ដោយក្នុងករណីនេះ ត្រូវសរសេរបញ្ជាក់ឈ្មោះ នោះក្នុងពាក្យសុំសញ្ជាតូបនីយកម្មរបស់ខ្លួន។

រីឯ ជនបរទេសដែលបានទទួលលិខិតអនុញ្ញាតឲ្យវិនិយោគត្រឹមត្រូវតាមច្បាប់[39] ពីស្ថាប័នមានសមត្ថកិច្ច (ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា) ហើយបានចំណាយទុនអនុវត្តគម្រោងវិនិយោគជាក់ស្តែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជនបរទេសនោះអាចដាក់ពាក្យសុំចូលសញ្ជាតូបនីយកម្មបាន ក្នុងករណីជនបរទេសនោះបានបំពេញល័ក្ខខ័ណ្ឌដូចមានចែងក្នុងចំណុចទី១ ទី២ ទី៤ ទី៥ និងទី៦ មាត្រា ១៩នៃច្បាប់នេះ និងបានស្នាក់នៅស្របច្បាប់យ៉ាងហោចរយៈពេល១២ខែ ពេញលេញក្នុងព្រះរាជាណាចក្រកម្ពុជា។ ចំនួនទឹកប្រាក់ វិស័យអាទិភាព និងប្រភេទគម្រោង វិនិយោគ ព្រមទាំងល័ក្ខខ័ណ្ឌផ្សេងទៀត ត្រូវកំណត់ដោយអនុក្រឹត្យ។

---

[37] មាត្រា ១២ នៃច្បាប់ស្តីពី សញ្ជាតិ ឆ្នាំ២០១៨។

[38] មាត្រា ១៨ នៃច្បាប់ស្តីពី សញ្ជាតិ ឆ្នាំ២០១៨។

[39] មាត្រា ២១ នៃច្បាប់ស្តីពី សញ្ជាតិ ឆ្នាំ២០១៨។

ជនបរទេសណា ដែលបានធ្វើអំណោយជាសាច់ប្រាក់ដល់ថវិកាជាតិ[40] សម្រាប់ជាផលប្រយោជន៍ដល់ការអភិវឌ្ឍសេដ្ឋកិច្ច ឬ វិស័យមនុស្សធម៌នៅព្រះរាជាណាចក្រកម្ពុជា ជនបរទេសនោះអាចដាក់ពាក្យសុំចូលសញ្ជាតិខ្មែរបាន ក្នុងករណីដែលជននោះបានបំពេញល័ក្ខខ័ណ្ឌដូចមានចែងក្នុងចំណុចទី១ ទី២ ទី៤ និងទី៦ មាត្រា ១៩ នៃច្បាប់នេះ និងបានស្នាក់នៅស្របច្បាប់យ៉ាងហោចរយៈពេល ៦ខែពេញលេញ ក្នុងព្រះរាជាណាចក្រកម្ពុជា។ ចំនួនទឹកប្រាក់អំណោយជាសាច់ប្រាក់ដល់ថវិកាជាតិ ឬវិស័យមនុស្សធម៌ត្រូវកំណត់ដោយអនុក្រឹត្យ។ បន្ថែមជាងនេះទៅទៀត ចំពោះជនបរទេសដែលបានបង្ហាញនូវភស្តុតាងថា បានផ្តល់គុណសម្បត្តិពិសេស ឬថ្វីដៃពិសេសអ្វីមួយជាប្រយោជន៍ដល់ព្រះរាជាណាចក្រកម្ពុជា និងបានទទួលស្គាល់ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាចដាក់ពាក្យស្នើសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម ។

[40] មាត្រា ២២ នៃច្បាប់ស្តីពី សញ្ជាតិ ឆ្នាំ២០១៨។

# ជំពូកទី២

# របបគតិយុត្តនៃការបង្កើតញ្ញាតិភាព

# ជំពូកទី២
# របបគតិយុត្តនៃការបង្កើតញាតិភាព

របបគតិយុត្តនៃការបង្កើតញាតិភាព នាពេលបច្ចុប្បន្នមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ត្រង់គន្ថីទី៧។

## ២.១. ខ្សែលោហិត

ខ្សែរលោហិត គឺជាញាតិដែលកើតឡើងដោយសារការជាប់ឈាមជ័រជាមួយគ្នា ដែលកើតចេញពីតំណពូជរួមលោហិតជាមួយគ្នាពីមួយលំដាប់ទៅមួយលំដាប់ ពីមួយជំនាន់ទៅមួយជំនាន់គឺជាបុគ្គលដែលមានទំនាក់ទំនងលោហិតនឹងគ្នា។

### ក. បុព្វញាតិ

បុព្វញាតិ[41] គឺជាញាតិលោហិតខ្សែផ្ទាល់ដែលបានកកើតមុន និងមានឋានៈខ្ពស់ជាងយើងក្នុងគ្រួសារដែលរាប់ចាប់ពីអ្នកដែលស្ថិតនៅក្នុងថ្នាក់ទី១នៃខ្សែបន្ទាត់នៃញាតិលោហិត ដែលត្រូវជាបុព្វជនរបស់យើង។ ហើយមួយវិញទៀតបុព្វញាតិ គឺជាអ្នកដែលផ្តល់នូវតំណលោហិតដែលបញ្ជូនមកអ្នកជំនាន់ក្រោយ ពីមួយជំនាន់ទៅមួយជំនាន់ រហូតមកដល់យើងដែលត្រូវជាអ្នកកើតចេញពីឈាមជ័រតែមួយ ដែលមានដូចជា ពីជីប៉ាទៅជីលា ពីជីលាទៅជីលួត ពីជីលួតទៅជីទួត ពីជីទួតទៅជីតា ពីជីតាទៅឪពុក ពីឪពុកទៅកូនជាដើម។[42] ហើយចំពោះបុព្វញាតិដែលបុព្វញាតិជំនាន់មុនស្មុំវិញ ក៏យើងចាត់ទុកជាបុព្វញាតិខ្សែផ្ទាល់ក្នុង៦ថ្នាក់របស់យើងដែរ។[43]

### ខ. បច្ឆាញាតិ

បច្ឆាញាតិ[44] គឺជាញាតិលោហិតខ្សែផ្ទាល់ដែលកើតនៅជំនាន់ក្រោយ និងមានថ្នាក់ទាបជាងខ្លួនយើង។ ហើយបច្ឆាញាតិនេះ គឺជាញាតិដែលសំខាន់បន្ទាប់ពីបុព្វញាតិ ដែលជាអ្នកស្នងនូវតំណលោហិតបន្តពីជំនាន់យើងទៅជំនាន់ក្រោយៗដែលនៅថ្នាក់ក្រោមបន្ទាប់ពីយើង ឬ ញាតិស្រករក្រោយខ្សែផ្ទាល់របស់យើង។ ហើយចំពោះកូនស្មុំវិញក៏យើងចាត់ទុកជាបច្ឆាញាតិខ្សែផ្ទាល់ក្នុង៦ថ្នាក់របស់យើងដែរ។[45] ប៉ុន្តែក្នុងពេលបច្ចុប្បន្ននេះភាគច្រើនគេរាប់ថ្នាក់បច្ឆាញាតិត្រឹមតែជំនាន់ចៅទួតតែប៉ុណ្ណោះ គឺដោយសារតែពេលខ្លះសាមីខ្លួនមិនអាចរស់នៅមានជីវិតបន្តរហូតដល់ជំនាន់ចៅទួត ឬ ចៅលួតឡើយ ជាហេតុធ្វើឲ្យការរាប់ថ្នាក់នៃបច្ឆាញាតិនេះ គឺមាន

---

[41] មាត្រា ៩៣៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។
[42] មាត្រា ៩៣៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។
[43] មាត្រា ១០១៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។
[44] មាត្រា ៩៣៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។
[45] មាត្រា ១០១៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

លក្ខណៈប្រែប្រួលទៅតាមសាមីខ្លួននីមួយៗ[46]។ ហើយបច្ឆាញាតិនេះមានដូចជា កូន ចៅ ចៅទួត ចៅលួត ចៅលា ចៅប៉ា ជាដើម។

**គ. សាខាញាតិ**

សាខាញាតិ[47] គឺជាញាតិដែលកើតឡើងដោយសារមានការជាប់ឈាមជ័រ ឬ តំណលោហិតជាមួយគ្នា រវាងញាតិដែលនៅក្នុងថ្នាក់ដូចគ្នា ឬ នៅក្នុងថ្នាក់បុព្វញាតិនៃខ្សែញាតិលោហិតក្នុង៦ថ្នាក់ ដែលបែកចេញពីអ្នកបង្កើតរួម ឬ បុព្វញាតិរួមតែមួយ[48]។ ហើយសាខាញាតិនេះមានដូចជា អ្នកដែលស្ថិតនៅក្នុងលំដាប់ថ្នាក់ទី១នៃបុព្វញាតិ ឬ អ្នកដែលស្ថិតនៅក្នុងលំដាប់ថ្នាក់ស្មើនិងយើង ឬ ថ្នាក់ក្រោមយើងនៃបុព្វញាតិរួមតែមួយ ជាដើម។ ហើយចំពោះសាខាញាតិដែលបុព្វញាតិជំនាន់មុនស្មុំ ឬ បច្ឆាញាតិស្មុំ ក៏យើងចាត់ទុកជាសាខាញាតិខ្សែផ្ទាល់របស់យើងផងដែរ។[49]

ហើយសាខាញាតិនេះ ក៏ត្រូវបានបែងចែកជាពីរគឺ បុព្វញាតិនៃសាខាញាតិលោហិត និងបច្ឆាញាតិនៃសាខាលោហិត។ ចំពោះបុព្វញាតិនៃសាខាញាតិលោហិតមានដូចជា ជីទួតជីលួតមួយ ជីដូនជីតាជីទួតមួយ ជីដូនជីតាជីដូនមួយជាដើម។ ហើយបច្ឆាញាតិនៃសាខាញាតិលោហិតនេះមានដូចជា ចៅជីដូនមួយ ក្មួយជីដូនមួយ បងប្អូនជីដូនមួយជាដើម។

### ២.១.១. តំណពូជពីធម្មជាតិ

ទោះបីជាមានតំណពូជរួមឈាមជ័រជាមួយគ្នាយ៉ាងណាក៏ដោយ តែតំណពូជពីធម្មជាតិនេះមិនអាចកំណត់ជាក់លាក់ថាជាញាតិលោហិតនិងគ្នាតាមផ្លូវច្បាប់បាននោះទេ គឺមានករណីជាច្រើនដែលបង្ករជាបញ្ហាក្នុងការកំណត់ជាក់លក្ខខ័ណ្ឌនៃញាតិនេះផងដែរ។ ដើម្បីកំណត់បុគ្គលម្នាក់នោះ ថាជាញាតិនៃខ្សែលោហិតនិងគ្នាតាមផ្លូវច្បាប់បាន គឺគេត្រូវពិចារណាអំពីលក្ខខ័ណ្ឌដែលច្បាប់បានកំណត់អំពីធាតុពិតនៃកូននោះ ថាកូននោះជាកូនរបស់ឪពុកដែរឬទេ ប៉ុន្តែប្រសិនបើតាមលក្ខខ័ណ្ឌដែលច្បាប់បានកំណត់មិនត្រូវបានបំពេញនោះ កូននោះក៏មិនអាចទទួលស្គាល់តាមផ្លូវច្បាប់ថាជាកូនបង្កើតបានឡើយ។

ហើយដើម្បីទទួលស្គាល់ទំនាក់ទំនងឪពុក ម្តាយ និងកូន តាមផ្លូវច្បាប់បានគឺលុះត្រាតែបានបំពេញលក្ខខ័ណ្ឌមួយចំនួនដូចជាទំនាក់ទំនងរវាងម្តាយនិងកូន និងទំនាក់ទំនងរវាងឪពុកនិងកូនជាដើម។

---

[46] មាត្រា ៩៣៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[47] មាត្រា ៩៣៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[48] មាត្រា ៩៣៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[49] មាត្រា ១០១៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

### ក. ទំនងទំនងរវាងម្ដាយ និងកូន

ស្ត្រីដែលបានសម្រាលកូន គឺជាម្ដាយរបស់កូននោះ ដោយហេតុបានសម្រាលកូននោះ[50] អំពី អត្ថិភាពនៃមាតុភាព។ ម្ដាយអាចដាក់ពាក្យបណ្ដឹងទាមទារឲ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ចំពោះកូនដែលខ្លួនបានបង្កើតបានក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ដោយគិតចាប់ពីពេលដែលខ្លួនបានដឹងថាជាកូន។ ហើយម្ដាយ អាចដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌខាងលើនេះ ចំពោះកូនដែលបានទទួលមរណភាពបាន តែក្នុងករណីដែលកូននោះមានបច្ឆាញាតិផ្ទាល់ គឺម្ដាយអាចដាក់ពាក្យបណ្ដឹងបាន នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃមរណភាពរបស់កូន ប្រសិនបើបានដឹងថាជាកូន នៅក្រោយមរណភាពរបស់កូននោះ ។[51]

ប្រសិនបើម្ដាយជាជននៅក្រោមអាណាព្យាបាលទូទៅ នៅពេលដែលអំឡុងពេលដែលបានកំណត់នៅ ត្រូវគណនាដោយគិតចាប់ពីពេលដែលមាន ការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ។[52] ក្នុងករណីដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូន ដែលជាភាគីម្ខាងនៃបណ្ដឹងជានីតិជន បើគ្មានការយល់ព្រមពីកូន ឬ បច្ឆាញាតិផ្ទាល់នោះទេ ម្ដាយមិនអាចដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅខាងលើបានឡើយ។ ទោះបីជាក្នុងករណីដែលអង្គហេតុនៃការបង្កើតកូន ត្រូវបានបញ្ជាក់ក៏ដោយ ប្រសិនបើការបញ្ជាក់មាតុភាព ផ្ទុយនិងផលប្រយោជន៍របស់កូន បច្ឆាញាតិផ្ទាល់របស់ កូននោះ តុលាការអាចលើកចោលបណ្ដឹងរបស់ម្ដាយបាន។

### ខ. ទំនងទំនងរវាងកូន និង ម្ដាយ

កូនអាចដាក់ពាក្យបណ្ដឹងទាមទារឲ្យ បញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ចំពោះស្ត្រីដែលបានបង្កើតខ្លួនបាន។[53] ប្រសិនបើកូនបានទទួលមរណភាព បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី។ កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅខាងលើនេះបាន ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ដោយគិតចាប់ពី ពេលដែលបានដឹងថាជាម្ដាយ។ ក្នុងករណីដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ ជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ នៅពេលដែលបានដឹងថាជាម្ដាយ អំឡុងពេលដែលបាន កំណត់នៅខាងលើនេះ គឺត្រូវគណនា ដោយគិតចាប់ពីពេលដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ បានក្លាយជានីតិជន ឬ ពេលដែលមានការលុបចោល ការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ២៧ (ការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ) នៃក្រមរដ្ឋ

[50] មាត្រា ៩៨៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[51] មាត្រា ១០០៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[52] មាត្រា ២៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[53] មាត្រា ១០០៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

ប្បវេណី។[54] កូន ឬ បច្ឆាញាតិផ្ទាល់របស់កូន អាចដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ប្រសិនបើបានដឹងថាជាម្ដាយ នៅក្រោយមរណភាពរបស់ម្ដាយ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃមរណភាព។

### គ. ទំនងទំនងរវាងឪពុក និង កូន

ឪពុករបស់កូន អាចទទួលស្គាល់កូនបាន ប៉ុន្តែប្រសិនបើកូននោះមានឪពុក តាមផ្លូវច្បាប់រួចហើយ ពុំអាចទទួលស្គាល់បានឡើយ។[55]ហើយដើម្បីទទួលស្គាល់ ទោះបីជាឪពុកជាអនីតិជន ឬជាជននៅក្រោមអាណាព្យាបាលទូទៅក៏ដោយ ក៏ពុំចាំបាច់មានការយល់ព្រម ពីអ្នកតំណាងដែលច្បាប់បានកំណត់ឡើយ។[56] ឪពុកអាចទទួលស្គាល់កូនដែលជាអនីតិជនបាន ហើយទោះជាទារកនៅក្នុងគភ៌ក៏ដោយ ក៏ឪពុកនៅតែអាចទទួលស្គាល់កូននោះបាន ដោយទទួលការយល់ព្រមពីម្ដាយ។[57]ចំពោះការទទួលស្គាល់កូនជានីតិជន និង កូនដែលបានទទួលមរណភាព គឺឪពុកដែលមានបំណងចង់ទទួលស្គាល់កូនដែលជានីតិជន មិនអាចទទួលស្គាល់បានឡើយ បើសិនជាគ្មានការយល់ព្រមពីកូននោះ។ ហើយឪពុករបស់កូន អាចទទួលស្គាល់កូនដែលទទួលមរណភាពនោះបាន តែក្នុងករណី ដែលកូននោះមានបច្ឆាញាតិផ្ទាល់ តែបើបច្ឆាញាតិផ្ទាល់នោះជាអនីតិជន គេត្រូវមានការទទួលស្គាល់ពីជននោះវិញ។[58]

### ឃ. ទំនងទំនងរវាងកូន និង ឪពុក

កូនអាចដាក់ពាក្យបណ្ដឹងទាមទារឲ្យឪពុកទទួលស្គាល់បាន។ ប៉ុន្តែកូនដែលមិនយល់ព្រមទេ គឺពុំអាចទាមទារឲ្យទទួលស្គាល់បានឡើយ។[59] ប្រសិនបើកូនបានទទួលមរណភាព បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្ដឹងទាមទារឲ្យទទួលស្គាល់បាន។ កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្ដឹងទាមទារឲ្យទទួលស្គាល់បាន ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ដោយគិតចាប់ពីពេលដែលបានដឹងថាជាឪពុក។ ក្នុងករណីដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ ជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ នៅពេលដែលខ្លួនបានដឹងថាជាឪពុក អំឡុងពេលដែលបានកំណត់ ត្រូវគណនាគិតចាប់ពីពេលដែលកូន ឬ

[54] មាត្រា ២៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[55] មាត្រា ៩៩៣ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[56] មាត្រា ៩៩៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[57] មាត្រា ៩៩៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[58] មាត្រា ៩៩៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[59] មាត្រា ១០០១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

បច្ឆាញាតិផ្ទាល់របស់កូននោះ បានក្លាយជានីតិជន ឬ ពេលដែលមានការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ២៧ (ការលុប ចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ) នៃក្រមរដ្ឋប្បវេណី។ កូន ឬ បច្ឆាញាតិផ្ទាល់របស់កូន អាចដាក់ពាក្យបណ្ដឹងទាមទារឲ្យទទួលស្គាល់បាននៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃមរណភាពរបស់ឪពុក ប្រសិនបើបានដឹងថាជាឪពុកនៅក្រោយមរណភាពរបស់ឪពុក។ បណ្ដឹងដែលបានកំណត់នៅខាងលើនេះ អ្នកតំណាងដែលច្បាប់បានកំណត់របស់កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្ដឹងទាមទារឲ្យទទួលស្គាល់ជំនួសជនទាំងនោះបាន។

## ២.២. សហព័ទ្ធ

សហព័ទ្ធ គឺជាញាតិរបស់របស់សហព័ទ្ធម្ខាងទៀត បើយោងទៅតាមក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ពីព្រោះក្រមនេះបានបញ្ញត្តិថា សហព័ទ្ធជាសន្តតិជនជានិច្ច[60]។ ហើយដើម្បីអាចក្លាយជាសហព័ទ្ធនិងគ្នាបានបុរស និង នារីត្រូវតែឆ្លងការរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយគ្នាទើបបង្កើតបានជាសហព័ទ្ធ។ ទន្ទឹមជាមួយគ្នានេះផងដែល ក្រមរដ្ឋប្បវេណីបានបញ្ញត្តិមាត្រា ៩៤៤ ដែលស្ដីពីកំជាប់ពាក្យ ដែលជាដំណាក់កាលដំបូងក្នុងការបង្កើតចំណងអាពាហ៍ពិពាហ៍ ដើម្បីបង្កើតសហព័ទ្ធនិងគ្នារវាងបុរសនារី។

### ២.២.១. កំជាប់ពាក្យ

កំជាប់ពាក្យ ត្រូវបានបង្កើតតាមសេចក្ដីសន្យាដែលបុរស និង នារីបានព្រមព្រៀងគ្នាថានឹងរៀបអាពាហ៍ពិពាហ៍រវាងគ្នានាពេលអនាគត ដោយសន្យាធ្វើពិធីកំជាប់ពាក្យ[61]។ ដោយហេតុថា ការសន្យានេះហើយទើបធ្វើឲ្យបុរស និង នារីត្រូវធ្វើពិធីកំជាប់ពាក្យ ដើម្បីបញ្ជាក់ថាអ្នកទាំងពីរជាគូរនិងគ្នា ហើយដើម្បីប្រកាសប្រាប់មនុស្សទាំងអស់គ្នាថាបុរស និង នារីនោះមានម្ចាស់រួចហើយ។

* សូមបញ្ជាក់ថា កំជាប់ពាក្យមិនមែនជាកាតព្វកិច្ចដែលច្បាប់កំណត់អោយធ្វើមុនពេលរៀបអាពាហ៍ពិពាហ៍ទេ។ បុរសនារីអាចធ្វើកំជាប់ពាក្យមុនពេលរៀបអាពាហ៍ពិពាហ៍ក៏បាន ឬ មិនចាំបាច់ធ្វើកំជាប់ពាក្យមុនពេលរៀបអាពាហ៍ពិពាហ៍ក៏បាន។ ប៉ុន្តែបើធ្វើកំជាប់ពាក្យមុនពេលរៀបអាពាហ៍ពិពាហ៍ គឺជាការអនុវត្តទៅតាមប្រពៃណីទំនៀមទម្លាប់ដូចខាងកក្រោម៖

#### ២.២.១.១. ការបង្កើតកំជាប់ពាក្យ

កំជាប់ពាក្យ គឺជាពិធីមួយដែលគេធ្វើឡើងនៅមុនពេលរៀបអាពាហ៍ពិពាហ៍ ដើម្បីជាសញ្ញាណមួយបញ្ជាក់ថាបុរស ឬ នារីនោះ មានគូរកំណាន់ និង ម្ចាស់ចិត្តរួចហើយ។ លើសពីនេះទៅទៀត វាក៏ជាល័ក្ខខ័ណ្ឌមួយ

[60] មាត្រា ១១៦១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[61] មាត្រា ៩៤៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

សម្រាប់គ្រួសារទាំងពីរ ដែលមានន័យថាពួកគេបានភ្ជាប់សាច់ឈាមនិងគ្នាហើយដោយសារពិធីកំជាប់ពាក្យនេះ។ ម្យ៉ាងវិញទៀត ការបង្កើតកំជាប់ពាក្យត្រូវកើតឡើងទៅតាមផ្លូវច្បាប់ដោយមានការព្រមព្រៀងពី ភាគីខាងកូនប្រុស និង ភាគីខាងកូនស្រី មុនពេលរៀបអាពាហ៍ពិពាហ៍ទៅតាមផ្លូវច្បាប់ បើយោងទៅតាមសម័យបុរាណ ការបង្កើតពិធីកំជាប់ពាក្យនេះ គេត្រូវធ្វើឡើងទៅតាមល័ក្ខខ័ណ្ឌមួយចំនួនដូចខាងក្រោម៖

**២.២.១.២. ការចែចូវ**

ជាទូទៅការចែចូវ គឺគេធ្វើឡើងនៅពេលដែលមាតាបិតាខាងកូនប្រុសបានមើលឃើញកូនស្រីរបស់នរណាម្នាក់ ឬ ពេញចិត្តនិងកូនស្រីនរណាម្នាក់ ដោយចង់បានធ្វើជាកូនប្រសារនោះគាត់នឹងពឹងពាក់អ្នកដែលមានមុខមាត់ មានគេគោរពច្រើនក្នុងភូមិ (អ្នកផ្លូវ) ដើម្បីចូលស៊ើបសួរពីមាតាបិតាខាងកូនស្រី ថាកូនរបស់គាត់នៅទំនេរ ឬ មួយក៏អត់។

ការចូលចែចូវនេះគេធ្វើឡើងបីលើកគឺ៖

- លើកទី១ អ្នកផ្លូវចូលទៅសួរសុខទុក្ខធម្មតាដោយគ្មានកាន់អ្វីនៅកំដរដៃទៅជាមួយទេ។
- លើកទី២ អ្នកផ្លូវចូលទៅដៃទទេដដែល តែចូលទៅម្តងនេះគឺដើម្បីស្ទង់មើលចិត្តថ្លើមមាតា បិតាខាងកូនស្រីប៉ុណ្ណោះ។
- លើកទី៣ នៅពេលដែលបានដឹងថាមានសង្ឃឹមហើយថាមាតាបិតាកូនស្រីយល់ព្រមហើយ នោះអ្នកផ្លូវត្រូវចូលទៅម្តងទៀត ដោយម្តងនេះត្រូវកាន់នូវរបស់ជាប់ដៃទៅជាមួយផងដែលរួមមាន បារី ម្លូរស្លា ដាក់ក្នុងជើងពានយកទៅជាមួយផង។

**២.២.១.៣. ការស្តីដណ្តឹង**

នៅពេលចូលស្តីដណ្តឹងមាតាបិតាខាងប្រុសត្រូវរកអ្នកមុខអ្នកការ មានអ្នកមហាបីនាក់ ឲ្យធ្វើជាអ្នកផ្លូវចូលទៅស្តីដណ្តឹង កូនស្រី ដោយមានរបស់កំដរដៃដូចជាការចូលចែចូវដែរ ដែលមាន ម្លូស្លា បារី ស្លាធ្មា កំបោរ កាន់មកជាប់ជាមួយផង។ ចំពោះការស្តីដណ្តឹងក៏មាន ៣ដំណាក់កាលដូចគ្នាទៅនិងការចែចូវដែរ ប៉ុន្តែសម្រាប់ពេលបច្ចុប្បន្ននេះ គឺគេធ្វើតែមួយដំណាក់ទេជាការស្រេច។ ចំពោះដំណាក់កាលនៅសម័យបុរាណនៃការស្តីដណ្តឹងរួមមាន៖

- លើកទី១ អ្នកផ្លូវត្រូវជម្រាបទៅមេបាជាពាក្យយ៉ាងនេះថាៈ សូមទាន សូមជម្រាបអស់លោកមេបារតូចធំត្រកូលរៀមច្បម សូមទានជ្រាប ដ្បិតអីលោកមេបាខាងកូនប្រុសបានពឹងពរកយើងខ្ញុំទាំងបី(៣)នាក់ ឲ្យធ្វើជាអ្នកនាំផ្លូវ នាំភ័ស្តុភារបណ្ណាការមកជូនលោកមេបា សុំស្គាល់ សុំស្រឡាញ់ជាសម្ព័ន្ធមិត្តនិងលោកមេបាឈ្មោះនាង......ថាទំនេរឥតមានទាក់ទាមសម្តីនិងអ្នកណាទេ ឬ ដូចម្តេច?

- ពេលនោះមេបាខាងស្រីនិងឆ្លើយតបមកវិញថាឲ្យ ឬ មិនឲ្យ។[62]
- លើកទី២ អ្នកផ្លូវ ចូលទៅដូចមុន ហើយនិយាយថាៈ ....ដ្បិតជើងមុន យើងខ្ញុំសុំឲ្យលោកមេបាដោះពាក្យដែលជំពាក់នោះ ឥឡូវនេះលោកបានដោះរួចហើយ ឬ នៅ?
- មេបាឆ្លើយតបទៅនិងអ្វីដែលបានសន្យាពីមុននោះ។[63]
- លើកទី៣ អ្នកផ្លូវសុំស្ដីដណ្ដឹងម្ដងទៀត តែមេបាតូច (មេបាស្រី) ឆ្លើយតបថាស្រេចលើមេបាធំ (មេបា)។[64]

ប៉ុន្តែសម្រាប់ពេលបច្ចុប្បន្ននេះពិធីមួយចំនួនក៏ត្រូវបានកាត់ចោលផងដែរ ដោយសារតែចំណាយពេលវេលាយូរ ចំណែកឯការចំណាយថវិការក៏ច្រើន។ ចំពោះពិធីចូលថៅ និង ស្ដីដណ្ដឹងក៏ត្រូវបានកាត់ចេញនៅពិធីមួយចំនួនផងដែរ ដែលពេលបច្ចុប្បន្ននេះការចូលថៅគឺមានតែមួយប៉ុណ្ណោះ ហើយយកជាការតែម្ដង។ ចំពោះការស្ដីដណ្ដឹងវិញក៏ដូចគ្នាដែរ ឲ្យតែកូនប្រុសស្រីបានព្រមព្រៀងគ្នាហើយមានការយល់ព្រមពីឪពុកម្ដាយសងខាងនោះគឺអាចប្រារព្ធពិធីបានដូចគ្នា ដែលភាគច្រើនគេធ្វើតែមួយលើកជាការស្រេច។ម្យ៉ាងវិញទៀត វាចំណេញពេល និងថវិការសំរាប់គ្រួសារទាំងពីរផងដែរ។

**២.២.១.៤. សេចក្ដីសន្យា**

សេចក្ដីសន្យា គឺសំដៅលើភាគីទាំងពីរដែលជាបុរស នារី បានបង្ហាញឆន្ទៈនៃការព្រមព្រៀងថាយកគ្នាជាប្ដីប្រពន្ធ ស្របតាមផ្លូវច្បាប់។ ម្យ៉ាងវិញទៀត សេចក្ដីសន្យានេះនឹងឈានទៅរកការរៀបការអាពាហ៍ពិពាហ៍នាពេលអនាគតផងដែរ។ បើយោងតាមមាត្រា៩៤៤ នៃក្រមរដ្ឋវេណីឆ្នាំ ២០០៧ បានចែងផងដែរថា (កំជាប់ពាក្យ ត្រូវបង្កើតឡើង តាមសេចក្ដីសន្យារវាងបុរសនារី ថានឹងរៀបការអាពាហ៍ពិពាហ៍រវាងគ្នា នាពេលអនាគត និងដោយធ្វើពិធីកំជាប់ពាក្យ)។[65]

ដូចនេះ សេចក្ដីសន្យា គឺជាការព្រមព្រៀងរវាងបុរសនារី ថានឹងរៀបអាពាហ៍ពិពាហ៍រវាងគ្នានៅពេលអនាគតដោយឆ្លងកាត់នូវពិធីកំជាប់ពាក្យ។

**២.២.១.៥. ពិធីកំជាប់ពាក្យ**

ពិធីកំជាប់ពាក្យ ឬ ការលើកស្លា ឬ ការនិយាយភាសាដែលប្រជាជនខ្មែរធ្លាប់ហៅជាប្រចាំថ្ងៃថា (ការភ្ជាប់ពាក្យ)។ ពិធីកំជាប់ពាក្យ ជាប្រពៃណីដែលប្រជាជនខ្មែរមានតាំងពីបុរាណមកហើយ ហើយក៏ជាពិធីធំមួយមុននឹងឈានទៅដល់ការរៀបអាពាហ៍ពិពាហ៍។ នៅសព្វថ្ងៃនេះ ពិធីនៅតែមានការនិយមជាទូទៅ មុននិងកូនបុត្រ

[62] រៀបរៀងដោយលោក ងឹម ហួរ និង ផ្សេងទៀត, អរិយធម៌ខ្មែរ (ភ្នំពេញ ២០១៤), ១៩៧។

[63] រៀបរៀងដោយលោក ងឹម ហួរ និង ផ្សេងទៀត, អរិយធម៌ខ្មែរ (ភ្នំពេញ ២០១៤), ២០០។

[64] រៀបរៀងដោយលោក ងឹម ហួរ និង ផ្សេងទៀត, អរិយធម៌ខ្មែរ (ភ្នំពេញ ២០១៤), ២០១។

[65] មាត្រា ៩៤៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

ធីតារបស់ពួកគេឈានដល់ថ្ងៃរៀបអាពាហ៍ពិពាហ៍ ហើយនៅក្នុងគ្រួសារដែលមានជីវភាពធូធារ បានរៀបចំពិធីនេះយ៉ាងអធិអធមធំប៉ុនគ្នា និងពិធីរៀបអាពាហ៍ពិពាហ៍ដែរ ប៉ុន្តែសម្រាប់គ្រួសារដែលមានជីវភាពមធ្យម បានរៀបចំតូចល្មមទៅតាមធនធាន ហើយសម្រាប់អ្នកខ្លះដែលមានជីវភាពមិនធូរធារ មិនបានប្រារព្ធពិធីនេះក៏មានដែរ។ ពិធីនេះ គេច្រើនធ្វើមួយព្រឹក ឬ ពេញមួយថ្ងៃតែម្តង ហើយមានការពាក់ចិញ្ចៀន ឬ ខ្សែករ ឬ ក៏ប្រគល់វត្ថុអនុស្សាវរីយ៍ផ្សេងៗដល់អនាគតស្វាមី ឬ ភរិយាទៀតផង តាមការនិយម និងតាមសមត្ថភាពធនធានដែលភាគីមាន។[66]

កំជាប់ពាក្យ សំដៅដល់ ពិធីតាមទំនៀមទម្លាប់ប្រពៃណីដែលច្បាប់ទទួលស្គាល់ ដែលតាមរយៈពិធីនេះ បុរស និង នារី សន្យាថានិងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលអនាគត។

### ២.២.២. លក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍

#### ២.២.២.១. គោលការណ៍ស្ម័គ្រចិត្ត

អាពាហ៍ពិពាហ៍គឺជាកិច្ចសន្យា ដ៏ឱឡារិកមួយធ្វើឡើងដោយបុរសម្នាក់និងស្ត្រីម្នាក់ ដែលប្តេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបទបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានទៅតាមទំនើងចិត្តរបស់ខ្លួន។ អាពាហ៍ពិពាហ៍ និងមានអានុភាពពេញលក្ខណៈច្បាប់បានលុះត្រាតែអាពាហ៍ពិពាហ៍នោះ ធ្វើឡើងស្រប តាមក្បួនខ្នាតដែល មានចែងក្នុងច្បាប់នេះ[67]។

បុរសនារី មានសិទ្ធិស្មើគ្នាគ្រប់វិស័យទាំងអស់ ពិសេសក្នុងអាពាហ៍ពិពាហ៍។ អាពាហ៍ពិពាហ៍ត្រូវធ្វើតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយ ប្រពន្ធមួយ។[68] ដូចនេះភាគីទាំង សងខាងត្រូវតែមានការស្ម័គ្រចិត្តក្នុងការរៀបអាពាហ៍ពិពាហ៍ ដែលមានគោលបំណងរួមរស់ជាមួយគ្នា ប្រសិនបើ ភាគីទាំងសងខាងពុំមានការព្រមព្រៀងនោះទេ ការរៀបអាពាហ៍ពិពាហ៍ពុំអាចធ្វើឡើងបានឡើយ។

ការអនុវត្តជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា ឈរលើគោលការណ៍ស្ម័គ្រចិត្ត ឬ មិនស្ម័គ្រចិត្ត ដែលពេលខ្លះពិបាកកំណត់ណាស់ ដោយសារតែប្រទេសកម្ពុជាមានប្រពៃណីទំនៀមទំលាប់ច្រើន។ ហេតុដូចនេះហើយ ទើបកូនៗ (ពិសេសកូនស្រី) ត្រូវស្តាប់តាមបង្គាប់ឪពុកម្តាយ ជីដូនជីតាក្នុងរឿងអាពាហ៍ពិពាហ៍ដែលមានពាក្យ ស្លោកមួយពោលថា (នំមិនធំជាងនាឡិ)។ មានន័យថា កាលណានៅពេលកូនៗ ឈានដល់វ័យរៀបអាពាហ៍ពិពាហ៍ គឺទុកឲ្យឪពុកម្តាយ ជាអ្នកសម្រេចចិត្តជំនួសសាមីខ្លួន។ ប៉ុន្តែសព្វថ្ងៃ កូនចៅប្រុសស្រី មានសិទ្ធិសេរីភាពជាងមុន ក្នុងការ ជ្រើសរើសគូស្រករ ដោយសារតែមានការរីកចម្រើននៃសិទ្ធិសេរីភាព ការសិក្សាអប់រំ និងទទួលវប្បធម៌ខ្លះៗពី បរទេស។

[66] នីតិគ្រួសារ និងអាពាហ៍ពិពាហ៍។

[67] មាត្រា ៣ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ក្រឹត្យច្បាប់លេខ ៥៦ក្រ.ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩។

[68] មាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

**២.២.២.២. ភេទរបស់គូភាគី**

ការរៀបអាពាហ៍ពិពាហ៍ គឺត្រូវធ្វើឡើងរវាងបុរស និង នារី។[69] ចំពោះអាពាហ៍ពិពាហ៍ដែលធ្វើឡើងដោយភេទដូចគ្នា អាពាហ៍ពិពាហ៍នោះពុំត្រូវបានច្បាប់ទទួលស្គាល់ឡើយ។ ច្បាប់ប្រទេសកម្ពុជាមិនទទួលស្គាល់ការរៀបអាពាហ៍ពិពាហ៍ដែលមានភេទដូចគ្នានោះទេ ពុំដូចជាបណ្តាលប្រទេសមួយចំនួននៅលើសកលលោក ដែលទទួលស្គាល់ឲ្យអ្នកដែលមានភេទដូចគ្នារួមរស់ជាមួយគ្នា និងអាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាដោយស្រប ច្បាប់បានឡើយ។

ករណីជាក់ស្តែងមួយចំនួន នៅក្នុងប្រទេសកម្ពុជាទៅតាមបណ្តាញព័ត៌មាន និងបណ្តាញសង្គម មានការចុះផ្សាយអំពីមនុស្សដែលមានភេទដូចគ្នា រួមរស់ជាមួយគ្នា ទោះបីជាច្បាប់មិនទទួលស្គាល់ក៏ដោយ ពោលគឺពួកគេរស់នៅជាមួយគ្នាតាមរបៀបអនីតិសង្វាសដែលមិនស្របជាមួយនិងល័ក្ខខ័ណ្ឌច្បាប់។

**២.២.២.៣. ល័ក្ខខ័ណ្ឌអាយុសម្រាប់រៀបអាពាហ៍ពិពាហ៍**

បុរសនារី ដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ លុះត្រាតែភាគីទាំងសងខាងគ្រប់អាយុ ១៨ឆ្នាំ ទើបមានសិទ្ធិរៀបអាពាហ៍ពិពាហ៍ស្របច្បាប់។ ប៉ុន្តែក្នុងករណីដែលភាគីម្ខាង បានដល់នីតិភាពហើយភាគីម្ខាងទៀតជាអនីតិជនដែលមានអាយុយ៉ាងតិចចាប់ពី១៦ឆ្នាំ ក៏អាចរៀបអាពាហ៍ពិពាហ៍បាន ដោយទទួលការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់អនីតិជននោះជាមុនសិន។[70]

ដោយផ្អែកលើក្រមរដ្ឋប្បវេណីសង្គមចាស់ បានកំណត់ថា បុរសមានអាយុមិនដល់១៧ឆ្នាំ រីឯនារីមានអាយុមិនដល់១៤ឆ្នាំ មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ។[71] ចំណែកឯច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩ បានកំណត់ថា បុរសត្រូវមានអាយុចាប់ពី២០ឆ្នាំឡើង រីឯនារីត្រូវមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ទើបអាចរៀបអាពាហ៍ពិពាហ៍បាន។

ទោះបីជាយ៉ាងណាក៏ដោយ ជនប្រុសស្រីទាំងអស់ដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ទើបអាចរៀបអាពាហ៍ពិពាហ៍បាន ដោយការសម្រេចចិត្តរបស់ខ្លួន និងមិនចាំបាច់មានការយល់ព្រមពីឪពុកម្តាយ ឬ អាណាព្យាបាលឡើយ ពោលគឺក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានផ្តល់សិទ្ធិពេញលេញដល់ពលរដ្ឋខ្មែរក្នុងការសម្រេចចិត្តជ្រើសរើសដៃគូរ ដើម្បីរៀបអាពាហ៍ពិពាហ៍។[72]

[69] មាត្រា ២ នៃច្បាប់ស្តីពីឯកពន្ធភាព ព្រះរាជក្រមលេខ នស/រកម/១០០៦/០២៦. ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៦។

[70] មាត្រា ៩៤៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[71] មាត្រា ១១៦ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ១៩២០។

[72] មាត្រា ៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, ក្រឹត្យច្បាប់លេខ ៥៦ក្រ.ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩។

### ២.២.២.៤. ការហាមឃាត់មិនឲ្យមានទ្វេពន្ធភាព

គោលការណ៍ ប្តីមួយ ប្រពន្ធមួយ ជាគោលការណ៍ ដែលត្រូវធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

បុរសនារីដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ លុះត្រាតែភាគីទាំងសងខាងនៅលីវ។ បើបុរសនារីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ តែបុរសនារីធ្លាប់មានសហព័ទ្ធរួចហើយក៏អាចរៀបអាចរៀបអាពាហ៍ពិពាហ៍ថ្មីបានដែរ គ្រាន់តែបុរសនារីត្រូវកាត់ផ្តាច់នៅចំណងអាពាហ៍ពិពាហ៍ចាស់តាមផ្លូវតុលាការឲ្យបានដាច់ស្រេច។ ព្រោះច្បាប់នៃព្រះរាជាណាចក្រកម្ពុជា បានហាមឃាត់មិនឲ្យមានទ្វេរពន្ធភាពទេ យោងតាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មាត្រា ៩៤៩ (ការហាមឃាត់មិនឲ្យមានទ្វេរពន្ធភាព) បានកំណត់ថា បុគ្គលដែលមានសហព័ទ្ធហើយពុំអាចរៀបអាពាហ៍ពិពាហ៍ទៀតបានឡើយ។[73] លើសពីនេះទៀត បើបុគ្គលណាមិនគោរពតាមបទបញ្ញត្តិមាត្រា ៩៤៩ នៃក្រមរដ្ឋប្បវេណីនេះទេ បុគ្គលនោះអាចប្រឈម និងការមានទោសទណ្ឌ និងពិន័យជាប្រាក់ ដែលស្របតាមច្បាប់ស្តីពីឯកព័ន្ធភាពផងដែរ។

### ២.២.២.៥. អំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត

នារីដែលធ្លាប់បានរៀបអាពាហ៍ពិពាហ៍រួចហើយ តែអាពាហ៍ពិពាហ៍នោះត្រូវបានបញ្ចប់ដោយការលែងលះ។ នារីក៏អាចរៀបអាពាហ៍ពិពាហ៍ថ្មីបានដែរ ដោយគ្រាន់តែនារីរង់ចាំរយៈពេល ១២០ថ្ងៃ ដោយគិតចាប់ពីរថ្ងៃដែរអាពាហ៍ពិពាហ៍ចាស់ ត្រូវបានរំលាយ ឬ លុបចោល។ ដោយយោងតាមមាត្រា ៩៥០ នៃក្រមរដ្ឋប្បវេណី បានកំណត់ថា នារីពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានឡើយ ប្រសិនបើអំឡុងពេល ១២០ថ្ងៃ ពុំទាន់បានកន្លងផុត គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុន ត្រូវបានរំលាយ ឬ លុបចោល។[74]អំឡុងពេលដែលហាមឃាត់នារីមិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មី ជាអំឡុងពេលដែលច្បាប់កម្រិតសម្រាប់នារី ដើម្បីជៀសវាងបញ្ហាជែងគ្នាក្នុងការកំណត់បិតុភាព (ឪពុករបស់កូន)។

ចំពោះករណីដែល នារី មានផ្ទៃពោះ និងបានសម្រាលមុនពេលចំណងអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬ លុបចោល ឬ ក្នុងករណី មានការបញ្ជាក់ថា នារីគ្មានផ្ទៃពោះ នារីអាចរៀបអាពាហ៍ពិពាហ៍ថ្មីបានដោយមិនចាំបាច់គោរពនូវអំឡុងពេលហាមឃាត់ទេ។[75]

---

[73] មាត្រា ៩៤៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[74] មាត្រា ៩៥០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[75] មាត្រា ៩៥០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

### ២.២.២.៦. ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិ

#### ក. ការហាមឃាត់រៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិត

អាពាហ៍ពិពាហ៍ ត្រូវបានហាមឃាត់រវាងញាតិលោហិត (ខ្សែផ្ទាល់ ឬ សាខាញាតិលោហិតក្នុង៣ថ្នាក់ រាប់ទាំងថ្នាក់ទី៣)។[76] ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិត ដោយសារ កត្តាជីវសាស្ត្រ និង កត្តាសង្គម និងសីលធម៌។

ការហាមឃាត់រៀបអាពាហ៍ពិពាហ៍ រវាងបុគ្គលដែលមានទំនាក់ទំនងញាតិ ត្រូវអនុវត្តដូចគ្នាផងដែរចំពោះអតីតញាតិក្រោយពេលបង្កើតសុំកូនពេញលេញ និងសុំកូនធម្មតា[77] មានន័យថា ក្នុងករណីសុំកូនពេញលេញ និងសុំកូនធម្មតា ត្រូវបានបង្កើតឡើងទំនាក់ទំនងញាតិ (ញាតិលោហិតខ្សែផ្ទាល់ និងសាខាញាតិ) រវាងឪពុកម្ដាយ និងកូនបង្កើត ត្រូវបានបញ្ចប់។ បុគ្គលដែលជាកូនសុំ ក្រោយបញ្ចប់ទំនាក់ទំនងសុំកូនតាមរយៈការកាត់កាល់ សុំកូនពេញលេញ និងសុំកូនធម្មតា មិនអាចរៀបអាពាហ៍ពិពាហ៍ ជាមួយនឹងបុគ្គលដែលធ្លាប់ជាញាតិលោហិត ឬ សាខាញាតិលោហិតក្នុង៣ថ្នាក់ របស់ឪពុកម្ដាយចិញ្ចឹមខ្លួនបានទេ។

#### ខ. ការហាមឃាត់រៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ

អាពាហ៍ពិពាហ៍ ត្រូវបានហាមឃាត់ផងដែររវាងញាតិពន្ធខ្សែផ្ទាល់[78] មានន័យថា សហព័ទ្ធម្ខាងទៀត មិនអាចទៅរៀបការជាមួយនឹងញាតិពន្ធនៃខ្សែផ្ទាល់របស់ខ្លួនបានទេ។ ការកម្រិតនេះ ត្រូវអនុវត្តដូចគ្នាផងអតីតញាតិពន្ធនៃខ្សែផ្ទាល់ ដូចជា ករណីក្រោយលែងលះ អតីត សហព័ទ្ធ និងឪពុកម្ដាយក្មេក មិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានទេ។ ម្យ៉ាងវិញទៀត ក្នុងករណីការបញ្ចប់នូវញាតិភាពរវាង ឪពុកម្ដាយចិញ្ចឹម និងកូនសុំ តាមរយៈការកាត់កាល់ កូនសុំ និងអតីតញាតិពន្ធរបស់ខ្លួន ក៏ត្រូវបានហាមឃាត់ការរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាដែរ។[79]

---

[76] មាត្រា ៩៥១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[77] មាត្រា ៩៥១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[78] មាត្រា ៩៥២ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[79] មាត្រា ៩៥២ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

ទោះបីជា មានការកម្រិតហាមឃាត់អាពាហ៍ពិពាហ៍រវាងអតីតញាតិពន្ធក៏ដោយ ប៉ុន្តែក្នុងករណី សហព័ទ្ធម្ខាងទទួលមរណភាព សហព័ទ្ធដែលនៅរស់អាចរៀបអាពាហ៍ពិពាហ៍ជាមួយអតីតសាខាញាតិពន្ធក្នុង៣ថ្នាក់បាន។[80] ការអនុញ្ញាតនេះ ក្នុងគោលបំណងងាយស្រួលថែទាំកូន ហើយក៏មិនប៉ះពាល់ដលសីលធម៌ ពីព្រោះការរលាយនូវចំណងអាពាហ៍ពិពាហ៍ដោយមូលហេតុមរណភាព មិនមែនលែងលះ។

**គ. ការហាមឃាត់រៀបអាពាហ៍ពិពាហ៍រវាងញាតិតាមរយៈការសុំកូន**

អាពាហ៍ពិពាហ៍ត្រូវបានហាមឃាត់ផងដែរ ចំពោះញាតិភាពដែលបង្កើតឡើងតាមរយៈការសុំកូនធម្មតា និងសុំកូនពេញលេញ ព្រោះពីថាកូនសុំ និងកូនបង្កើតក៏ជាញាតិនិងគ្នា។ ក្នុងករណីសុំកូនពេញលេញ និងសុំកូនធម្មតា ត្រូវបានបង្កើតឡើងទំនាក់ទំនងញាតិ (ញាតិលោហិតខ្សែផ្ទាល់ និងសាខាញាតិ) រវាងឪពុកម្តាយ និងកូនបង្កើត ត្រូវបានបញ្ចប់។[81] មួយវិញទៀតកូនសុំ ក្រោយបញ្ចប់ទំនាក់ទំនងសុំកូនតាមរយៈការកាត់កាល់ សុំកូនពេញលេញ និងសុំកូនធម្មតា មិនអាចរៀបអាពាហ៍ពិពាហ៍ ជាមួយនឹងបុគ្គលដែលធ្លាប់ជាញាតិលោហិត ឬសាខាញាតិលោហិតក្នុង៣ថ្នាក់ របស់ឪពុកម្តាយចិញ្ចឹមខ្លួនបានទេ។

**២.២.២.៧. ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន**

ភាគីដែលជាអនីតិជនដែលមិនទាន់គ្រប់អាយុ១៨ឆ្នាំ ត្រូវតែមានអាយុយ៉ាងតិចចាប់១៦ឆ្នាំឡើងទៅ ទើបច្បាប់អនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍បាន ដោយមានល័ក្ខខ័ណ្ឌដូចខាងក្រោមៈ

**ក. អនីតិជន និងនីតិជន**

បុរស នារី មានបំណងរៀបអាពាហ៍ពិពាហ៍ តែភាគីម្ខាងមានអាយុមិនតិចជាង១៦ឆ្នាំ ហើយភាគីម្ខាង ទៀតមានអាយុ១៨ឆ្នាំឡើងទៅ ត្រូវតែមានការយល់ព្រមពីឪពុកម្តាយ ឬ អាណាព្យាបាលរបស់អនីតិជននោះ ទើបអាចរៀបអាពាហ៍ពិពាហ៍បាន។ [82]

**ខ. ជនដែលទទួលបានអត្តាធីនភាព**

អនីតិជនដែលទទួលបានអត្តាធីនភាព ត្រូវបានចាត់ទុកជានីតិជន។[83] ដូចនេះ អនីតិជនដែលទទួលបានអត្តាធីនភាព អាចរៀបអាពាហ៍ពិពាហ៍បានដោយពុំចាំបាច់មានការយល់ព្រមពី ឪពុកម្តាយ ឬ អាណាព្យាបាល។

[80] មាត្រា ៩៥២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[81] មាត្រា ៩៥២ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[82] មាត្រា ៩៤៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[83] មាត្រា ២២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

ក្នុងករណីដែល អាពាហ៍ពិពាហ៍នោះកើតឡើងរវាង អនីតិជនដែលទទួលបានអត្តាធីនភាព និង អនីតិជនចាំបាច់ត្រូវមានការយល់ព្រមពីឪពុកម្តាយរបស់អនីតិជននោះទើបអាចរៀបអាពាហ៍ពិពាហ៍បាន។ ប្រសិនបើអាពាហ៍ពិពាហ៍នោះកើតឡើងរវាង អនីតិជនដែលទទួលបានអត្តាធីនភាព និងអនីតិជនដែលទទួលបានអត្តាធីនភាពដូចគ្នា ពួកគេអាចរៀបអាពាហ៍ពិពាហ៍បានដោយពុំចាំបាច់មានការយល់ព្រមពីឪពុកម្តាយឡើយ។

| ករណី | អាយុរបស់ភាគី | | ការយល់ព្រមពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាល |
|---|---|---|---|
| | អាយុភាគីម្ខាង | អាយុភាគីម្ខាងទៀត | |
| ១ | នីតិជន | នីតិជន | មិនចាំបាច់យល់ព្រម |
| ២ | នីតិជន | អនីតិជន (អាយុចាប់ពី១៦ដល់ក្រោម១៨ឆ្នាំឡើង) | ភាគីអនីតិជនចាំបាច់ត្រូវមានការយល់ព្រមជាមុនសិន |
| ៣ | ជនទទួលបានអត្តាធីនភាព (អាយុចាប់ពី១៦ឆ្នាំដល់ក្រោម១៨ឆ្នាំ) | នីតិជន | មិនចាំបាច់មានការយល់ព្រម |
| ៤ | ជនទទួលបានអត្តាធីនភាព (អាយុចាប់ពី១៦ឆ្នាំដល់ក្រោម១៨ឆ្នាំ) | អនីតិជន (អាយុចាប់ពី១៦ដល់ក្រោម១៨ឆ្នាំឡើង) | ភាគីដែលជាអនីតិជនចាំបាច់ត្រូវតែមានការយល់ព្រម |
| ៥ | ជនទទួលបានអត្តាធីនភាព (អាយុចាប់ពី១៦ឆ្នាំដល់ក្រោម១៨ឆ្នាំ) | ជនទទួលបានអត្តាធីនភាព (អាយុចាប់ពី១៦ឆ្នាំដល់ក្រោម១៨ឆ្នាំ) | មិនចាំបាច់មានការយល់ព្រម |

**គ.ជននៅក្រោមអាណាព្យាបាលទូទៅ**

ជននៅក្រោមអាណាព្យាបាលទូទៅ ឬ ជនវិកលចរិតដែលជានីតិជន អាចរៀបអាពាហ៍ពិពាហ៍បាន ក្នុងករណីដែលមានសមត្ថភាពបង្ហាញឆន្ទៈក្នុងកម្រិតអប្បបរមា ដែលចាំបាច់ដើម្បីរៀបអាពាហ៍ពិពាហ៍ ហើយការដែលជននៅក្រោមអាណាព្យាបាលទូទៅ ឬ ជនវិកលចរិត ចង់រៀបអាពាហ៍ពិពាហ៍ អាចសម្រេចចិត្តដោយខ្លួន

ឯងបាន និងអាចប្រព្រឹត្តទៅបាន ដោយមិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅដែលគ្រប់គ្រងជនវិកលចរិតនោះទេ។[84]

**២.២.២.៨. ឧបសគ្គក្នុងការរៀបអាពាហ៍ពិពាហ៍**

កាលណានៅពេលដែល សហព័ទ្ធណាម្នាក់ អវត្តមាន ឬ បាត់ខ្លួន ហើយសហព័ទ្ធម្ខាងទៀតនៅរស់ដោយមានភាពលំបាកក្នុងការគ្រប់គ្រងគ្រួសារ កូននៅក្នុងបន្ទុក ជាពិសេសការសម្រេចចិត្តដើម្បីរៀបអាពាហ៍ពិពាហ៍ថ្មីទៀត។ អវត្តមាន សំដៅដល់បុគ្គលណាម្នាក់ដែលបានចេញពីលំនៅដ្ឋាន ឬ ទីសំណាក់ដែលគ្មានលទ្ធភាពនិងត្រឡប់មកវិញដោយងាយស្រួល។

ការបាត់ខ្លួន សំដៅដល់ករណីដែលបុគ្គលណាម្នាក់ពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាព ដូចជាករណីដែលបុគ្គលដែលចូលទៅក្នុងតំបន់ដែលមានសង្គ្រាម បុគ្គលដែលមានវត្តមានក្នុងនាវាលិចទឹក ឬ បុគ្គលដែលបានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងៗទៀតដូចជា ការរញ្ជួយដី អគ្គិភ័យ ស៊ូណាមី ការរអិលផ្ទាំងទឹកកកពីភ្នំជាដើម ដែលអាចនាំឲ្យទទួលមរណភាព ហើយពុំមានដំណឹងច្បាស់លាស់ថាអ្នក អវត្តមាននៅរស់ ឬ ទទួលមរណភាព។

ក្នុងករណីដែលសហព័ទ្ធរបស់អ្នកដែលអវត្តមាននោះ មានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយប្ដី ឬ ប្រពន្ធថ្មីមិនមានសិទ្ធិដើម្បីនិងរៀបអាពាហ៍ពិពាហ៍ថ្មីឡើយ ពីព្រោះអ្នកដែលអវត្តមាន អាចមានលទ្ធភាពនឹងវិលត្រឡប់មកវិញ។ ប៉ុន្តែក្នុងករណីដែលបុគ្គលអវត្តមាន មានរយៈពេលយូរ គេអាចប្រកាសអំពីការបាត់ខ្លួន ឬ ក្នុងករណី ដែលបុគ្គលបានជួបនឹងឧបទ្ទវហេតុដែលគេគ្មានសង្ឃឹមថា នឹងមានជីវិតមកវិញ ហើយសហព័ទ្ធម្ខាងទៀតអាចរៀបអាពាហ៍ពិពាហ៍បាន លុះត្រាតែមានល័ក្ខខ័ណ្ឌដូចជា៖

**ក. ការបាត់ខ្លួនលើសពី៥ឆ្នាំ**

ក្នុងករណីដែលអវត្តមានរបស់សហព័ទ្ធណាម្នាក់ ដែលមានរយៈពេលលើសពី៥ឆ្នាំឡើងទៅ ហើយពុំមានដំណឹង ច្បាស់លាស់ថា អ្នកដែលអវត្តមាននោះនៅរស់ ឬ ទទួលមរណភាពទេ សហព័ទ្ធដែលនៅរស់ ឬ ឪពុកម្ដាយ ឬ អាណាព្យាបាល ឬ អ្នកដែលមានផលប្រយោជន៍ផ្សេងទៀត អាចស្នើសុំទៅតុលាការដើម្បីប្រកាសអំពីការ បាត់ខ្លួនរបស់អ្នកដែលអវត្តមានយូរនោះបាន ហើយសហព័ទ្ធដែលនៅរស់អាចរៀបអាពាហ៍ពិពាហ៍ជាមួយប្រពន្ធ ឬ ប្ដីថ្មីទៀតបាន ក្រោយពេលដែលតុលាការប្រកាសសាលក្រមអំពីការបាត់ខ្លួនជននោះ។

[84] មាត្រា ៩៥៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

**ខ. ការបាត់ខ្លួនលើសពី១ឆ្នាំ ដោយឧបទ្ទវហេតុ**

ក្នុងករណី ដែលអវត្តមានរបស់សហព័ទ្ធណាម្នាក់ជួបនឹងឧបទ្ទវហេតុដូចជា ចូលទៅក្នុងតំបន់ដែលមានសង្គ្រាម បុគ្គលដែលមានវត្តមានក្នុងនាវាលិចទឹក ឬ បុគ្គលដែលបានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងៗទៀត ដូចជា ការរញ្ជួយដី អគ្គិភ័យ ស៊ូណាមិ ការរអិលផ្ទាំងទឹកកកពីភ្នំជាដើម ដែលអាចនាំឲ្យទទួលមរណភាព ហើយពុំមាន ដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាព ដែលមានរយៈពេលលើស១ឆ្នាំឡើងទៅក្រោយពីថ្ងៃជួបឧបទ្ទវហេតុនោះ តុលាការអាចប្រកាសអំពីការបាត់ខ្លួនរបស់បុគ្គលនោះ តាមពាក្យសុំរបស់ សហព័ទ្ធដែលនៅរស់ ឬ ឪពុកម្ដាយ ឬ អាណាព្យាបាល ឬ អ្នកដែលមានផលប្រយោជន៍ផ្សេងទៀត ហើយសហព័ទ្ធដែលនៅ រស់អាចរៀបអាពាហ៍ពិពាហ៍ជាមួយប្ដី ឬ ប្រពន្ធថ្មីបាន ក្រោយពេលដែលតុលាការប្រកាសសាលក្រមអំពីការបាត់ខ្លួន។[85]

### ២.២.៣. នីតិវិធីនៃការបង្កើតចំណងអាពាហ៍ពិពាហ៍

#### ២.២.៣.១. នីតិវិធីរៀបអាពាហ៍ពិពាហ៍រវាងជនជាតិខ្មែរ និង ជនជាតិខ្មែរ

ការរៀបអាពាហ៍ពិពាហ៍គឺ ជាចំណងគតិយុត្តមួយរវាងបុរស និង ស្ត្រី ដើម្បីក្លាយជាប្ដីប្រពន្ធ ស្របច្បាប់។ ដើម្បីឲ្យការរៀបអាពាហ៍ពិពាហ៍នោះអាចប្រព្រឹត្តទៅបាន គឺគេត្រូវធ្វើវាទៅតាមនីតិវិធីដែល ច្បាប់បានកំណត់។ លើសពីនេះទៅទៀតនោះ ដើម្បីឲ្យអាពាហ៍ពិពាហ៍នោះមានលក្ខណៈស្របទៅ តាមបទដ្ឋានគតិយុត្តនៃច្បាប់ និង ដើម្បីធានាថាការរៀបអាពាហ៍ពិពាហ៍នេះមិនមានការប៉ះផលប្រយោជន៍អ្នកដទៃ។

ដូចនេះ ការរៀបអាពាហ៍ពិពាហ៍ គឺចាំបាច់ត្រូវតែធ្វើទៅតាមនីតិវិធីដែលមានដូចតទៅៈ

**ក. ការដាក់ពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍**

មុននឹងរៀបអាពាហ៍ពិពាហ៍ "បុរសនារីដែលមានបំណងរៀបអាពាហ៍ពិពាហ៍នឹងគ្នា ត្រូវដាក់ពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬ សង្កាត់នៃគេហដ្ឋានសាមីខ្លួនខាងនារី"។ [86] ម្យ៉ាងវិញទៀតនោះ គឺភាគីត្រូវធ្វើលិខិតបញ្ជាក់ពីឃុំ ឬ សង្កាត់ ដែលជាលំនៅដ្ឋានរបស់ភាគីរៀងៗខ្លួន អំពីភាពនៅលីវ ឬ មេម៉ាយ ឬ ពោះម៉ាយ ដោយមិនមានការជាប់ជំពាក់ជាមួយបុគ្គលណាផ្សេងឡើយ។

ក្រោយពីទទួលបានលិខិតបញ្ជាក់នេះហើយ ដោយមានទាំងឪពុកម្ដាយនៅរស់ ឬ អាណាព្យាបាលរួមជាមួយផង ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍នៅខាងឃុំ ឬ សង្កាត់ខាងភាគីស្ត្រីរស់នៅ។ ក្រោយពីមេឃុំ ឬ ចៅសង្កាត់ទទួលពាក្យស្នើសុំនោះហើយ ក្នុងឋានៈលោកជាមន្ត្រីអត្រានុកូលដ្ឋាន ត្រូវចេញលិខិតអនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍ និង ចេញប័ណ្ណប្រកាសសម្រាប់រៀបអាពាហ៍ពិពាហ៍ឲ្យទៅភាគីទាំងពីរយកទៅបិទផ្សាយជា

[85] មាត្រា ៤១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ចុះព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[86] អនុក្រឹត្យ, លេខ ១០៣, អនុប្រកប (ស្ដីពីអត្រានុកូលដ្ឋាន)ថ្ងៃទី២៩ ធ្នូ២០០០ មាត្រា ២៨។

សាធារណៈ។ ម្យ៉ាងវិញទៀតច្បាប់នេះប្រទេសកម្ពុជាក៏បានកំណត់ផងដែរអំពីការដាក់ពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍នេះដែរថា "អាពាហ៍ពិពាហ៍មានអានុភាពដោយការដាក់ពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និង ការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន"។ [87]

មេឃុំ ឬ ចៅសង្កាត់ដែលបានចេញលិខិតបញ្ជាក់ពីភាពនៅលីវ ឬ មេម៉ាយ ឬ ពោះម៉ាយនេះ ត្រូវមានបិទរូបថតថ្មីទំហំ ៤ គុណ ៦ មួយសន្លឹកផង ហើយលិខិតនេះមានសុពលភាពត្រឹម៣ខែ ប៉ុណ្ណោះ។

### ខ. ការបិទប្រកាសលិខិតស្នើសុំរៀបអាពាហ៍ពិពាហ៍

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ដែលគ្រោងនឹងធ្វើនោះផ្សាយ ជាសាធារណៈនៅលំនៅដ្ឋាន និង នៅសាលាឃុំ ឬ សាលាសង្កាត់នៃសាមីខ្លួននារី ០១ច្បាប់។ ហើយប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ០២ច្បាប់ទៀត ត្រូវផ្ញើរជូនមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ខាងប្រុស ដើម្បីយកទៅបិទផ្សាយនៅលំនៅដ្ឋាន និង បិទនៅសាលាឃុំ ឬ សាលាសង្កាត់សាមីខ្លួនបុរស ០១ ច្បាប់។

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ត្រូវតែបិទផ្សាយក្នុងរយៈពេល ១០ថ្ងៃ មុនថ្ងៃរៀបអាពាហ៍ពិពាហ៍ដើម្បីឲ្យអ្នកមានផលប្រយោជន៍ក្នុងរឿងនេះ អាចប្ដឹងជំទាស់នឹងអាពាហ៍ពិពាហ៍នេះបាន។ ប្រសិនបើគ្មានអ្នកណាមកប្ដឹងជំទាស់អាពាហ៍ពិពាហ៍នោះទេ ផុតរយៈពេល១០ថ្ងៃអាពាហ៍ពិពាហ៍នេះអាចធ្វើទៅបាន។ ប៉ុន្តែប្រសិនបើមាននរណាម្នាក់ ដែលមានផលប្រយោជន៍ក្នុងអាពាហ៍ពិពាហ៍បានប្ដឹងទាស់ទៅនឹងអាពាហ៍ពិពាហ៍នោះអាពាហ៍ពិពាហ៍អាចត្រូវរលាយ ឬ ក៏ពន្យាពេល រៀបអាពាហ៍ពិពាហ៍សិនដើម្បីរងចាំការស៊ើបអង្កេតអំពីករណីនេះ។ [88]

### គ. ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍[89]

ក្រោយពេលរៀបអាពាហ៍ពិពាហ៍ហើយ ដំណាក់កាលចុងក្រោយក្នុងការបង្កើតឲ្យមានអាពាហ៍ពិពាហ៍ស្របច្បាប់មួយ ដែលទទួលស្គាល់ដោយច្បាប់ គឺការចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅរបស់នារី។ នីតិវិធីបែបនេះអ្នកខ្លះហៅថា "ការចុះអេតាស៊ីវិល"។ មិនមានល័ក្ខខ័ណ្ឌតម្រូវពិសេសណាមួយទេ ដើម្បីរៀបចំពិធីនោះ។ អនុក្រឹត្យលេខ១០៣អនក្រ.បក ស្ដីពីអត្រានុកូលដ្ឋានបានចែងថា «អនាគតប្ដីប្រពន្ធ រួមទាំងសាក្សី២នាក់ដែលមានអាយុឈានដល់នីតិភាព ត្រូវចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន១រូប» ហើយមន្ត្រីអត្រានុកូលដ្ឋានត្រូវចុះកិច្ចសន្យានោះ ក្នុងសៀវភៅអាពាហ៍ពិពាហ៍របស់

---

[87] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៥៥អនុក្រឹត្យ, លេខ ១០៣ អនប្រកប (ស្ដីពីអត្រានុកូលដ្ឋាន) ថ្ងៃទី២៩ ធ្នូ ២០០០ មាត្រា ២៨។

[88] អនុក្រឹត្យ, លេខ ១០៣ អនប្រកប (ស្ដីពីអត្រានុកូលដ្ឋាន) ថ្ងៃទី២៩ ធ្នូ ២០០០, មាត្រា ២៩។

[89] អនុក្រឹត្យ, លេខ ១០៣ អនប្រកប (ស្ដីពីអត្រានុកូលដ្ឋាន) ថ្ងៃទី២៩ ធ្នូ ២០០០, មាត្រា ៣០។

ឃុំសង្កាត់ ហើយភាគីទាំងពីរត្រូវផ្តិតមេដៃ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះហត្ថលេខា និងបោះត្រាលើសៀវភៅនោះផងដែរ។

ទោះជាយ៉ាងណា អនាគតប្តី ឬ ពន្ធត្រូវបញ្ជាក់ប្រាប់មន្ត្រីអត្រានុកូលដ្ឋានថា អាពាហ៍ពិពាហ៍របស់គេធ្វើឡើងដោយស្ម័គ្រចិត្ត។ ពិធីខាងសាសនាពុំមានលក្ខណៈចាំបាច់ដែលតម្រូវឲ្យធ្វើដូចជាបណ្តាប្រជាជនដែលកាន់សាសនាគ្រិស្តនោះឡើយ ហើយដែលពិធីខាងសាសនា ត្រូវបានគេរៀបចំធ្វើក្នុងពិធីរៀបអាពាហ៍ពិពាហ៍រួចហើយ។ ការនេះពុំមែនមានន័យថា ពិធីទាំងខាងសាសនានោះគ្មានសារៈសំខាន់ត្រូវបានគេបំភ្លេចចោល ឬ មើលរំលងនោះទេ ការពិតវាមានសារៈសំខាន់យ៉ាងខ្លាំង ហើយដែលគេបានរៀបចំក្នុងពិធីរៀបអាពាហ៍ពិពាហ៍រួចហើយ។

### ឃ. ការចុះសំបុត្រអាពាហ៍ពិពាហ៍

ការចុះសំបុត្រអាពាហ៍ពិពាហ៍ គឺជាការភ្ជាប់ចំណងគតិយុត្តរវាងប្តីប្រពន្ធឲ្យមានលក្ខណៈ ស្របទៅនិងច្បាប់។ យោងតាមច្បាប់កំណត់ គឺតម្រូវឲ្យប្តីប្រពន្ធចាំបាច់ត្រូវតែចុះសំបុត្រអាពាហ៍ពិពាហ៍ ពីព្រោះថាប្រសិនប្តីប្រពន្ធមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ គឺគេចាត់ទុកថាជាការរស់នៅជាមួយគ្នាបែបជាអនីតិសង្វាស។ ការស់នៅបែបនេះ បើតាមផ្លូវច្បាប់មិនទទួលស្គាល់ថាជា ប្តីប្រពន្ធស្របច្បាប់ឡើយ ហើយប្រសិនបើមានវិវាទកើតឡើងនោះក៏វាពិបាកនៅក្នុងការដោះស្រាយដែរ ពីព្រោះថាពុំមានភស្តុតាងបញ្ជាក់ថាអ្នកទាំងពីរជាប្តីប្រពន្ធនិងគ្នា។លើសពីនេះទៅទៀត "អាពាហ៍ពិពាហ៍នឹងមានអានុភាពលុះត្រាបានចុះសំបុត្រអាពាហ៍ពិពាហ៍ ដែលការចុះសំបុត្រ នេះត្រូវទៅចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងស្រី ដោយមានសាក្សីចំនួនពីរនាក់ដែលមានអាយុគ្រប់តាមច្បាប់កំណត់"។ [90]

### ង. ការចេញសំបុត្រអាពាហ៍ពិពាហ៍[91]

នៅក្រោយពេលសាមីខ្លួន អនាគតប្តីនិងប្រពន្ធបានមកតាយការណ៍សុំចុះសៀវភៅអាពាហ៍ពិពាហ៍ហើយមន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅអាពាហ៍ពិពាហ៍ បន្ទាប់មកត្រូវប្រគល់ឲ្យសាមីខ្លួនប្តីប្រពន្ធនូវសំបុត្រមួយហៅថា «សំបុត្រអាពាហ៍ពិពាហ៍» ជាច្បាប់ដើមមួយច្បាប់ និង «សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍» មួយចំនួនទៀតតាមការស្នើសុំរបស់ភាគី។

នៅក្នុង «សំបុត្រអាពាហ៍ពិពាហ៍» មានចុះឈ្មោះរបស់សហព័ន្ធ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត ថ្ងៃខែឆ្នាំចុះសំបុត្រអាពាហ៍ពិពាហ៍ និងទីកន្លែងចុះសំបុត្រអាពាហ៍ពិពាហ៍ជាដើម។ សំបុត្រអាពាហ៍ពិពាហ៍នេះមានសារៈ

[90] អនុក្រឹត្យ, លេខ ១០៣ អនប្រកប (អត្រានុកូលដ្ឋាន) ថ្ងៃទី២៩ ធ្នូ ២០០០ មាត្រា ៣០។

[91] អនុក្រឹត្យ, លេខ ១០៣ អនប្រកប (អត្រានុកូលដ្ឋាន) ថ្ងៃទី២៩ ធ្នូ ២០០០ មាត្រា ៣១។

សំខាន់ខ្លាំង ដើម្បីបញ្ជាក់ធម្មានុរូប (ភាពស្របច្បាប់)រូបនៃប្ដីប្រពន្ធដែលកើតចេញពីអាពាហ៍ពិពាហ៍ដែលត្រឹមត្រូវតាមច្បាប់។

ដូចនេះនៅ ពេលរៀបអាពាហ៍ពិពាហ៍ប្ដីប្រពន្ធត្រូវតែមកចុះសំបុត្រអាពាហ៍ពិពាហ៍ដើម្បីឲ្យ អាពាហ៍ពិពាហ៍នោះមានអានុភាព។

**២.២.៣.២. នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងជនជាតិខ្មែរ និង ជនបរទេស**

ការរៀបអាពាហ៍ពិពាហ៍រវាងជនជាតិខ្មែរជាមួយជនបរទេសគឺជារឿងដែលល្អមួយ ចំពោះគូរស្រករនីមួយៗ ប៉ុន្តែត្រូវតែគោរពទៅលើច្បាប់ជាតិ បើសិនជាការរៀបអាពាហ៍ពិពាហ៍នោះលើទឹកដីកម្ពុជា។[92]ប៉ុន្តែបើពលរដ្ឋខ្មែររៀបអាពាហ៍ពិពាហ៍នៅបរទេស ក៏ត្រូវតែមានការអនុញ្ញាតឲ្យប្រើច្បាប់ខ្មែរផងដែរ ព្រោះជាប្រយោជន៍ទូទៅចំពោះការរៀបចំលិខិតស្នាមផ្សេងៗដើម្បីបញ្ជាក់អំពី អត្តសញ្ញាណរបស់គាត់ថាជាពលរដ្ឋខ្មែរ។ លើសពីនេះទៅទៀតគឺជនបរទេសដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ ចាំបាច់ត្រូវមានវត្តមាននៅក្នុងព្រះរាជាចក្រកម្ពុជាដើម្បីបំពេញបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍។ [93]

ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និង ជនបរទេស ឬ ជនអន្តោប្រវេសន៍ ដែលរស់នៅស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ត្រូវប្រព្រឹត្តទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ [94]

ដើម្បីរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ សាមីខ្លួនជនបរទេសត្រូវបំពេញបែបបទទៅ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈក្រសួងមហាផ្ទៃ។ ម្យ៉ាងវិញទៀតសាមីខ្លួនជនបរទេសនោះក៏ត្រូវភ្ជាប់នូវសំណុំឯកសារមួយចំនួនដែលមាន ដូចខាងក្រោមនេះ៖

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍
- ឯកសារថតចម្លងនៃលិខិតឆ្លងដែនរបស់សាមីខ្លួនជនបរទេស មានទិដ្ឋាការចូលប្រទេសកម្ពុជាដែលមានសុពលភាព
- លិខិតបញ្ជាក់ពីភាពនៅលីវ ឬ ពោះម៉ាយ ឬ មេម៉ាយចេញដោយសមត្ថកិច្ចនៃប្រទេសរបស់ សាមីខ្លួនជនបរទេស លិខិតបញ្ជាក់សុខភាពចេញដោយសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា
- លិខិតបញ្ជាក់អំពីមុខរបរពិតប្រាកដ និង ធានាជីវិភាពរស់នៅរបស់សាមីខ្លួនជនបរទេស។ លិខិតទាំងនោះចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស។ ឯកសារថតចម្លងនលិខិតឆ្លងដែន និង

[92] អនុក្រឹត្យ, លេខ ១០៣ អនប្រកប (ស្ដីពីអត្រានុកូលដ្ឋាន) ថ្ងៃទី២៩ ធ្នូ ២០០០, មាត្រា ៣៤។

[93] អនុក្រឹត្យស្ដីពីការកំណត់បែបបទ និង នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និង ជនបរទេស, លេខ១៨៣មាត្រា ៥។

[94] អនុក្រឹត្យ, លេខ ១០៣ អនប្រកប (ស្ដីពីអត្រានុកូលដ្ឋាន) ថ្ងៃទី២៩ ធ្នូ ២០០០, មាត្រា ៣៣។

លិខិតបញ្ជាក់នីត្យានុកូលភាពពីស្ថានទូត ឬ ស្ថាប័នតំណាងនៃប្រទេស របស់សាមីខ្លួនជនបរទេសប្រចាំព្រះរាជាណាចក្រកម្ពុជា។ [95]

### ក. ការដាក់ពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍

ចំពោះការដាក់ពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេស និង ជនជាតិខ្មែរ គឺអាចធ្វើទៅបាន តែត្រូវបំពេញទៅតាមល័ក្ខខ័ណ្ឌគតិយុត្តនៃច្បាប់បានកំណត់។ សាមីខ្លួនជាជនបរទេស និង សាមីខ្លួនជាជនជាតិខ្មែរ ត្រូវធ្វើលិខិតស្នើសុំទៅក្រសួងការបរទេសតាម រយៈក្រសួងមហាផ្ទៃ ដោយផ្ទាល់ ដែលមានអ្នកធានាទៅជាមួយផងដែរនៅក្រសួងមហាផ្ទៃ។ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជាមានភារកិច្ចពិនិត្យ និង ផ្តល់យោបល់លើសំណុំឯកសាររបស់ជនបរទេសដែលសុំរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ និងជូនដំណឹងទៅសាមីខ្លួនវិញ ក្នុងរយៈពេលយ៉ាងយូរ ៥ថ្ងៃ(ដែលជាថ្ងៃធ្វើការ)។ ក្រោយពីពិនិត្យ និង ផ្តល់យោបល់លើសំណុំឯកសាររបស់ជនបរទេសហើយ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ត្រូវបញ្ជូនសំណុំ ឯកសារទាំងអស់នោះទៅក្រសួងមហាផ្ទៃ និង ជូនព័ត៌មានទៅស្ថាប័នពាក់ព័ន្ធ។ [96]

ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍នៅទីនេះក៏ដូចគ្នា ទៅនឹងការរៀបអាពាហ៍ពិពាហ៍របស់ ជនជាតិខ្មែរ និង ជនជាតិខ្មែរដែរ ព្រោះថាការធ្វើបែបនេះ គឺដើម្បីបញ្ជាក់ថាបុរស ឬ ស្រ្តីនោះនៅលីវ មិនមានជាប់ចំណងអាពាហ៍ពិពាហ៍ជាមួយបុគ្គលណាមួយឡើយ។ ប្រសិនបើ បុរស ឬ នារីនោះ បានរៀបអាពាហ៍ពិពាហ៍ពីមុនរួចហើយនោះ ក៏អាចបង្កើតចំណងអាពាហ៍ពិពាហ៍ថ្មីបានដែរឲ្យតែចំណងអាពាហ៍ពិពាហ៍ចាស់នោះបានបញ្ចប់។

ម្យ៉ាងវិញទៀត គឺដើម្បីបង្ហាញពីការយល់ព្រមរបស់ឪពុកម្តាយ ឬ អ្នកអាណាព្យាបាលរបស់ អ្នកទាំងពីរនាក់នោះ (កូនកំលោះ និង កូនក្រមុំ) ក្នុងការសម្រេចឲ្យរៀបអាពាហ៍ពិពាហ៍ ដោយដាក់លិខិតស្នើសុំនោះទៅខាងឃុំ-សង្កាត់ ខាងស្រីដើម្បីឲ្យឃុំ-សង្កាត់នោះចេញលិខិតបញ្ជាក់ពីភាពនៅលីវ ដោយមានភ្ជាប់មកជាមួយនឹងរូបថត ៤ គុណ ៦ មកផង ហើយលិខិតនោះមានសុពលភាពត្រឹម តែបីខែប៉ុណ្ណោះ។

### ខ. ការបិទប្រកាសលិខិតស្នើសុំរៀបអាពាហ៍ពិពាហ៍

ចំពោះការបិទប្រកាសលិខិតស្នើសុំរៀបអាពាហ៍ពិពាហ៍នេះក៏មិនខុសគ្នាទៅនឹង ការរៀបអាពាហ៍ពិពាហ៍រវាងជនជាតិខ្មែរ និង ជនជាតិខ្មែរដែរ គឺប័ណ្ណប្រកាសរៀបអាពាហ៍ពិពាហ៍ត្រូវតែបិទផ្សាយក្នុងរយៈពេល ១០ថ្ងៃនៅលំនៅឋានខាងស្រី និងនៅសាលាឃុំ សង្កាត់ខាងស្រី។ ចំណែកឯជនជាតិបរទេសវិញ ការបិទប្រកាសលិខិតស្នើសុំរៀបអាពាហ៍ពិពាហ៍មិនត្រូវបានធ្វើឡើងឡើយ គឺ គេបិទតែនៅផ្ទះខាងស្រី ឬ ខាងប្រុសប៉ុណ្ណោះ ដើម្បីឲ្យ

[95] អនុក្រឹត្យស្តីពីការកំណត់បែបបទ និង នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និង ជនបរទេស, លេខ១៨៣, មាត្រា ៦។

[96] អនុក្រឹត្យស្តីពីការកំណត់បែបបទ និង នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និង ជនបរទេស, លេខ១៨៣, មាត្រា ៧។

គេដឹងលឺជាសាធារណៈ ឬ ដើម្បីឲ្យអ្នកមាន ផលប្រយោជន៍ក្នុងអាពាហ៍ពិពាហ៍អាចប្តឹងជំទាស់និង អាពាហ៍ពិពាហ៍នេះបាន ។

**គ. ការចុះសំបុត្រអាពាហ៍ពិពាហ៍រវាង ជនជាតិខ្មែរ និង ជនជាតិបរទេស**

អាពាហ៍ពិពាហ៍នឹងមានអានុភាពពេញលក្ខណៈច្បាប់បានលុះត្រាតែសាមីខ្លួនបុរស និងនារី ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍តាមរយៈការចុះបញ្ជីអាពាហ៍ពិពាហ៍ដោយសាមីខ្លួនផ្ទាល់ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ ដែលសាមីខ្លួនទាំងពីរបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ដោយនាំមកជាមួយនូវសាក្សីជានីតិជនចំនួន ០២រូបផង ស្របទៅតាមទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន ។ [97]

ចំពោះអាពាហ៍ពិពាហ៍របស់ជនជាតិខ្មែរ និង ជនជាតិបរទេសក៏មិនខុសគ្នាដែរ ព្រោះថានៅក្នុងច្បាប់ខ្មែរក៏បានកំណត់ផងដែរថា ប្រសិនបើជនបរទេសណាដែលចង់រៀបអាពាហ៍ពិពាហ៍ជាមួយជនជាតិខ្មែរនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាត្រូវគោរពតាមច្បាប់កម្ពុជា។ ហេតុនេះ ការចុះសំបុត្រអាពាហ៍ពិពាហ៍ក៏ធ្វើឡើងដូចជាជនជាតិខ្មែរដែរគឺ ត្រូវចុះសំបុត្រអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៅគេហដ្ឋានជនជាតិខ្មែរ ដោយមានការចុះហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋាន និង ហត្ថលេខារបស់កូនកំលោះ និង កូនក្រមុំជាចាំបាច់។

**២.២.៤. អានុភាពនៃអាពាហ៍ពិពាហ៍**

**២.២.៤.១. ការប្រើប្រាស់នាមត្រកូលរបស់ប្តីប្រពន្ធ**

ផ្អែកទៅតាមគោលការណ៍ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីនៅពេលរៀបអាពាហ៍ពិពាហ៍ ប្តីប្រពន្ធ អាចប្រើប្រាស់នាមត្រកូលរបស់ប្តីប្រពន្ធ ឬអាចប្រើនាមត្រកូលដើមរៀងៗខ្លួនដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍បាន។[98] ជាក់ស្តែងក្នុងសង្គម ការប្រើប្រាស់នាមត្រកូលប្តីប្រពន្ធ គេសង្កេតឃើញថាភាគច្រើន មានតែភាគីប្រពន្ធតែប៉ុណ្ណោះ ដែលយកនាមត្រកូលប្តីមកប្រើ ជាពិសេសអ្នកដែលមានឋានន្តរសក្តិខ្ពង់ខ្ពស់ ( សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដែលឈ្មោះភរិយារបស់លោកគឺ សម្តេចគតិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន) ។

**២.២.៤.២. ករណីយកិច្ចរបស់សហព័ទ្ធ**

ប្តីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការ សង្គ្រោះគ្នាទៅវិញទៅមក។[99] ក្រោយពេលរៀបអាពាហ៍ពិពាហ៍ សហព័ទ្ធទាំងពីរមានករណីយកិច្ចរួមរស់សហការគ្នា ជួយរំលែកទុក្ខធុរៈទៅវិញទៅមក និងចូលរួមដោះស្រាយបញ្ហាទាំងអស់គ្នា។

---

[97] អនុក្រឹត្យស្តីពីការកំណត់បែបបទ និង នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និង ជនបរទេស, លេខ១៨៣, មាត្រា១១។

[98] មាត្រា ៩៦៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[99] មាត្រា ៩៦៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

**២.២.៤.៣. សេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ និងសិទ្ធិចូលរួមសកម្មភាពសង្គម**

ទោះបីជាអាពាហ៍ពិពាហ៍ ជាចំណងចងភ្ជាប់កាតព្វកិច្ចជាមួយគ្នារវាង ប្តីប្រពន្ធ និងជាចំណងចងភ្ជាប់គ្នាគ្រប់សកម្មភាពរវាងគ្នា នឹងគ្នាទៅវិញទៅមកដោយ ក៏ក្រមរដ្ឋប្បវេណីបានផ្តល់សេរីភាពដល់ប្តីប្រពន្ធក្នុងការជ្រើសរើសវិជ្ជាជីវៈ ហើយមានសេរីភាពក្នុងការចូលរួមក្នុងសកម្មភាពនយោបាយ វប្បធម៌ សាសនា សង្គមរៀងៗខ្លួន។[100] ប្រពន្ធមានសេរីភាពធ្វើការងារអ្វីដែលខ្លួនពេញចិត្ត ហើយប្តីក៏មានសេរីភាពធ្វើការងារអ្វីដែលខ្លួនពេញចិត្តដូចគ្នាផងដែរ។ សហព័ទ្ធម្ខាងមិនអាចបង្ខំឲ្យសហព័ទ្ធម្ខាងទៀតឈប់ប្រកបមុខរបរ ឬ ការងាររបស់គេបាន នោះទេ លើសពីនេះទៅទៀតសហព័ទ្ធទាំងពីរ មានសិទ្ធិសេរីភាពក្នុងការចូលរួមសកម្មភាពនយោបាយរៀងៗខ្លួន ដោយគ្មានសហព័ទ្ធណាអាចបង្ខំឲ្យប្តីប្រពន្ធរបស់ខ្លួនចូលរួមសកម្មភាពនយោបាយរបស់ខ្លួនបាននោះទេ មានន័យថាសហព័ទ្ធទាំងពីរស្រឡាញ់គណបក្សនយោបាយខុសគ្នាបាន។ ប្តីប្រពន្ធក៏មានសិទ្ធិសេរីភាពក្នុងការគោរពជំនឿ និងសាសនារៀងៗខ្លួនបានផងដែរ ។

**២.២.៤.៤. សិទ្ធិ និងករណីយកិច្ចរបស់អ្នកមានអំណាចមេបា**

ឪពុកម្តាយ មានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឲ្យទៅជាពលរដ្ឋល្អ។ កូនមានករណីយកិច្ចចិញ្ចឹម និងបីបាច់ថែរក្សាមាតាបិតាដែលចាស់ជរា។[101] ឪពុកម្តាយដែលបានបង្កើតកូនហើយ មិនអាចបោះបង់កូន ឬ ទុកកូនចោល ឬ បង្កើតកូនដើម្បីយកកូនធ្វើអាជីវកម្ម ឬ កេងប្រវ័ញ្ចលើកម្លាំងពលកម្មកូនបានទេ។ ប្រសិនបើឪពុកម្តាយធ្វើបែបនេះ ពួកគេនឹងត្រូវទទួលទោសតាមច្បាប់។

**២.២.៤.៥. ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ**

ក្រោយពេលដែលសហព័ទ្ធទាំងពីរបានក្លាយជាប្តីប្រពន្ធស្របច្បាប់ ពួកគេទាំងពីរអាចជ្រើសរើសប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់ពួកគេដូចមានចែងនៅក្នុងក្រមរដ្ឋប្បវេណី (ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា និងប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់កំណត់) ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិដែលពួកគេរកព្រមទាំងជៀសវាងជម្លោះដែលកើតឡើងដោយសារទ្រព្យ។

**ក. ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា**

ប្តីប្រពន្ធអាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬ ក្រោយពេលរៀបអាពាហ៍ពិពាហ៍បាន ប៉ុន្តែកិច្ចសន្យានេះមិនអាចផ្ទុយ និងបញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារកាតព្វកិច្ច និងភាគបម្រុងបានឡើយ។[102] ការ ចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺដើម្បីកំណត់នូវសិទ្ធិ និងកាតព្វកិច្ចលើទ្រព្យសម្បត្តិដែលប្តីប្រពន្ធ ដែល

[100] មាត្រា ៩៦៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[101] មាត្រា ៤៦ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[102] មាត្រា ៩៦៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

បាន កំណត់នៅមុន ឬ ក្រោយពេលរៀបអាពាហ៍ពិពាហ៍ និងដើម្បីបង្ការលក្ខណៈងាយស្រួលក្នុងការបែងចែកទ្រព្យសម្បត្តិនៅពេលមានការលែងលះគ្នា។ ការចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវធ្វើនៅក្រសួងយុត្តិធម៌។ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺត្រូវបានទាមទារឲ្យចុះបញ្ជី។ ប្រសិនបើមិនបានចុះបញ្ជីទេ ប្តីប្រពន្ធមិនអាច យកកិច្ចសន្យានោះមកតតាំងជាមួយនឹងតតិយជនបានឡើយ។[103]

ក្នុងករណីដែលប្តីប្រពន្ធមិនបានធ្វើកិច្ចសន្យាពិសេសចំពោះទ្រព្យសម្បត្តិនោះទេ ទ្រព្យសម្បត្តិរបស់ពួកគេនឹងត្រូវអនុលោមតាមប្រព័ន្ធទ្រព្យសម្បត្តិដែលច្បាប់កំណត់ ។[104]

**ខ. ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់**

ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ គឺជាប្រព័ន្ធទ្រព្យសម្បត្តិដែលច្បាប់តម្រូវឲ្យភាគីប្តីប្រពន្ធអនុវត្តប្រសិនបើពួកគេមិនបានជ្រើសរើសការអនុវត្តប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា។ ប្រព័ន្ធទ្រព្យសម្បត្តិដែលច្បាប់កំណត់ បានបែងចែកទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធជា២គឺ ទ្រព្យសម្បត្តិដោយឡែក និង ទ្រព្យសម្បត្តិរួម។

- ទ្រព្យសម្បត្តិដោយឡែក

ទ្រព្យសម្បត្តិដោយឡែក គឺជាទ្រព្យសម្បត្តិដែលសហព័ទ្ធមាន នៅមុនពេលរៀបអាពាហ៍ពិពាហ៍ទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ និងជាទ្រព្យសម្បត្តិជាតម្លៃតបដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដែលបានកំណត់ខាងលើ។[105]

សហព័ទ្ធទាំងពីរអាចប្រើប្រាស់ និង ចាត់ចែងទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនបានដោយសេរីដោយពុំចាំបាច់មានការយល់ព្រមពីភាគីម្ខាងទៀត។ សហព័ទ្ធនីមួយៗ មានសិទ្ធិប្រើប្រាស់ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនរៀងៗខ្លួនបាន។[106]

[103] មាត្រា ៩៧០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧។

[104] មាត្រា ៩៦៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[105] មាត្រា ៩៧២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ព្រះរាជក្រមលេខ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[106] មាត្រា៩៧៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ព្រះរាជក្រមលេខ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

❖ ទ្រព្យសម្បត្តិរួម

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិដែលប្តីប្រពន្ធទាំងសងខាង ឬ តែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។ ទ្រព្យសម្បត្តិរួម គឺចង់សំដៅទៅលើទ្រព្យសម្បត្តិទាំងឡាយណាដែលប្តីប្រពន្ធរកបានដូចជាប្រាក់ខែរបស់ប្តី ឬ ប្រពន្ធ និងចំណូលពីការរកស៊ីរបស់ប្តី ឬ ប្រពន្ធ ជាដើម។[107]

**២.២.៤.៦. ទំនាក់ទំនងសហព័ទ្ធ និងញាតិ**

ក្រោយពីការរៀបអាពាហ៍ពិពាហ៍ សហព័ទ្ធម្ខាងបានក្លាយទៅជាសមាជិករបស់គ្រួសារម្ខាងទៀត។ នេះក៏ជាគោលបំណងនៃអាពាហ៍ពិពាហ៍ផងដែរ ដែលចង់ពង្រីកសមាជិកគ្រួសារឲ្យកាន់តែធំ ទោះបីសហព័ទ្ធម្ខាងមិនមែនជាញាតិលោហិតរបស់សហព័ទ្ធម្ខាងទៀតក៏ដោយ ប៉ុន្តែសហព័ទ្ធនោះមានករណីយកិច្ច គោរពញាតិ និងគោរពសិទ្ធិរបស់សមាជិកក្នុងគ្រួសារនោះផងដែរ មិនតែប៉ុណ្ណោះត្រូវសង្គ្រោះគ្នាទៅវិញទៅមក។ ហើយសមាជិកម្នាក់ៗ ក្នុងគ្រួសារត្រូវបង្ការកុំឲ្យមានអំពើហិង្សាក្នុងគ្រួសារ និងត្រូវធ្វើយ៉ាងណាកុំឲ្យមានការកើតឡើង នូវការរំលោភសិទ្ធិមនុស្ស។[108]

## ២.៣. ញាតិពន្ធ

ញាតិពន្ធ គឺជាទំនាក់ទំនងញាតិភាពមួយបែបដែលកើតឡើងដោយសារចំណងនៃអាពាហ៍ពិពាហ៍ចំណងរបស់យើងជាមួយសហព័ទ្ធ( ដែលជាស្វាមី ឬ ភរិយា ) ដែលត្រូវជាញាតិខាងសហព័ទ្ធយើង។ ហើយបុគ្គលដែលជាញាតិពន្ធ គឺជាញាតិក្នុង ៣ ថ្នាក់ ដែលត្រូវបានបែងចែកជា ញាតិពន្ធខ្សែផ្ទាល់ (បុព្វញាតិពន្ធខ្សែផ្ទាល់ និងបច្ឆាញាតិពន្ធ ខ្សែផ្ទាល់) និងសាខាញាតិពន្ធ (បុព្វញាតិនៃសាខាញាតិពន្ធ និង បច្ឆាញាតិនៃសាខាញាតិពន្ធ) ដូចគ្នានឹងញាតិលោហិតដែរ[109]។

ញាតិពន្ធ គឺសំដៅទៅដល់ចំណងគតិយុត្តរវាងសហព័ទ្ធម្ខាង ជាមួយនិងញាតិលោហិតរបស់សហព័ទ្ធម្ខាងទៀត។ ញាតិពន្ធនេះអាចកើតឡើងបាន ដោយចំណងគតិយុត្តដោយស្របច្បាប់បានលុះត្រាតែចំណងអាពាហ៍ពិពាហ៍រវាងបុគ្គលម្នាក់និងសហព័ទ្ធម្ខាងនោះ បានកើតឡើងដោយស្របតាមចំណងច្បាប់ដែលបានកំណត់ឡើង មិនមែនកើតឡើងដោយសារតែចំណងអាពាហ៍ពិពាហ៍តាមបែបប្រពៃណីសាសនាតែប៉ុណ្ណោះនោះទេ។ ប្រសិនបើចំណងអាពាហ៍ពិពាហ៍ដែលកើតឡើងរវាងបុរសនិងនារីមួយគូ បានកើតឡើងដោយសារការរៀបអាពាហ៍ពិពាហ៍តាមបែបប្រពៃណីសាសនា ដែលមានការដឹងឮអំពីញាតិមិត្តសាច់លោហិតក៏ពិតមែន ប៉ុន្តែនៅ

[107] មាត្រា ៩៧៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[108] មាត្រា ៩៤៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[109] មាត្រា ៩៣៩ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

ក្នុងចំណងគតិយុត្តច្បាប់គឺបុរសនិងនារីមួយគូនោះបានរស់នៅជាមួយនិងគ្នាតាមបែបអនីតិសង្វាសគឺមានន័យថាបុរសនិងនារីនោះបានរួមរស់នៅជាមួយគ្នាដោយពិតប្រាកដមែនប៉ុន្តែចំណងគតិយុត្តិរវាងគ្នានឹងគ្នាគឺមិនមានឡើយ។

ហើយចំពោះញាតិពន្ធនេះ អាចមានចំណងគតិយុត្តតាមផ្លូវច្បាប់បាន លុះត្រាតែបុគ្គលម្នាក់និងសហព័ទ្ធម្នាក់ទៀតបានរៀបអាពាហ៍ពិពាហ៍ និងបានធ្វើតាមនីតិវិធីច្បាប់ដែលបានកំណត់ជាធរមានដោយមានការចុះសំបុត្រអាពាហ៍ពិពាហ៍នៅសាលាឃុំ ឬ សង្កាត់នៃខាងលំនៅដ្ឋានណាមួយរបស់គូស្វាមីភរិយានោះ ។

ហើយញាតិពន្ធនេះត្រូវបានបែងចែកជាពីរផងដែរគឺញាតិពន្ធនៃខ្សែផ្ទាល់ និងញាតិពន្ធនៃសាខាញាតិពន្ធ។ ចំពោះញាតិពន្ធនៃញាតិពន្ធខ្សែផ្ទាល់ គឺសំដៅទៅដល់បុព្វញាតិទាំងឡាយណារបស់សហព័ទ្ធរបស់ខ្លួន ដែលកើតឡើងដោយសារចំណងអាពាហ៍ពិពាហ៍ដោយស្របច្បាប់របស់ខ្លួន មានន័យថាគឺជាបុគ្គលដែលមានលំដាប់ថ្នាក់ដែលនៅខ្ពស់ជាងសហព័ទ្ធរបស់យើងដែលមានដូចជាឳពុកម្ដាយក្មេកជីដូនជីតាក្មេកជាដើម។ ឬ ញាតិពន្ធគឺជាបុគ្គលដែលកើតឡើងដោយសារចំណងអាពាហ៍ពិពាហ៍ដោយស្របច្បាប់ជាមួយបច្ឆាញាតិលោហិតខ្សែផ្ទាល់របស់យើង ដែលបុគ្គលនោះមានលំដាប់ថ្នាក់ស្មើរ និងបច្ឆាញាតិលោហិតខ្សែផ្ទាល់យើង ដូចជា កូនប្រសារ ចៅប្រសារជាដើម។

ចំណែកឯញាតិពន្ធនៃសាខាញាតិពន្ធវិញ គឺជាបុគ្គលដែលស្ថិតនៅលំដាប់ថ្នាក់ស្មើ ឬ មួយក៏ក្រោមថ្នាក់ញាតិពន្ធរបស់យើងដែលមានដូចជាបងប្អូនថ្លៃ ក្មួយថ្លៃជាដើម ។

ហើយការរំលត់នៃញាតិពន្ធនេះអាចកើតឡើងដោយសារការបញ្ចប់នូវទំនាក់ទំនងនៃនីតិសង្វាស់ គឺមានន័យថាការលែងលះ ឬ ទំនាក់ទំនងនេះត្រូវបានបញ្ចប់ដោយសារតែសហព័ទ្ធម្ខាងបានទទួលមរណភាព ហើយសហព័ទ្ធម្ខាងដែលបាននៅរស់បានរៀបអាពាហ៍ពិពាហ៍ថ្មីទៀតដែលបានបង្ហាញឆន្ទៈក្នុងការបញ្ចប់ទំនាក់ទំនងញាតិពន្ធ ។

## ២.៤. ញាតិតាមរយៈការបង្កើតស្មុំកូន

### ២.៤.១. ស្មុំកូនធម្មតា

ស្មុំកូនធម្មតា សំដៅដល់ការសុំកូនដែលកូននោះអាចជាអនីតិជន ឬ នីតិជនដោយមិនកាត់ផ្តាច់ញាតិភាពពីឳពុកម្ដាយបង្កើត ហើយការសុំនេះត្រូវសម្រេចដោយតុលាការ។

#### ២.៤.១.១. សញ្ញាណទូទៅនៃស្មុំកូនធម្មតា

ស្មុំកូនធម្មតា អាចហៅម្យ៉ាងទៀតបានថា ស្មុំកូនសាមញ្ញគឺទម្រង់មួយដែលបានសម្រួល ពីសុំកូនពេញលេញ។ របបដែលដាក់កូនសុំទៅក្នុងការគ្រប់គ្រង ទាំងស្រុងរបស់គ្រួសារឳពុកម្តាយចិញ្ចឹម ហើយមិនមានការកាត់ផ្តាច់នូវចំណងទំនាក់ទំនងរវាងកូនសុំ និង ឳពុកម្តាយបង្កើត។ ប្រព័ន្ធស្មុំកូនធម្មតានេះត្រូវបានបង្កើតឡើង

ដោយតម្រូវឲ្យមានការពាក់ព័ន្ធពីតុលាការ ដើម្បីបង្កើតអានុភាព ញាតិលោហិតតាមផ្លូវច្បាប់ដូចជា សន្តតិកម្ម និង អាហារកាតព្វកិច្ចជាដើម។

### ២.៤.១.២. លក្ខណៈពិសេសនៃសុំកូនធម្មតា

សុំកូនធម្មតា មិនមានលក្ខណៈតឹងរឹងដូចសុំកូនពេញលេញនោះទេ។ ញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយបង្កើតត្រូវបន្តអត្ថិភាពរហូត ហើយកូនសុំ និង ឪពុកម្ដាយបង្កើតមានសិទ្ធិធ្វើសន្តតិកម្មឲ្យគ្នា ទៅវិញទៅមកបាន។ កូនសុំ និង ឪពុកម្ដាយបង្កើតក៏មានសិទ្ធិទាមទារ និង មានករណីកិច្ចត្រូវ ផ្គត់ផ្គង់អាហារកាតព្វកិច្ចផងដែរ។ លើសពីនេះ កូនសុំត្រូវទទួលបាននូវឋានៈដូចគ្នានឹងកូនបង្កើត របស់ឪពុកម្ដាយចិញ្ចឹម និង ត្រូវទទួលបាននូវសិទ្ធិ និងករណីកិច្ចដូចគ្នានឹងកូនបង្កើត នៅក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្ដាយចិញ្ចឹម។

### ២.៤.១.៣. ល័ក្ខខ័ណ្ឌនៃការបង្កើតសុំកូនធម្មតា

មានល័ក្ខខ័ណ្ឌជាច្រើនសម្រាប់ការបង្កើតសុំកូនធម្មតា ហើយល័ក្ខខ័ណ្ឌទាំងនោះមានដូចជា អាយុរបស់ឪពុកម្ដាយចិញ្ចឹម និង កូនសុំការចូលរួមរបស់សហព័ទ្ធម្ខាងរបស់បុគ្គលដែលនឹងក្លាយជា ឪពុក ឬ ម្ដាយចិញ្ចឹម ក្នុងករណីបុគ្គលនោះមានសហព័ទ្ធ និង កូនសុំជាអនីតិជន ការចូលរួមរបស់ ឪពុកម្ដាយបង្កើតក្នុងករណីកូនសុំជាអនីតិជន និងមូលដ្ឋានដែលតុលាការនិងពិចារណា។

#### ក. អាយុរបស់ឪពុកម្ដាយចិញ្ចឹម

បុគ្គលដែលមានអាយុចាប់ពី ២៥ឆ្នាំឡើងទៅ[110] អាចបង្កើតសុំកូនធម្មតាបាន ប៉ុន្តែសុំកូនធម្មតាមិនអាចបង្កើតបានឡើយក្នុងករណីបុគ្គលដែលនឹងក្លាយជាកូនចិញ្ចឹម មានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម។ ម្យ៉ាងវិញទៀត ការបង្កើតសុំកូនធម្មតាមិនហាមឃាត់ចំពោះបុគ្គលដែលជាញាតិនឹងគ្នានោះទេ ប៉ុន្តែសុំកូនមិនអាចបង្កើតបានឡើយ ក្នុងករណីបុគ្គលដែលនឹងក្លាយជាកូនសុំជាបុព្វញាតិរបស់បុគ្គល ដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម។ តាមការបកស្រាយក្នុងក្រមរដ្ឋប្បវេណី អាយុ២៥ឆ្នាំឡើងទៅ ត្រូវគិតចាប់ពីពេលដាក់ពាក្យសុំ ហេតុនេះករណីអ្នកដាក់ពាក្យសុំមានអាយុ ២៤ឆ្នាំ នៅពេលដាក់ពាក្យសុំទៅតុលាការមិនអាចបង្កើតសុំកូនធម្មតាបានទេ។

---

[110] មាត្រា ១០២០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

### ខ. អាយុរបស់កូនសុំ

អាយុរបស់កូនសុំធម្មតាពុំត្រូវបានកម្រិត ហេតុនេះកូនសុំអាចជាអនីតិជន ឬ នីតិជន ហើយមានអាយុប៉ុន្មានក៏បានដែរ លើកលែងតែកូនសុំមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជា ឪពុកម្តាយចិញ្ចឹម ឬ កូនសុំនោះជាបុព្វជាតិរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម។[111]

### គ. ការចូលរួមរបស់សហព័ទ្ធ

ក្នុងករណីជនដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមមានសហព័ទ្ធសុំកូនធម្មតា អាចបង្កើតបានទោះបីជាបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមមាន ឬ គ្មានសហព័ទ្ធក៏ដោយ ប៉ុន្តែក្នុងករណីបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមមានសហព័ទ្ធ ដើម្បីបង្កើតសុំកូនធម្មតាបាន លុះត្រាតែមានការយល់ព្រមពីសហព័ទ្ធរបស់ខ្លួន ។[112] ប៉ុន្តែប្រសិន បើសហព័ទ្ធម្ខាងមិនបាន ដាក់ពាក្យជាមួយសហព័ទ្ធម្ខាងទៀត ឬ សហព័ទ្ធម្ខាងមិនអាចបង្ហាញឆន្ទៈយល់ព្រមបាន សុំកូនធម្មតាមិនអាចបង្កើតបានទេ។[113] ផ្ទុយទៅវិញ ក្នុងករណីកូនសុំជាអនីតិជន ហើយបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមមានសហព័ទ្ធ ការយល់ព្រមរបស់ភាគីម្ខាងមិនគ្រប់គ្រាន់ទេ ពោល គឺត្រូវដាក់ពាក្យសុំរួមគ្នា (សុំកូនដោយសហការ ) ទើបអាចបង្កើតសុំកូនធម្មតាបាន។[114] ប៉ុន្តែក្នុងករណីយកកូនរបស់សហព័ទ្ធមកធ្វើជាកូនសុំ ឬ សហព័ទ្ធម្ខាងទៀតមិនអាចបង្ហាញឆន្ទៈបាន សុំកូនអាចបង្កើតឡើងបានត្រឹមអ្នកដាក់ពាក្យសុំតែម្នាក់ឯងប៉ុណ្ណោះ។

គួរបញ្ជាក់ថា ការដាក់ពាក្យសុំរួមគ្នា និង ការដាក់ពាក្យសុំដោយមានការយល់ព្រមពីសហព័ទ្ធ មានភាពខុសគ្នាត្រង់ថា៖ ការដាក់ពាក្យសុំរួមគ្នា (ដូចមានចែងក្នុងមាត្រា១០២១) សហព័ទ្ធទាំងពីរនឹងក្លាយជាឪពុកម្តាយចិញ្ចឹម ប៉ុន្តែក្នុងករណីពាក្យសុំត្រូវបានដាក់ដោយសហព័ទ្ធម្ខាង ដោយមានការយល់ព្រមរបស់សហព័ទ្ធម្ខាងទៀត (ដូចមានចែងនៅក្នុងមាត្រា១០២២) អ្នកដែល ក្លាយជាឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម គឺសហព័ទ្ធម្ខាងដែលបានដាក់ពាក្យសុំ។

---

[111] មាត្រា ១០២០ កថាខ័ណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[112] មាត្រា ១០២២ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[113] មាត្រា ១០២២ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[114] មាត្រា ១០២១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

❖ ក្នុងករណីឪពុក ឬ ម្ដាយចិញ្ចឹមនៅលីវ

ស្នុំកូនធម្មតា អាចបង្កើតបានទោះបីជាបុគ្គលដែលនឹងក្លាយជាឪពុក ឬ ម្ដាយចិញ្ចឹមនោះ គ្មានសហព័ទ្ធ ឬ នៅលីវក៏ដោយ ដែលមានអាយុចាប់ពី២៥ (ម្ភៃប្រាំឆ្នាំ) ឡើងទៅ អាចដាក់ពាក្យជាមួយនឹងបុគ្គល ដែលនឹងក្លាយជាកូនសុំបាន។ ប៉ុន្តែបុគ្គលដែលនឹងក្លាយជាកូនសុំ មិនត្រូវជាបុព្វញាតិរបស់បុគ្គលដែល នឹងក្លាយជាឪពុកម្ដាយចិញ្ចឹម ឬ បុគ្គលដែលមានអាយុច្រើនជាងបុគ្គលនឹងក្លាយជាឪពុក ឬ ម្ដាយចិញ្ចឹមឡើយ។ ក្នុងករណីដែលបុគ្គលនឹងក្លាយជាកូនសុំជាអនីតិជន អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវដាក់ពាក្យសុំដែលបានកំណត់ខាងលើនេះ ក្នុងនាមជាអ្នកតំណាងដែលច្បាប់បានកំណត់ ។

តុលាការអាចឲ្យបង្កើតស្នុំកូនបាន លុះត្រាតែករណីដែលអាចបញ្ជាក់អំពីឆន្ទៈពិតប្រាកដរបស់សាមីខ្លួនក្នុងការបង្កើតទំនាក់ទំនង រវាងឪពុក ឬ ម្ដាយ និងកូនសុំ។ តុលាការមិនត្រូវឲ្យបង្កើតស្នុំកូនឡើយ បើយល់ឃើញថា ស្នុំកូនត្រូវបានបំពានក្នុងគោលបំណងរៀបអាពាហ៍ពិពាហ៍ រវាងភេទផ្សេងគ្នា ឬ ភេទដូចគ្នា ឬ ក្នុងគោលបំណងមិនត្រឹមត្រូវផ្សេងទៀត ។

### ឃ. ការចូលរួមរបស់ឪពុកម្ដាយបង្កើតរបស់កូនសុំ

ក្នុងករណីបុគ្គលដែលនឹងក្លាយជាកូនសុំជានីតិជន ការដាក់ពាក្យបង្កើតស្នុំកូនធ្វើឡើងត្រឹម តែបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម និង បុគ្គលដែលនឹងត្រូវក្លាយជាកូនសុំនោះមានភាពគ្រប់គ្រាន់ ដោយមិនពិចារណាអំពីឆន្ទៈរបស់ឪពុកម្ដាយបង្កើតឡើយ។ ម្យ៉ាងវិញទៀត ទោះបីជាកូនសុំ មានសហព័ទ្ធក៏ដោយ ស្នុំកូនត្រូវបានបង្កើតឡើងត្រឹមឆន្ទៈរបស់កូនសុំ ដោយមិនពិចារណាអំពីឆន្ទៈ របស់សហព័ទ្ធនៃកូនសុំឡើយ។

ក្នុងករណីកូនសុំជាអនីតិជន ស្នុំកូនអាចបង្កើតបានលុះត្រាតែមានការចូលរួមដាក់ពាក្យពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កូនសុំ ក្នុងនាមជាអ្នកមានអំណាចមេបា។[115] បើកូនសុំជាអនីតិជនមានអាយុដល់ ១៥ឆ្នាំ ដើម្បីបង្កើតស្នុំកូនបាន លុះត្រាតែ មានការយល់ព្រមពីអនីតិជននោះ ហេតុនេះក្នុងករណីអនីតិជនមិនយល់ព្រម ស្នុំកូនមិនអាចបង្កើតឡើងបានទេ ។[116]

[115] មាត្រា ១០២០ កថាខ័ណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[116] មាត្រា ១០២៤ កថាខ័ណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

### ង. មូលដ្ឋានវិនិច្ឆ័យដែលតុលាការ និង ពិចារណា

តុលាការធ្វើការវិនិច្ឆ័យអំពីការបង្កើតសុំកូនធម្មតា ដោយផ្អែកលើមូលដ្ឋានដូចជា៖

- ទី១៖ តម្រូវឲ្យមានការបញ្ជាក់អំពីឆន្ទៈពិតប្រាកដរបស់ភាគី ក្នុងការបង្កើតទំនាក់ទំនងរវាងឪពុកម្តាយ និង កូន។
- ទី២៖ តុលាការមិនត្រូវឲ្យបង្កើតសុំកូនឡើយ បើយល់ឃើញថា សុំកូនត្រូវបានបំពានក្នុងគោលបំណង អាពាហ៍ពិពាហ៍ រវាងភេទផ្សេងគ្នា ឬ ដូចគ្នា ឬ ក្នុងគោលបំណងមិនត្រឹមត្រូវផ្សេងទៀត។[117]
- ទី៣៖ ក្នុងករណីកូនសុំជាអនីតិជន គឺតុលាការអាចឲ្យបង្កើតសុំកូនបានលុះត្រាតែយល់ឃើញថា មានភាព ចាំបាច់ពិសេស ដើម្បីផលប្រយោជន៍របស់កូនសុំដែលជាអនីតិជននោះ។[118]តុលាការ ត្រូវពិចារណាអំពីឆន្ទៈ របស់អនីតិជន កាលបើអនីតិជនមានអាយុដល់ ១៥ឆ្នាំ ហើយទោះបីជាពុំមានអាយុដល់ ១៥ឆ្នាំ ក៏ដោយ ក៏តុលាការអាចសួរយោបល់របស់អនីតិជនបានដែរ។ ម្យ៉ាងទៀត ក្នុងករណី ឪពុកម្តាយបង្កើតលែងលះ គ្នា មុននឹងសម្រេចបង្កើតសុំកូនធម្មតា តុលាការក៏ត្រូវសួរយោបល់ ឪពុក ឬ ម្តាយបង្កើតដែលមិនមែនជាអ្នក មានអំណាចមេបា។

### ២.៤.១.៤. អានុភាពនៃសុំកូនធម្មតា

### ក.បង្កើតញាតិភាពជាមួយឪពុកម្តាយចិញ្ចឹម ក្រោយបង្កើតសុំកូន

ញាតិភាពរវាងឪពុកម្តាយចិញ្ចឹម និង កូនសុំត្រូវបានបង្កើតឡើង កូនសុំមានឋានៈដូចគ្នានឹងកូនបង្កើត មាន សិទ្ធិធ្វើសន្តតិកម្មចំពោះគ្នាទៅវិញទៅមក និង កាតព្វកិច្ច ចំពោះគ្នាទៅវិញទៅមកផងដែរ ហើយកូនសុំអាចប្រើ ប្រាស់នាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬ នាមត្រកូលរបស់ខ្លួនមុនពេលបង្កើតសុំកូនបាន។[119] ក្នុងករណី កូនសុំជាអនីតិជនកូនសុំត្រូវស្ថិតក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម ប៉ុន្តែក្នុងករណីយកកូនបង្កើត របស់ សហព័ទ្ធមកធ្វើជាកូនសុំ កូនសុំនោះត្រូវស្ថិតក្រោមអំណាចមេបារួមរបស់ឪពុក ឬ ម្តាយចិញ្ចឹម និង សហព័ទ្ធ នោះ។[120]

---

[117] មាត្រា ១០២៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[118] មាត្រា ១០២៤ កថាខ័ណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[119] មាត្រា ១០២៧ កថាខ័ណ្ឌទី១ និងទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[120] មាត្រា ១០២៧ កថាខ័ណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

កូនសុំ មានន័យថា គឺយកតែកូនប៉ុណ្ណោះហេតុនេះញាតិរបស់កូនមិនត្រូវបានមកជាមួយទេ។

ឧទាហរណ៍៖ លោក x ជាកូនសុំ ហើយមានប្រពន្ធ y និង កូនម្នាក់ z ក្នុងករណីនេះ មានតែ x ទេ ដែលជាញាតិរបស់ឳពុកម្តាយចិញ្ចឹម រីឯប្រពន្ធ និង កូនរបស់ x មិនមែនជាញាតិជាមួយ ឳពុក ម្តាយចិញ្ចឹមទេ ប៉ុន្តែក្រោយបង្កើតសុំកូន លោក x មានកូនម្នាក់ទៀត ក្នុងករណីនេះ កូនទី២ របស់x គឺជាញាតិជាមួយឳពុកម្តាយចិញ្ចឹម។

**ខ.ការបន្តញាតិភាពជាមួយឳពុកម្តាយបង្កើត**

ទោះបីជាសុំកូនត្រូវបានបង្កើតឡើងក៏ដោយ ញាតិភាពរវាងឳពុកម្តាយបង្កើត និង កូនសុំ នៅតែបន្ត ហេតុនេះកូនសុំ និង ឳពុកម្តាយបង្កើត មានសិទ្ធិធ្វើសន្តតិកម្មឲ្យគ្នាទៅវិញទៅមក ហើយមាន ក៏មានសិទ្ធិទាមទារ និងករណីកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមកដែរ។[121]

ជាទូទៅសុំកូនធម្មតា កូនសុំនោះមានឳពុកម្តាយបង្កើតផង និង ឳពុកម្តាយចិញ្ចឹមផង ហេតុនេះសិទ្ធិក្នុងការធ្វើសន្តតិកម្ម ក៏មានចំពោះគ្នាទៅវិញទៅមកដែរ មានន័យថា មានទាំងទំនាក់ទំនងជាមួយឳពុកម្តាយចិញ្ចឹម និង ឳពុកម្តាយបង្កើត ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក្នុងករណីកូនសុំជាអនីតិជន អ្នកដែលមានអំណាចមេបាលើកូនសុំ គឺឳពុកម្តាយចិញ្ចឹម។

## ២.៤.២. សុំកូនពេញលេញ

### ២.៤.២.១. និយមន័យ

សុំកូនពេញលេញ គឺសំដៅដល់ការសុំអនីតិជនដែលមានអាយុក្រោម៨ឆ្នាំយកមកធ្វើជាកូនសុំ ដោយមានការបង្កើតទំនាក់ទំនងឳពុកម្តាយនឹងកូនជាមួយឳពុកម្តាយចិញ្ចឹម និងបញ្ចប់ញាតិភាពនៃលោហិត រួមទាំងសិទ្ធិ និងកាតព្វកិច្ចរវាងកុមារ និងឳពុកម្តាយ ឬ អាណាព្យាបាលកុមារ ហើការការសុំនេះត្រូវធ្វើតាមសេចក្តីសម្រេចរបស់តុលាការតាមនីតិវិធីច្បាប់។

ដោយរបបសុំកូនពេញលេញ ត្រូវកាត់ផ្តាច់រាល់ទំនាក់ទំនងគតិយុត្តិទាំងអស់រវាងកុមារនឹងឳពុកម្តាយបង្កើត ឬ អាណាព្យាបាលរបស់ខ្លួន រួចបង្កើតទំនាក់ទំនងជាមួយឳពុកម្តាយចិញ្ចឹមវិញ។ លើសពីនេះ អានុភាពនៃកូនសុំត្រូវមានឋានៈដូចគ្នាទៅនឹងកូនបង្កើតរបស់ឳពុកម្តាយ និងត្រូវទទួលបាននូវរាល់សិទ្ធិ និង ករណីកិច្ចដូចគ្នាទាំងអស់ជាមួយកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយឳពុកម្តាយចិញ្ចឹម។

### ២.៤.២.២. ល័ក្ខខ័ណ្ឌនៃការបង្កើតសុំកូនពេញលេញ

ដើម្បីអាចបង្កើតសុំកូនពេញលេញបាន លុះត្រាបានបំពេញតាមល័ក្ខខ័ណ្ឌ ដែលបានកំណត់ដោយច្បាប់ ហើយមានល័ក្ខខ័ណ្ឌជាច្រើន ដែលល័ក្ខខ័ណ្ឌទាំងនេះទាក់ទងនឹងអាយុរបស់ឳពុកម្តាយចិញ្ចឹម និងកូនសុំ ការចូលរួមរបស់ភាគីដែលមានផលប្រយោជន៍ពាក់ព័ន្ធ។ ដោយការបង្កើតសុំកូនពេញលេញគឺ មិនមែនមានតែភាគី

[121] មាត្រា ១០២៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

ម្ខាងៗនោះទេគឺមានទាំងឪពុកម្តាយចិញ្ចឹម ឬ ឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម ក៏ដូចជាកូនសុំ និងនៅមានល័ក្ខខ័ណ្ឌដទៃមួយចំនួនទៀតផងដែរ។

**ក. ល័ក្ខខ័ណ្ឌចំពោះឪពុកម្តាយចិញ្ចឹម**

បើយោងតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ការសុំកូនពេញលេញអាចប្រព្រឹត្តទៅបានលុះត្រាតែឪពុកម្តាយចិញ្ចឹមទាំងពីរមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទៅតាមល័ក្ខខ័ណ្ឌដែលបានកំណត់ហើយត្រូវមានសេចក្តីសម្រេចរបស់តុលាការអោយមានការសុំកូនពេញលេញនោះ ទើបការសុំកូនកើតចេញជារូបរាងបានដូចជា៖

- ❖ អាយុរបស់ឪពុកម្តាយចិញ្ចឹម

ដោយយោងតាមមាត្រា១០០៩ នៃក្រមរដ្ឋប្បវេណី ពុំបានបញ្ជាក់ថាឪពុកម្តាយចិញ្ចឹមត្រូវមានអាយុ២៥ឆ្នាំគិតចាប់ពីពេលណានោះទេ ប៉ុន្តែនៅក្នុងក្រមរដ្ឋប្បវេណីបានកំណត់ត្រឹមតែថាឪពុកម្តាយចិញ្ចឹមរបស់កូនសុំត្រូវមានអាយុ២៥ឆ្នាំឡើង ទើបអាចបង្កើតសុំកូនពេញលេញបាន។ ហើយមួយវិញទៀតឪពុកម្តាយចិញ្ចឹមត្រូវមានអាយុច្រើនជាងកូនសុំយ៉ាងតិច ២០ឆ្នាំផងដែរ។[122] ប្រសិនបើអាយុឪពុកម្តាយតិចពេក នោះលទ្ធភាព និងបទពិសោធន៍នៃការថែទាំកូននៅមានកម្រិតដែលកូននិងមិនអាចទទួលបានការថែទាំដែលត្រឹមត្រូវ ម្យ៉ាងវិញទៀតពួកគេនិងមិនអាចផ្តល់នូវគ្រួសារយ៉ាងល្អប្រសើរជាងឪពុកម្តាយបង្កើតបាន ហេតុដូច្នេះហើយបានជាច្បាប់មានការតឹងរឹងចំពោះល័ក្ខខ័ណ្ឌនៃអាយុរបស់ឪពុកម្តាយដែលសុំកូនពេញលេញនេះ។

- ❖ ការសុំកូនដោយសហការរវាងសហព័ទ្ធ

បុគ្គលដែលក្លាយជាឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម ត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ[123]។ សហព័ទ្ធត្រូវមានការសហការ និងមានការឯកភាពយល់ព្រមរវាងប្តីប្រពន្ធ ប្រសិនបើមិនដូចច្នេះទេប្តី ឬ ប្រពន្ធតែម្ខាងមិនអាចក្លាយជាឪពុក ឬ ម្តាយចិញ្ចឹមគេបានឡើយ បើសហព័ទ្ធម្ខាងទៀតមិនមែនជាឪពុក ឬ ម្តាយចិញ្ចឹមនៃកូមសុំនោះ[124]។ តែលើកលែងចំពោះសហព័ទ្ធក្លាយជាឪពុកម្តាយ ឬ ម្តាយចិញ្ចឹមនៃកូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត ក្នុងករណីនេះគឺមានន័យថាប្រសិនបើសហព័ទ្ធម្ខាង ចង់សុំកូនរបស់សហព័ទ្ធម្ខាងទៀតមកធ្វើជាកូនសុំ នោះពុំចាំបាច់មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតឡើយ។

[122] មាត្រា ១០០៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[123] មាត្រា ១០០៨ កថាខ័ណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[124] មាត្រា ១០០៨ កថាខ័ណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

**ខ. ល័ក្ខខ័ណ្ឌចំពោះកូនសុំពេញលេញ**

ដោយនៅក្នុងក្រមរដ្ឋប្បវេណី មិនបានកំណត់ពីចំនួននៃកូនសុំនោះទេ។ ហើយជាគោលការណ៍កូនសុំត្រូវមានអាយុ៨ឆ្នាំ[125]។ ដោយសារតែបេបស្នុំកូនពេញលេញ គឺជារបបដែលបង្កើតឡើងរវាងឪពុកម្ដាយចិញ្ចឹម និង កុមារតូចក្នុងការបង្កើតញាតិថ្មី និងផ្ដាច់កូនសុំនោះពីញាតិចាស់ហើយកូនសុំត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ឪពុកម្ដាយចិញ្ចឹមទាំងស្រុង ដើម្បីទទួលនូវល័ក្ខខ័ណ្ឌគ្រួសារដ៏ល្អប្រសើរមួយ ដូច្នេះប្រសិនបើកូនសុំមានអាយុច្រើនល្មម និងអាចយល់ដឹងបាន នោះច្បាស់ជាបង្កើតជាបញ្ហាខានក្រោយពេលស្នុំកូនជាមិនខាន។

**គ. ល័ក្ខខ័ណ្ឌផ្សេងៗ**

ដើម្បីបង្កើតស្នុំកូនពេញលេញបានលុះត្រាតែ មានការយល់ព្រមពីឪពុកម្ដាយបង្កើត ឬ អាណាព្យាបាលរបស់កុមារដែលត្រូវជាកូនសុំនោះ ប៉ុន្តែក្នុងករណីឪពុកម្ដាយរបស់កូនសុំមិនអាចបង្ហាញឆន្ទៈបាន ឬ មានករណីមានការធ្វើបាបដោយឪពុកម្ដាយ បានបោះបង់កូនដោយគំនិតទុច្ចរិត ឬ ហេតុផលផ្សេងៗទៀតដែលបំពានផលប្រយោជន៍របស់កុមារដែលនឹងក្លាយជាកូនសុំនោះ ដោយក្នុងករណីនេះស្នុំកូនពេញលេញអាចបង្កើតបាន ដោយមិនចាំបាច់មានយល់ព្រមពីឪពុកម្ដាយបង្កើតឡើយ។ ការយល់ព្រមរបស់ឪពុកម្ដាយបង្កើតអាចដកវិញនៅពេលណាក៏បាន មុនពេលដីកាសម្រេចបង្កើតស្នុំកូនពេញលេញចូលជាស្ថាពរ ក្នុងករណីឪពុកម្ដាយបង្កើតរបស់កូនសុំដកនូវការយល់ព្រមតុលាការ ត្រូវលើកចោលពាក្យសុំបង្កើតនូវស្នុំកូនពេញលេញ លើកលែងតែដកការយល់ព្រមនោះប៉ះពាល់ដល់ផលប្រយោជន៍ធ្ងន់ធ្ងររបស់កូនសុំនោះ ដូចមូលហេតុដែលមានចែងនៅក្នុងមាត្រា១០១វាក្យខណ្ឌទី២នៃក្រមរដ្ឋប្បវេណី។

ដោយនៅក្នុងមាត្រា១០១៣បានចែងថា ដើម្បីបង្កើតស្នុំកូនពេញលេញបាន តុលាការត្រូវពិចារណាលើស្ថានភាពបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម បានធ្វើក្នុងការគ្រប់គ្រងថែរក្សាកុមារនឹងក្លាយជាកូនសុំជាគោលការណ៍យ៉ាងតិច៦ខែ (ប្រាំមួយខែ)។[126]

បន្ថែមពីនេះទៀត ស្នុំកូនពេញមានអានុភាពតាមច្បាប់ លុះត្រាតែបានបង្កើតតាមផ្លូវតុលាការ គឺមានន័យថាបុគ្គលដែលមានបំណងបង្កើតស្នុំកូនពេញលេញ ត្រូវតែដាក់ពាក្យសុំទៅតុលាការ។

---

[125] មាត្រា ១០១០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[126] មាត្រា ១០១៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

### ២.៤.២.៣. អានុភាពនៃសុំកូនពេញលេញ

យើងអាចឃើញថារបបសុំកូន បង្កើតអានុភាពនៅពេលដីការសម្រេចសុំកូនចូលជាស្ថាពរ។ ហើយនៅពេលចូលជាស្ថានពរនៃដីការសម្រេចនេះ វាបានបង្កើតនូវអានុភាពគតិយុត្តិមួយចំនួនផងដែរ មានដូចជា ការកាត់ផ្តាច់ទំនាក់ទំនងញាតិ និង ការបង្កើតទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹមជាដើម។[127]

#### ក. ការកាត់ផ្តាច់ទំនាក់ទំនងញាតិ

នៅពេលដែលដីការសម្រេចសុំកូនពេញលេញចូលជាស្ថានពរ នោះញាតិភាពរវាងឪពុកម្តាយបង្កើតត្រូវបានបញ្ចប់[128] គឺមានន័យថាឪពុកម្តាយ និងកូនបង្កើតក្លាយជាអ្នកដ៏ទៃលែងមានជាប់សាច់ឈាមនឹងគ្នាតទៅទៀតទាំងសិទ្ធិនិងករណីកិច្ចផ្សេងៗត្រូវបានកាត់ផ្តាច់ទាំងស្រុង លើកលែងតែករណីកូនសុំជាកូនរបស់សហព័ទ្ធម្ខាងទៀត។ ហេតុនេះ សិទ្ធិធ្វើសន្តតិកម្មចំពោះគ្នាទៅវិញទៅមក ត្រូវបានបាត់បង់និងមិនអាចទទួលកាតព្វកិច្ចទៅវិញទៅមកថែមទាំងមិនមានសិទ្ធិសួរសុខទុក្ខកូនបានផងដែរ។ ការកំណត់បែបនេះ ដោយហេតុជាគោលការណ៍នៃការបង្កើតសុំកូនពេញលេញ គឺបង្កើតញាតិថ្មីមួយ នៅក្នុងមជ្ឈដ្ឋាននៃគ្រួសាររបស់ឪពុកម្តាយចិញ្ចឹមដែលមានលក្ខណៈប្រសើរហើយកូនសុំ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុង របស់ឪពុកម្តាយចិញ្ចឹមប្រៀបដូចកូនបង្កើត ដូច្នេះដើម្បីជៀសវាងការរំខាន ឬ ការជ្រៀតជ្រែកដោយកាយវិការមិនសមរម្យរបស់ឪពុកម្តាយបង្កើតដោយប្រការណាមួយគឺត្រូវតែបញ្ចប់ទំនាក់ទំនងជាមួយឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតផងដែរ។ ការកំណត់បែបនេះ ជាមូលដ្ឋានសមរម្យនៅពេលដែលសុំកូនពេញលេញបានបង្កើតឡើង ព្រោះដើម្បីផលប្រយោជន៍ទាំងកូនដែលសុំ និងឪពុកម្តាយចិញ្ចឹមផងដែរ។ ប៉ុន្តែទោះបីទំនាក់ទំនងញាតិត្រូវបានបញ្ចប់ដោយការកំណត់របស់ច្បាប់ក៏ដោយ ប៉ុន្តែញាតិភាពជាមួយឪពុកម្តាយបង្កើតនិងញាតិភាពជាមួយលោហិតរបស់ឪពុកម្តាយបង្កើតជាឈាមជ័រតាមធម្មជាតិ ដូច្នេះការហាមឃាត់មិនអោយរៀបអាពាហ៍ពិពាហ៍ជាមួយញាតិលោហិត នៅតែបន្ត។[129]

#### ខ. ការបង្កើតទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹម

ទំនាក់ទំនងរវាងកូនចិញ្ចឹមនិងឪពុកម្តាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមនោះ នឹងត្រូវបង្កើតនូវញាតិភាពដូចគ្នានិងញាតិភាពលោហិត នៅពេលដីការសម្រេចចាប់ផ្តើមសុំកូនមានអានុភាពចូលជាស្ថាពរ[130]។ ដោយកូនសុំមានឋានៈដូចគ្នានិងកូនបង្កើត គឺត្រូវទទួលបានសិទ្ធិ និងករណីកិច្ចដូចគ្នានឹងកូនបង្កើត

[127] មាត្រា ១០១៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[128] មាត្រា ១០១៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[129] មាត្រា ៩៥១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[130] មាត្រា ៩៤០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

នៅក្នុងទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹម ហើយកូនសុំអាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬ នាមត្រកូលរបស់ខ្លួនមុនក៏បាន[131]។ កូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបាររបស់ឪពុកម្តាយចិញ្ចឹម[132]។ ម្យ៉ាងវិញទៀត ក្នុងករណីដែលប្តីប្រពន្ធណាមួយម្ខាងក្លាយជាឪពុកម្តាយចិញ្ចឹម ឬ ម្តាយចិញ្ចឹមរបស់កូនបង្កើតសហព័ទ្ធម្ខាងទៀត កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុកបង្កើត ឬ ម្តាយបង្កើត និងឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម។[133]

[131] មាត្រា ១០១៥ កថាខណ្ឌទី១និងទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[132] មាត្រា ១០១៥ កថាខណ្ឌទី៣ វាក្យខណ្ឌទី១ និងមាត្រា១០៣៥នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[133] មាត្រា ១០១៥ កថាខណ្ឌទី៣ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

# ជំពូកទី៣

# របបគតិយុត្តនៃការផ្ដាច់ទំនាក់ទំនងញាតិ

# ជំពូកទី៣

# របបគតិយុត្តនៃការផ្ដាច់ទំនាក់ទំនងញាតិ

ការកាត់កាល់កូន គឺជាការបោះបង់កូនលែងរាប់អានតទៅទៀត ព្រោះកូនមិនបានស្ដាប់តាមដំបូន្មានរបស់ឪពុកម្ដាយ ដោយយោងតាមវចនានុក្រមសម្ដេចសង្ឃរាជ ជួន ណាត។[134]ក៏ប៉ុន្តែបើតាមយោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាកំណត់ថា ការកាត់កាល់កូន គឺជាការកាត់ផ្ដាច់ទំនាក់ទំនងញាតិរវាងកូន និងឪពុកម្ដាយ ដែលបានផ្ដាច់នូវកាតព្វកិច្ច និងករណីកិច្ចរវាងកូន និងឪពុកម្ដាយ។ ចំពោះការកាត់កាល់កូននេះផងដែរ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិការកាត់កាល់តែ២ប្រភេទប៉ុណ្ណោះ គឺការកាត់កាល់កូនសុំធម្មតា[135] និងការកាតកាល់កូនសុំពេញលេញ[136] ចំពោះកូនបង្កើតក្រមរដ្ឋប្បវេណីមិនបានបញ្ញត្តិទេ ហើយច្បាប់នៃព្រះរាជាណាចក្រកម្ពុជាមិនទទួលស្គាល់ការកាត់កាល់កូនបង្កើតទេ។

## ៣.១.ចំពោះញាតិលោហិត

នៅក្នុងសង្គមកម្ពុជាបច្ចុប្បន្នមានឪពុកម្ដាយខ្លះបានសម្រេចកាត់កាល់កូនខ្លួនឯងចោលដោយលើកយកមូលហេតុផ្សេងៗមកអះអាងដូចជា កូននោះមិនស្ដាប់តាមការទូន្មានរបស់ពួកគាត់ ឬ ក៏ឈានទៅប្រព្រឹត្តអំពើល្មើសផ្សេងៗផ្ទុយនិងច្បាប់ ដែលមិនអាចគ្រប់គ្រងបាន។ រីឯមធ្យោបាយដែលឪពុកម្ដាយតែងធ្វើ គឺការជូនដំណឹងតាមប្រព័ន្ធផ្សព្វផ្សាយមាន កាសែត ទស្សនាវដ្ដី វិទ្យុ បណ្ដាញសង្គម ឬ មានករណីខ្លះបានទៅធ្វើលិខិតលាយលក្ខណ៍អក្សរប្រាប់អាជ្ញាធរមានសមត្ថកិច្ចជួយដឹងឮជាដើម...។ ឪពុកម្ដាយមិនអាចធ្វើការកាត់កាល់កូនរបស់ខ្លួនចោលដោយហេតុថា ច្បាប់មិនទទួលស្គាល់ ដោយទំនាក់ទំនងញាតិរវាងកូនបង្កើត និងឪពុកម្ដាយបង្កើតនៅតែមានដដែល ហើយគេសង្កេតឃើញមានឪពុកម្ដាយមួយចំនួនបានធ្វើការកាត់កាល់កូនរបស់ខ្លួន តាមរយៈការចុះកាសែតវិទ្យុ ទូរទស្សន៍ ឬ តាមបណ្ដាញទំនាក់ទំនងសង្គមផ្សេងៗ គឺគោលបំណងធំបំផុតរបស់ឪពុកម្ដាយបង្កើតមិនចង់ឲ្យមានការពាក់ព័ន្ធ និងទទួលខុសត្រូវនូវអំពើអនីត្យានុកូលរបស់កូន, មិនចង់ឲ្យកូនទទួលមរតកជាដើម តែការកាត់កាល់បែបនេះ គឺមិនមានលក្ខណៈត្រឹមត្រូវ ឬ មានអនុភាពតាមផ្លូវច្បាប់នោះទេ។ ចំពោះអំពើរបស់កូនដែលបានប្រព្រឹត្តនូវអំពើអ្វីមួយដែលផ្ទុយនឹងផ្លូវច្បាប់នោះ ប្រសិនបើកូននោះជាអនីតិជនមានអាយុក្រោម ១៨ ឆ្នាំ គឺកូននោះគឺត្រូវស្ថិតនៅក្រោមអំណាចមេបាររបស់ឪពុកម្ដាយនៅឡើយ ដូច្នេះឪពុកម្ដាយត្រូវទទួលខុសត្រូវចំពោះអំពើរបស់កូនខ្លួនដែលបានធ្វើឲ្យមានការខូចខាត ឬ បាត់បង់ផលប្រយោជន៍ដល់អ្នកដទៃ។ តែផ្ទុយមក

[134] វចនានុក្រមសម្ដេចសង្ឃរាជ ជួន ណាត។

[135] មាត្រា ១០២៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[136] មាត្រា ១០១៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

វិញបើកូននោះជានីតិជនដែលមានអាយុលើសពី ១៨ ឆ្នាំឡើងទៅ គឺកូនរបស់គាត់ត្រូវបានច្បាប់ចាត់ទុកថាមានសមត្ថភាពយល់ដឹងហើយត្រូវទទួលខុសនូវអំពើរបស់ខ្លួន ទាំងសំណងរដ្ឋប្បវេណី និងរឿងព្រហ្មទណ្ឌ ព្រោះថាឪពុកម្ដាយ លែងមានករណីយកិច្ចទទួលខុសត្រូវនូវអំពើខុសច្បាប់របស់កូនខ្លួនទៀតហើយ។

នៅក្នុងពេលបច្ចុប្បន្នកម្ពុជាយើងមិនមានច្បាប់ចែងស្ដីពីការកាត់កាល់រវាងកូនបង្កើត និងឪពុកម្ដាយបង្កើតនោះទេ ហើយច្បាប់មិនទទួលស្គាល់ចំពោះការកាត់កាល់នេះទេ។ ពីព្រោះក្រមរដ្ឋប្បវេណីបានបញ្ញត្តិផងដែរចំពោះបុគ្គលដែលបំពានដោយខុសច្បាប់នូវសិទ្ធិ ឬ ផលប្រយោជន៍ របស់ជនដទៃដោយកំហុសចេតនា ឬ ដោយកំហុសអចេតនាត្រូវទទួលខុសត្រូវក្នុងការសងការខូតខាតដែលកើតឡើងដោយអំពើនោះ។[137] តែដោយឡែកចំពោះជនដែលមានអាយុក្រោម ១៤(ដប់បួន)ឆ្នាំ និង បុគ្គលដែលស្ថិតក្នុងស្ថានភាពដែលមិនអាចយល់ដឹង ឬ មូលហេតុផ្សេងៗ មិនត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលឡើយ។ ពីព្រោះថាអ្នកដែលមានករណីកិច្ចត្រួតពិនិត្យ គឺសំដៅទៅលើ ឪពុកម្ដាយ អាណាព្យាបាល ឬ ហិតូបត្ថម្ភ ( ហិតូបត្ថម្ភ គឺការគ្រប់គ្រងលើជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ) បុគ្គលដែលមានករណីកិច្ចដែលច្បាប់បានកំណត់ក្នុងការត្រួតពិនិត្យ អនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ ឬ មានវិបត្តិខាងស្មារតី ឬ មូលហេតុផ្សេងៗទៀត ត្រូវសងនូវការខូចខាតរបស់អ្នកដ៏ទៃ ដោយអំពើបំពានរបស់អ្នកនៅក្រោមការត្រួតពិនិត្យរបស់ខ្លួននោះ។[138]

## ៣.២. ការកាត់កាល់ស្មុំកូនធម្មតា

### ៣.២.១. មូលហេតុ និង ការវិនិច្ឆ័យនៃការកាត់កាល់កូនធម្មតា

ការកាត់កាល់ គឺត្រូវបានប្រើលើគ្រប់ស្មុំកូនបានទាំងអស់ឲ្យតែអនុវត្តតាមច្បាប់ ដែលបាន បញ្ញត្តិជាធរមាន។ ការកាត់កាល់ គឺជាការបោះបង់លែងរាប់អានតទៅទៀត មានន័យថា បើមានពាក្យសុំកាត់កាល់ស្មុំកូនធម្មតា តុលាការអាចសម្រេចឲ្យកាត់កាល់បាន លុះត្រាតែបានបញ្ជាក់ថា ភាគីសងខាង មានបំណងពិតប្រាកដក្នុងការរំលាយទំនាក់ទំនងរវាងឪពុកម្ដាយ និង កូន។ បុគ្គលដែល អាចដាក់ពាក្យបណ្ដឹងទាមទារឲ្យកាត់កាល់បាន លុះត្រាតែភាគីម្ខាងទៀតបានប្រព្រឹត្តដូចបញ្ញត្តិក្នុង មាត្រា១០៣១នៃក្រមរដ្ឋប្បវេណី២០០៧។

ឧទាហរណ៍៖ ដូចជាឪពុកម្ដាយចិញ្ចឹមបានបោះបង់ កូន ចិញ្ចឹមដោយមានគំនិតទុច្ចរិត ឬ បើភាគីខាងឪពុកម្ដាយចិញ្ចឹម ឬ កូនចិញ្ចឹមមិនដឹងថារស់ ឬ ស្លាប់ក្នុងរយៈពេលយ៉ាងតិច១ឆ្នាំ ជាដើម។

---

[137] មាត្រា ៧៤៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[138] មាត្រា ៧៤៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

### ៣.២.២. ពាក្យសុំឲ្យកាត់កាល់សុំកូនធម្មតា

ភាគីនៃសុំកូន អាចដាក់ពាក្យសុំទៅតុលាការឲ្យកាត់កាល់សុំកូនធម្មតាបាន ក្នុងករណីដែលភាគីទាំងសងខាងព្រមព្រៀងអំពីការកាត់កាល់នោះ តែប្រសិនបើក្នុងករណីដែលកូនសុំជាអនីតិជន ពាក្យកាត់កាល់ដែលបានធ្វើឡើងដោយមានការព្រមព្រៀងគ្នានោះ ត្រូវធ្វើឡើងដោយឪពុកម្ដាយចិញ្ចឹម និង បុគ្គលដែលនឹងត្រូវក្លាយជាអ្នកតំណាង ដែលច្បាប់បានកំណត់ក្រោយពេលកាត់កាល់ តែបើកូនសុំដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ហើយត្រូវទទួលការយល់ព្រមពីកូនសុំនោះ។ តែទោះបីជាយ៉ាងណាក៏ដោយ អនីតិជននោះមិនទាន់ដល់អាយុ១៥ឆ្នាំក៏ដោយ បើអនីតិជននោះអាចបង្ហាញឆន្ទៈរបស់ខ្លួន តុលាការត្រូវសួរយោបល់របស់អនីតិជននោះ។ ក្នុងករណីដែលឪពុកម្ដាយបង្កើត របស់កូនសុំបានលែងលះគ្នាហើយ ឪពុកម្ដាយបង្កើតរបស់កូនសុំនោះត្រូវពិភាក្សា និងកំណត់ថា ឪពុក ឬ ម្ដាយបង្កើតជាបុគ្គលដែលត្រូវក្លាយជាអ្នកមានអំណាចមេបានៅក្រោយពេលកាត់កាល់ បើសិនជា ការពិភាក្សាខាងលើពុំបានសម្រេច ឬ ពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់បុគ្គល ដែលត្រូវក្លាយជាអ្នកមានអំណាចមេបា ដោយគិតពិចារណាទៅលើផលប្រយោជន៍របស់កូនសុំ។[139]

### ៣.២.៣. ល័ក្ខខ័ណ្ឌនៃការកាត់កាល់សុំកូនធម្មតា

ដើម្បីឲ្យការកាត់កាល់សុំកូនធម្មតាប្រព្រឹត្តទៅបាន លុះត្រាតែមានមូលហេតុដូចជា៖ ភាគីម្ខាងនៃសុំកូនអាចដាក់ពាក្យបណ្ដឹងទាមទារឲ្យកាត់កាល់បាន  លុះត្រាតែ បើត្រូវបានបោះបង់ចោលដោយភាគីម្ខាងទៀតដោយទុច្ចរិត។ បើមិនច្បាស់ ក្នុងអំឡុងពេលយ៉ាងតិច ១ (មួយ)ឆ្នាំ ភាគីម្ខាងទៀតនៅរស់ ឬ ទទួលមរណភាព។ បើមានហេតុធ្ងន់ធ្ងរផ្សេងទៀតដែលបណ្ដាលឲ្យមានការពិបាកក្នុងការបន្តសុំកូន។

ក្នុងអំឡុងពេលដែលកូនសុំពុំទាន់ក្លាយជានីតិជន ឪពុកម្ដាយចិញ្ចឹមមិនអាចដាក់ពាក្យបណ្ដឹង សុំកាត់កាល់ចំពោះកូនសុំបានឡើយ។ ទោះបីក្នុងករណីកូនសុំជាអនីតិជនក៏ដោយ ក៏កូនសុំអាចដាក់ពាក្យបណ្ដឹងចំពោះឪពុកម្ដាយ ចិញ្ចឹមបានដែរ ឲ្យតែបានគោរពល័ក្ខខ័ណ្ឌដូចដែលបានកំណត់ខាងលើ។

### ៣.២.៤. អានុភាពនៃការកាត់កាល់សុំកូនធម្មតា

អានុភាពទាំងឡាយនៃសុំកូនធម្មតា ត្រូវបញ្ចប់ទៅអនាគតដោយការកាត់កាល់ ហើយក្រោយ ការកាត់កាល់កូនសុំអាចទទួលបានវិញនូវនាមត្រកូលមុនសុំកូនក៏បាន ឬ អាចប្រើត្រកូលរបស់ ឪពុក ម្ដាយចិញ្ចឹមក៏បាន។

## ៣.៣. ការកាត់កាល់សុំកូនពេញលេញ

ការកាត់កាល់ គឺជាការបញ្ចប់ទំនាក់ទំនងញាតិរវាងកូនសុំ និងឪពុកម្ដាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយចិញ្ចឹម។ ការស្នើសុំកាត់កាល់កូនសុំពេញលេញបានលុះត្រាតែក្នុងករណីដែលត្រូវនិងចំណុចដែលបានកំណត់នៅក្នុងមាត្រា១០១៦ នៃក្រមរដ្ឋប្បវេណីដូចខាងក្រោម៖

[139] មាត្រា ១០២៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

### ៣.៣.១. មូលហេតុនៃការកាត់កាល់

ទោះបីកូនសុំមិនមែនជាកូនបង្កើតក៏ពិតមែន ប៉ុន្តែក្នុងច្បាប់បានកំណត់យ៉ាងច្បាស់លាស់ពីសិទ្ធិ និង ករណីកិច្ចដែលកូនសុំទទួលបានបន្ទាប់ពីដីការសម្រេចរបស់តុលាការចូលជាស្ថានពរ ហេតុនេះកូនសុំមានលក្ខណៈ ដូចនិងកូនបង្កើតដែរ ដូច្នេះឪពុកម្តាយចិញ្ចឹម និងកូនសុំក៏មិនអាចបញ្ចប់ទំនាក់ទំនងនឹងគ្នាងាយៗនោះទេ។ ម្យ៉ាងវិញទៀតសុំកូនគ្រាន់តែជាកូនដែលសន្មតតាមច្បាប់ នៅតែមិនមែនជាកូនបង្កើតដែលកើតចេញតាមខ្សែ លោហិត ដូចនេះសុំកូនអាចបញ្ចប់ទៅវិញដោយការកាត់កាល់ ដែលមានល័ក្ខខ័ណ្ឌចែងយ៉ាងតឹងរឹងនៅក្នុមាត្រា ១០១៦ នៃក្រមរដ្ឋប្បវេណី។

សុំកូនកើតឡើង ដោយសារតែចង់ជួយសង្គ្រោះកុមារអោយទទួលបានគ្រួសារថ្មីដែលមានសុភមង្គល ពេញលេញ ពោរពេញទៅដោយការរស់នៅដោយសមរម្យ ប៉ុន្តែប្រសិនបើមានការធ្វើបាបដោយឪពុកម្តាយចិញ្ចឹម បោះបង់កូនសុំចោលដោយគំនិតទុច្ចរិត ឬ ហេតុផលផ្សេងៗទៀតដែលបំពានដល់ផលប្រយោជន៍របស់កូនសុំ យ៉ាងធ្ងន់ធ្ងរ ឬ មិនទទួលបានការចិញ្ចឹមបីបាច់ថែរក្សាយ៉ាងត្រឹមត្រូវពីឪពុកម្តាយចិញ្ចឹម នោះកូនសុំអាចធ្វើពាក្យ បណ្តឹងទាមទារកាត់កាល់បាន។ ក្រៅពីនេះក៏នៅមានករណីមួយទៀតដែលជាហេតុនៃការកាត់កាល់នេះ គឺ ប្រសិនបើឪពុកម្តាយបង្កើតមានលទ្ធភាពគ្រប់គ្រាន់ក្នុងការថែរក្សាកូនបង្កើតបានឡើងវិញបាន។ លើសពីនេះ ក៏ នៅមានចំណុចមួយចំនួនផ្សេងទៀតដែលជាមូលហេតុនៃបណ្តឹងទាមទារនៃការកាត់កាល់ផងដែរ គឺអាស្រ័យលើ ឆន្ទានុសិទ្ធិរបស់តុលាការ។

### ៣.៣.២. អ្នកដែលមានសិទ្ធិកាត់កាល់

ជាមូលហេតុដែលនាំឲ្យអាចសម្រេចអោយកាត់កាល់ ត្រូវតែធ្វើឡើងតាមផ្លូវតុលាការ ដោយបណ្តឹង ទាមទារអោយកាត់កាល់ហើយការសម្រេចអំពីការកាត់កាល់ ត្រូវបានអនុលោមតាមច្បាប់ស្តីពីនីតិវិធីនៃបណ្តឹង ទាក់ទងនឹងឋានៈបុគ្គល។ ហើយអ្នកមានសិទ្ធិប្តឹង និងកាត់កាល់សុំកូនពេញលេញបានគឺមាន៖ តំណាងអយ្យការ ឪពុកម្តាយបង្កើត និងភាគីកូនសុំ[140]៖

#### ក. តំណាងអយ្យការ

តុលាការជាអ្នកមានអំណាចសម្រេចលើការកាត់កាល់ភាគីនៃកូនសុំបាន បើសិនឃើញថាការកាត់កាល់ នេះពិតជាមានភាពមិនបំរើផលប្រយោជន៍របស់កូនសុំតាមពាក្យរបស់កូនសុំ។

[140] មាត្រា ១០០៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

**ខ. ឪពុកម្ដាយបង្កើត**

បើមានការធ្វើបាបដោយឪពុកម្ដាយចិញ្ចឹម បោះបង់កូនចោលដោយគំនិតទុច្ចរិត ឬ ហេតុផលផ្សេងទៀត ដែលបំពានផលប្រយោជន៍កូនសុំយ៉ាងធ្ងន់ធ្ងរហើយឪពុកម្ដាយបង្កើត អាចគ្រប់គ្រង់ថែរក្សាដោយសមរម្យ។

**គ. ភាគីកូនសុំ**

ប្រសិនបើឪពុកម្ដាយចិញ្ចឹមមិនអាចមើលថែរក្សាកូនសុំអោយសមស្របទៅតាមការស្នើសុំនោះ ភាគីកូនសុំអាចធ្វើការប្ដឹងនឹងការកាត់កាល់សុំកូនពេញលេញបាន ដោយផ្អែកទៅតាមមាត្រា១០១៦ នៃក្រមរដ្ឋប្បវេណី ធ្វើបែបនេះគឺដើម្បីការពារនូវប្រយោជន៍នៃកូនចិញ្ចឹម។

ការកាត់កាល់ត្រូវធ្វើឡើងតាមនីតិវិធីបណ្ដឹងឋានៈបុគ្គល ហើយតុលាការធ្វើការសម្រេចសេចក្ដីដោយចេញសាលក្រម។

### ៣.៣.៣. អានុភាពនៃការកាត់កាល់សុំកូនពេញលេញ

តាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់នូវការបង្កើតឡើងវិញ ដោយស្វ័យប្រវត្តិនូវញាតិភាពរវាងកូនសុំ និងឪពុកម្ដាយបង្កើត និងញាតិភាពនៃឪពុកម្ដាយបង្កើត និងកូនសុំក្រោយពីបញ្ចប់ដោយសុំកូនពេញលេញត្រូវកើតឡើងវិញគិតចាប់ពីថ្ងៃបានកាត់កាល់។ រីឯញាតិភាពរវាងកូនចិញ្ចឹមសហព័ទ្ធរបស់ជននោះ បច្ឆាញាតិផ្ទាល់ និងសហព័ទ្ធរបស់បច្ឆាញាតិផ្ទាល់នោះ ជាមួយឪពុកម្ដាយចិញ្ចឹម និងញាតិលោហិតរបស់ឪពុកម្ដាយចិញ្ចឹមនោះ ត្រូវបានបញ្ចប់ដោយកាត់កាល់ ឬ លែងទទួលស្គាល់។

សរុបមកសេចក្ដី អានុភាពនៃសាលក្រមសម្រេចកាត់កាល់សុំកូនពេញលេញ និងធ្វើអោយកាត់ផ្ដាច់ទំនាក់ទំនងញាតិជាមួយឪពុកម្ដាយបង្កើត[141]។

## ៣.៤. ការផ្ដាច់ទំនាក់ទំនងញាតិតាមរយៈការលែងលះ

ដោយយោងតាមមាត្រា ៩៤១ ទំនាក់ទំនងញាតិពន្ធ ត្រូវបានបញ្ចប់ដោយការលែងលះគ្នា មានន័យថា ទំនាក់ទំនងញាតិភាពរវាងប្ដីប្រពន្ធត្រូវបានបញ្ចប់។ ម្យ៉ាងវិញទៀត ចំពោះករណីដែលសហព័ទ្ធណាម្ខាងបានទទួលមរណភាព ហើយសហព័ទ្ធដែលនៅរស់ បានរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ឬ បានបង្ហាញឆន្ទៈបញ្ចប់ទំនាក់ទំនងញាតិពន្ធ។[142] នៅប្រទេសកម្ពុជា ដោយសារតែមានករណីជាច្រើនដែលសហព័ទ្ធនៅរស់ នៅតែបន្តស្នាក់នៅជាមួយគ្រួសាររបស់សហព័ទ្ធដែលទទួលមរណភាព និង មើលថែទាំឪពុកម្ដាយរបស់សហព័ទ្ធដែលទទួលមរណភាពនោះ ដូច្នោះទើបមានការសម្រេចថា ទុកឲ្យសហព័ទ្ធដែលនៅរស់ជាអ្នកសម្រេចអំពីការរលត់ទំនាក់ទំនងញាតិពន្ធនោះ ដើម្បីកុំអោយពួកគេជាប់ចំណងដោយមិនសមហេតុផល។ ក៏ប៉ុន្តែ ប្រសិនបើសហព័ទ្ធដែលនៅ

[141] មាត្រា ១០១៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[142] មាត្រា ៩៤១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

រស់រៀបអាពាហ៍ពិពាហ៍ម្តងទៀតនោះទំនាក់ទំនងញាតិជាមួយនឹងញាតិរបស់សហព័ទ្ធថ្មីនិងកើតឡើងដែលធ្វើអោយទំនាក់ទំនងញាតិមានភាពស្មុគស្មាញ ទើបមាត្រានេះចែងថា ទំនាក់ទំនងញាតិពន្ធត្រូវបានបញ្ចប់ដោយសារការរៀបអាពាហ៍ពិពាហ៍ថ្មី។[143]

**ក. ទំនាក់ទំនងប្តីប្រពន្ធ**

ក្រោយពីប្តីប្រពន្ធបានលែងលះគ្នា ទំនាក់ទំនងញាតិពន្ធ និង សហព័ទ្ធ ត្រូវបានកាត់ផ្តាច់គ្នា។ លែងជាមានទំនាក់ទំនងញាតិពន្ធនិងគ្នា ចំពោះសិទ្ធិ កាតព្វកិច្ចនិងករណីកិច្ច ផ្សេងៗ ត្រូវបានរលត់ដូចគ្នា។ មួយវិញទៀត ក្រោយពីបានលែងលះគ្នាហើយ ប្តី ឬ ប្រពន្ធ ដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ដែលបានប្រើប្រាស់នាមត្រកូលថ្មីតាមសហព័ទ្ធ អាចប្តូរមកប្រើប្រាស់នាមត្រកូលចាស់ ដែលប្រើប្រាស់មុនពេលរៀបអាពាហ៍ពិពាហ៍វិញក៏បាន។ ហើយប្តី ឬ ប្រពន្ធក៏អាចបន្តប្រើប្រាស់នាមត្រកូលដែលបានបានប្តូរក្រោយពេលរៀបអាពាហ៍ពិពាហ៍ ក៏បាន ទោះបីជាលែងលះគ្នាហើយក៏ដោយ។

**ខ. ការកាត់ផ្តាច់ទំនាក់ទំនងគតិយុត្តនៃញាតិពន្ធ**

អានុភាពនៃការលែងលះ មិនមែនត្រឹមតែកាត់ផ្តាច់ទំនាក់ទំនងរវាងសហព័ទ្ធនោះទេ ការលែងលះថែមទាំងនាំឲ្យមានការកាត់ផ្តាច់ដល់ទំនាក់ទំនងញាតិពន្ធ ផងដែរ។ ពីព្រោះ ញាតិពន្ធ នេះកើតមានឡើងបន្ទាប់ពីមានចំណងអាពាហ៍ពិពាហ៍រវាងសហព័ទ្ធ ដែលនាំឲ្យមានការភ្ជាប់សាច់ញាតិ នៃភាគីទាំងសងខាង។ ហេតុនេះបានជាញាតិពន្ធ ក៏នឹងត្រូវបានបញ្ចប់ទៅវិញនៅពេលដែល ចំណងអាពាហ៍ពិពាហ៍បានបញ្ចប់ទៅវិញដូចគ្នា។ ពោលគឺ ក្រោយការលែងលះប្តី ឬ ប្រពន្ធមិនមានបន្សល់នៅទំនាក់ទំនងញាតិពន្ធបន្តទៀតឡើយ។

[143] មាត្រា ៩៨១ នៃសេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០១០។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានបញ្ចប់ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី “**ញាតិ**” ដោយផ្តោតទៅលើ ការបង្កើតទំនាក់ទំនងញាតិ និងការគណនាញាតិតាមផ្លូវច្បាប់។ ចំពោះការបង្កើតទំនាក់ទំនងញាតិ យើងសង្កេតឃើញថាការកើតមានឡើងនូវញាតិអាចមានឡើងជាច្រើនទំរង់ដែលរួមមានដូចជា ញាតិលោហិតក្នុង៦ថ្នាក់ សហព័ទ្ធ និងញាតិពន្ធក្នុង៣ថ្នាក់ជាដើម។ ប៉ុន្តែយើងសង្កេតថានៅក្នុងប្រទេសកម្ពុជាក្នុងពេលបច្ចុប្បន្ន ប្រជាពលរដ្ឋនៅមានការយល់ច្រលំអំពីការគណនាញាតិតាមច្បាប់ជាច្រើន ដែលទាក់ទងទៅនិងញាតិលោហិតក្នុង៦ថ្នាក់ ញាតិពន្ធ និងញាតិភាពតាមរយៈការសុំកូន។

ញាតិលោហិត ត្រូវបានកំណត់យ៉ាងជាក់ច្បាស់នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ហើយការគណនាថ្នាក់ញាតិ ត្រូវបានកំណត់ដោយគណនាចំនួននៃតំណពូជរវាងញាតិ  ហើយដើម្បីកំណត់ថ្នាក់ញាតិនៃសាខាញាតិបាន ត្រូវគណនាចំនួននៃតំណពូជនោះដោយគិតចាប់ពីជននោះ ឬ សហព័ន្ធរបស់ជននោះ ឡើងទៅដល់ជនដូចគ្នា និងចំនួននៃតំណពូជដោយគិតចាប់ពីបុព្វជនរបស់ជននោះ ចុះមករហូតទៅដល់ជនម្នាក់ទៀត ធ្វើឲ្យយើងអាចគណនាថ្នាក់ញាតិនៃជននោះ ឬ យើងអាចគណនាសាខាញាតិ ឬ ញាតិលោហិតខ្សែត្រង់បានផងដែរ ដែលបង្កើតឲ្យមានសិទ្ធិ និងករណីកិច្ចរវាងញាតិតាមផ្លូវច្បាប់ដែលបានកំណត់។ ហើយទំនាក់ទំនងញាតិនេះ បានបង្កើតឲ្យមាននូវអំណាចមេបា ដែលមានសិទ្ធិ និងកាតព្វកិច្ចរវាងឪពុកម្តាយចំពោះកូន ក្នុងការចិញ្ចឹមបីបាច់រក្សា ទំនុកបំរុង និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន ព្រមទាំងអប់រំ ទូន្មាន ប្រៀនប្រដៅកូន ឲ្យក្លាយទៅជាពលរដ្ឋល្អម្នាក់នៅក្នុងសង្គម។ រីឯកូនវិញ គឺមានករណីកិច្ចក្នុងការចិញ្ចឹម បីបាច់ថែរក្សា ទំនុកបំរុងចុងដើមនៅពេលឪពុកម្តាយចាស់ជរា និងពេលគាត់ទទួលមរណៈភាព ត្រូវធ្វើបុណ្យតាមប្រពៃណីទំនៀមទម្លាប់សាសនាជូនគាត់តាមលទ្ធភាព។

ចំពោះញាតិពន្ធបានបង្កើតឡើងនៅពេលបុរសនារីបានរៀបអាពាហ៍ពិពាហ៍តាមច្បាប់បានកំណត់។ ហើយញាតិពន្ធគឺគិតត្រឹម៣ថ្នាក់ ដែលរួមមាន ញាតិពន្ធខ្សែផ្ទាល់ក្នុង៣ថ្នាក់ និងសាខាញាតិពន្ធក្នុង៣ថ្នាក់។ រីឯការសុំកូនវិញគឺ មានលក្ខណៈបែងចែកដាច់ពីគ្នាផងដែរ រវាងការសុំកូនធម្មតា និងការសុំកូនពេញលេញ ដែលការសុំកូនទាំងពីរនេះបានបង្កើតនូវសិទ្ធិ កាតព្វកិច្ច និងករណីកិច្ចដូចៗគ្នា ទៅមានទំរង់នៃការសុំកូនធម្មតា និងការសុំកូនពេញលេញ ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។ កូនសុំអាចទទួលបានសិទ្ធិស្មើគ្នាទៅនិងកូនបង្កើតដែរ ចាប់តាំងពីពេលដែលតុលាការចេញដីការសម្រេចសុំកូន។

ក៏ប៉ុន្តែញាតិក៏អាចរលត់ទៅវិញផងដែរជាពិសេស ញាតិពន្ធ និងញាតិភាពតាមរយៈការសុំកូន។ ចំពោះការរលត់ញាតិពន្ធច្បាប់បានកំណត់ជា២កថាខណ្ឌ គឺការរលត់ញាតិក្រោយការលែងលះមិនសូវមានការភាន់ច្រលំទេ ដោយសារតែការលែងលះបានធ្វើទៅតាមនីតិវិធីរបស់តុលាការរួចរាល់ហើយញាតិក៏ត្រូវមានរលត់តាមការ

លែងលះនៅរួចហើយ ក៏ប៉ុន្តែការទទួលមរណភាពរបស់សហព័ទ្ធណាមួយខាងទើបជាបញ្ហាចោទយ៉ាងសំខាន់ ដែលពិបាកដឹងថាញាតិភាពរលត់នៅពេលណា ដោយយើងសង្កេតឃើញថាជាធម្មតាក្រោយពីសហព័ទ្ធណាមួយបានបាត់បង់ជីវិតទៅហើយសហព័ទ្ធដែលនៅរស់តែងតែនៅមើលថែរញាតិបុព្វញាតិខ្សែផ្ទាល់របស់សហព័ទ្ធដែលបាត់បង់ជីវិតទៅ។ ប៉ុន្តែបើយោងតាមច្បាប់បានកំណត់ ការរលត់ញាតិពន្ធក្រោយសហព័ទ្ធណាម្ខាងបានទទួលមរណភាព គឺត្រូវបានបញ្ចប់នៅពេលដែលសហព័ទ្ធដែលនៅរស់បានរៀបអាពាហ៍ពិពាហ៍ថ្មី។ ចំពោះស្មុំកូនក៏អាចកាត់ផ្តាច់ញាតិបានដែលតាមរយៈការកាត់កាលកូនស្មុំ ដោយហេតុកូនសុំផ្តាច់ដោយសារឪពុកម្តាយកូនសុំមិនបំពេញកាតព្វកិច្ច និងករណីកិច្ចចំពោះកូនស្មុំ ហើយការកាត់កាល់នេះត្រូវតែដាក់ពាក្យសុំទៅតុលាការសម្រេចនិងចេញដីការសម្រេច។

ហើយទាក់ទងនិងអាហារកាតព្វកិច្ច គឺញាតិក្លាយជាជនដែលមានករណីកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចតាមទំហំ និងតាមលំដាប់ដែលច្បាប់បានកំណត់ទៅតាមលំដាប់ដូចជា លំដាប់ទី១ ត្រូវជាញាតិដែលរស់នៅជាមួយគ្នា លំដាប់ទី២ ត្រូវជាញាតិលោហិតខ្សែផ្ទាល់ និងលំដាប់ទី៣ ត្រូវជាបងប្អូនបង្កើតជាដើម។

ចំពោះទំនាក់ទំនងប្រព័ន្ធញាតិ និងទ្រព្យសម្បត្តិវិញ គឺនៅពេលដែលបុគ្គលដែលជាញាតិបានទទួលមរណភាព បានបន្សល់ទុកនូវទ្រព្យសម្បត្តិ ឲ្យញាតិដែលនៅរស់នេះឯង តាមច្បាប់ត្រូវបានហៅថាសន្តិកម្ម។ ហើយសន្តិកម្មបានចាប់ផ្តើម បន្ទាប់ពីការទទួលមរណភាពរបស់មតកជន ដោយផ្អែកតាមឆន្ទៈរបស់មតកជនតាមរយៈបណ្តាំ ឬ តាមបញ្ញត្តិនៃច្បាប់ដែលបានកំណត់ ដែលផ្តល់អានុភាពដល់សន្តតិជនជាញាតិទាំងឡាយ ក្នុងការទទួលនូវសិទ្ធិ និងករណីកិច្ចទាំងអស់ របស់មតកជនចាប់តាំងពីពេលដែលបានប្រកាសចាប់ផ្តើមបើកទទួលសន្តតិកម្ម។ ហើយលំដាប់នៃសន្តតិជន ញាតិក៏ត្រូវបានបែងចែកដូចគ្នាមានដូចជា សន្តតិជនលំដាប់ទី១ សន្តតិជនលំដាប់ទី២ សន្តតិជនលំដាប់ទី៣ជាដើម ដោយសហព័ទ្ធជាសន្តតិជនជានិច្ច ត្រូវបានទទួលនូវចំណែកមរតក តាមលំដាប់ថ្នាក់នៃញាតិដែលច្បាប់បានកំណត់ ដោយគ្មានការរើសអើងឡើយទោះបីជាញាតិនោះជាកូនស្មុំក៏ដោយ។

សរុបមក ការសិក្សាពីញាតិ និងការគណនាថ្នាក់ញាតិ មានពិតជាមានសារៈសំខាន់ក្នុងការរាប់ញាតិឲ្យត្រូវតាមច្បាប់ និងធ្វើអោយយើងងាយស្រួលក្នុងការគណនារកថ្នាក់ញាតិ ទៅតាមប្រភេទនៃញាតិ ទំហំនៃញាតិក្នុងការស្វែងរកចំនួននៃថ្នាក់ដើម្បីកំណត់អំពីវិសាលភាពដែលបានកំណត់យ៉ាងជាក់លាក់នៅក្នុងរង្វង់គ្រួសាររបស់បុគ្គល និងងាយស្រួលក្នុងការបែងចែកទ្រព្យសម្បត្តិទៅតាមថ្នាក់នីមួយៗ តាមរយៈសន្តតិកម្មដែលច្បាប់បានកំណត់។

# អនុសាសន៍

# អនុសាសន៍

តាមរយៈការសិក្សាស្រាវជ្រាវលម្អិតពីប្រធានបទ "**ញាតិ**" រួចមកក្រុមយើងខ្ញុំបានយល់ឃើញថាថ្វីត្បិតតែរបបក្នុងការកំណត់នៃទំហំញាតិ និងទំនាក់ទំនងញាតិនេះមានវិសាលភាពធំផងក្តី ហើយការស្វែងយល់ពីញាតិនេះមានភាពស្មុកស្មាញ និងមានភាពមិនច្បាស់ស្រពិចស្រពិលជាច្រើចំណុច ច្រើនកន្លែងក្តី ចំពោះអ្នកសិក្សាដែលអានសារណានេះ គឺប្រធានបទញាតិនេះបានផ្តល់ជាផលលំបាកក្នុងការសិក្សាស្វែងយល់ក៏ពិតមែន តែបន្ទាប់ពីបានសិក្សាពីយល់ពីអត្ថរសនៃទំនាក់ទំនងញាតិនេះហើយ គឺវាបានតបស្នងសងផលទៅវិញដោយបានផ្តល់នូវផ្លែផ្កាដែលមានរសជាតិផ្អែមឆ្ងាញ់មានក្លិនក្រអូប ធ្វើឲ្យអ្នកអាននូវសារណានេះបានយល់ដឹងកាន់តែជាក់ច្បាស់ជាងមុន រាល់មន្ទិលដែលសង្ស័យ ត្រង់កន្លែងដែលបានងឿងឆ្ងល់នៅក្នុងចិត្ត និងបកស្រាយពង្រីកន័យបន្ថែម ព្រមទាំងបានបង្ហាញនូវនូវល័ក្ខខ័ណ្ឌផ្សេងៗដែលច្បាប់បានកំណត់ផងដែរ ។

ដោយចំណុចគោលសំខាន់នៃអត្ថបទសារណានេះបានផ្តោតយ៉ាងសំខាន់ទៅលើចំណុចចម្បងៗដូចខាងក្រោម៖

- យល់ដឹងពីអត្ថន័យនៃញាតិ : ដោយហេតុថា ញាតិមានវិសាលភាពធំណាស់ ទាំងអត្ថន័យ ការយល់ដឹងពី ប្រភេទ ដែលបានកំណត់អត្តសញ្ញាណរបស់បុគ្គលនៅក្នុងគ្រួសារនោះ ។
- ស្វែងយល់កាន់តែច្បាស់អំពីការគណនានៃថ្នាក់ញាតិ : ការគណនាថ្នាក់ញាតិនេះមានលក្ខណៈខុសៗគ្នាទៅតាមប្រភេទនៃញាតិ និងរបៀបក្នុងការគណនាក៏មានលក្ខណៈខុសគ្នាផងដែរ ដែលជាហេតុមួយធ្វើឲ្យសារណានេះ បានតាក់តែងចងក្រងឡើងដោយមានការងបែងចែកថ្នាក់ញាតិ និងរបៀបគណនាទៅតាមប្រភេទនីមួយៗដោយមានទាំងរូបមន្ត ព្រមទាំងរបៀបគណនារបស់ប្រភេទញាតិ ទៅតាមថ្នាក់នីមួយៗដែលធ្វើឲ្យអ្នកសិក្សាងាយស្រួលក្នុងការសិក្សាតាមលំដាប់លំដោយ និងមិនភ័ន្តច្រឡំ។
- យល់ដឹងកាន់តែច្បាស់ពីការកកើតនៃញាតិ : គឺញាតិមានការកកើតដោយ៣របៀប គឺ ញាតិដែលកើតឡើងតាមធម្មជាតិ មានន័យថាជាញាតិដែលកើតឡើងដោយតំណឈាមជ័រ ឬ ខ្សែលោហិតដែលបានបន្តពីឪពុកម្តាយ ទៅកាន់កូនៗជំនាន់ក្រោយ ។រីឯញាតិមួយប្រភេទទៀតកើតឡើងតាមរយៈការរៀបអាពាហ៍ពិពាហ៍ដែលមានដូចជាតាមរយៈសហព័ទ្ធ បង្កើតឲ្យមានញាតិពន្ធជាដើមនេះ។ ព្រមទាំងញាតិមួយប្រភេទទៀតកើតឡើងតាមរយៈច្បាប់ដូចជាតាមរយៈកូនស្មុំ ដែលត្រូវបែងចែកជាពីរគឺកូនស្មុំពេញលេញ និងកូនស្មុំធម្មតាជាដើម ដែលការស្មុំនេះត្រូវបានធ្វើឡើងទៅតាមនីតិវិធី ក៏ដូចជាតំណាក់កាលនីមួយៗនៃច្បាប់ តាមផ្លូវតុលាការ រហូតដល់មានការប្រកាសនូវសាលក្រមពីតុលាការ។
- យល់ដឹងបន្ថែមអំពីការរលត់ទៅវិញនៃញាតិ : គឺញាតិអាចរលត់ទៅវិញបានគឺដោយសារកត្តាចំនួន២យ៉ាងដូចជា កត្តាដែលកើតឡើងដោយឆន្ទៈរបស់បុគ្គលពីរនាក់ ឬ តែម្នាក់មានឆន្ទៈក្នុងការបញ្ចប់ទំនាក់

ទំនងជាផ្លូវការ និងកត្តាមួយទៀតគឺកើតឡើងដោយសារបុគ្គលដែលជាសាមីខ្លួន បានចាកចេញពីលំនៅដ្ឋានដោយឥតហេតុ ការជួបឧបទ្ទវហេតុដែលមិនសង្ឃឹមថានឹងអាចមានជីវិត ការជួបគ្រោះធម្មជាតិ មរណៈភាព ឬ ការកាត់កាល់ជាដើម ក៏ជាដើមហេតុនៃការរំលត់តញ្ញាតិផងដែរ ។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

១. រដ្ឋធម្មនុញ ឆ្នាំ១៩៩៣

២. ច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ២០១៨

៣. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

៤. ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ១៩៨៩

៥. សេចក្តីណែនាំស្តីពី ការអនុវត្តអនុក្រឹត្យស្តីពីការកំណត់បែបបទ និង នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និង បរទេស ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៨

៦. អនុក្រឹត្យស្តីពី ការអនុវត្តអនុក្រឹត្យស្តីពីការកំណត់បែបបទ និង នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និង បរទេស ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៨

៧. សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៥៖ គន្ថីទី៧ ឆ្នាំ២០១០

៨. ក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០

## វចនានុក្រម

១. ក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០

២. វចនានុក្រមខ្មែរសម្តេចសង្ឃជួន ណាត

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១៖** អនុក្រឹត្យស្តីពី ការអនុវត្តអនុក្រឹត្យស្តីពីការកំណត់បែបបទ និង នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និង បរទេស ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៨

**ឧបសម្ព័ន្ធទី២៖** ដីការសម្រេចសុំកូន

**ឧបសម្ព័ន្ធទី៣៖** នីតិវិធីមុខពេលរៀបអាពាហ៍ពិពាហ៍ និងក្រោយពេលរៀបអាពាហ៍ពិពាហ៍

**ឧបសម្ព័ន្ធទី៤៖** នីតិវិធីនៃការលែងលះ និងសាលក្រមលែងលះ

# ឧបសម្ព័ន្ធទី១៖

# អនុក្រឹត្យស្តីពី

# ការអនុវត្តអនុក្រឹត្យស្តីពីការកំណត់

# បែបបទ និង នីតិវិធីនៃការរៀប

# អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និង

# បរទេស ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៨

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៨៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញក្រឹត្យលេខ ៩៦ក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ ០៥ នស ៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៦/០២៦ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីឯកពន្ធភាព
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា រវាងពលរដ្ឋខ្មែរ និងជនបរទេស។

**មាត្រា ២.-**

ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសត្រូវផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត និងឆន្ទៈផ្ទាល់របស់សាមីខ្លួន និងត្រូវអនុវត្តតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣.-**

ត្រូវបានហាមឃាត់ដាច់ខាតចំពោះអាពាហ៍ពិពាហ៍ដែលធ្វើឡើងតាមរយៈភ្នាក់ងាររើសគូស្រករ ឈ្មួញកណ្តាល ឬក្រុមហ៊ុនអាជីវកម្ម។

**មាត្រា ៤.-**

ត្រូវបានហាមឃាត់ដាច់ខាតចំពោះអាពាហ៍ពិពាហ៍ក្លែងក្លាយ បោកបញ្ឆោត ក្នុងគោលបំណងកេងប្រវ័ញ្ចពលកម្ម ជួញដូរមនុស្ស ឬធ្វើអាជីវកម្មផ្លូវភេទ។

# ជំពូកទី ២
## បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរនិងជនបរទេស

**មាត្រា ៥.-**

ជនបរទេសដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ ចាំបាច់ត្រូវមានវត្តមាននៅព្រះរាជាណាចក្រកម្ពុជាដើម្បីបំពេញបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ ។

**មាត្រា ៦.-**

ដើម្បីរៀបអាពាហ៍ពិពាហ៍បានជាមួយពលរដ្ឋខ្មែរ សាមីខ្លួនជនបរទេសត្រូវបំពេញបែបបទទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ដោយភ្ជាប់នូវសំណុំឯកសារដូចខាងក្រោម :

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍
- ឯកសារថតចម្លងនៃ លិខិតឆ្លងដែនរបស់សាមីខ្លួនជនបរទេសមានទិដ្ឋាការចូលប្រទេសកម្ពុជា ដែលនៅមានសុពលភាព
- លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស
- លិខិតបញ្ជាក់សុខភាពចេញដោយសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា
- លិខិតថ្កោលទោសចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស
- លិខិតបញ្ជាក់អំពីមុខរបរពិតប្រាកដរបស់សាមីខ្លួនជនបរទេសដែលធានាដល់ជីវភាពរស់នៅចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស ។

ឯកសារថតចម្លងនៃលិខិតឆ្លងដែន និងលិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ត្រូវមានបញ្ជាក់នីត្យានុកូលភាពពីស្ថានទូត ឬស្ថានតំណាងនៃប្រទេសរបស់សាមីខ្លួនជនបរទេស ប្រចាំព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៧.-**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជាមានភារកិច្ចពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសាររបស់ជនបរទេសដែលសុំរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ និងត្រូវជូនដំណឹងទៅសាមីខ្លួនជនបរទេសវិញ ក្នុងរយៈពេលយ៉ាងយូរ០៥ថ្ងៃការងារ ។ ក្រោយពីបានពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសាររបស់ជនបរទេសហើយ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវបញ្ជូនសំណុំឯកសារទាំងនោះទៅក្រសួងមហាផ្ទៃ និងជូនពត៌មានទៅស្ថាប័នពាក់ព័ន្ធ ។

មាត្រា ៨.-

បន្ទាប់ពីទទួលសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេសពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងមហាផ្ទៃមានភារកិច្ច :

- ចុះបញ្ជីសំណុំឯកសាររបស់ជនបរទេសនោះ និងត្រូវជូនដំណឹងទៅសាមីខ្លួនជនបរទេសវិញ ក្នុងរយៈពេលយ៉ាងយូរ ០៥ថ្ងៃការងារ ។

- ជូនដំណឹងអំពីការសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ។

- ពិនិត្យនីត្យានុកូលភាពលើសំណុំឯកសារដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ។

មាត្រា ៩.-

សាមីខ្លួនជនបរទេស បន្ទាប់ពីបានទទួលការពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសារ និងបានចុះបញ្ជីសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍រួចហើយ ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ។

ចំពោះសាមីខ្លួនពលរដ្ឋខ្មែរ ដែលត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសនោះ ក៏ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍ដែលខ្លួនរស់នៅដោយមានភ្ជាប់នូវសំណុំឯកសារដូចខាងក្រោម :

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍
- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួនពលរដ្ឋខ្មែរ
- លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ចេញដោយមេឃុំ ឬចៅសង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ
- លិខិតបញ្ជាក់សុខភាពចេញដោយមន្ទីរពេទ្យ ដែលទទួលស្គាល់ជាផ្លូវការពីក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងសំណុំឯកសារសាមីខ្លួនជាពលរដ្ឋខ្មែរ និងជនបរទេសត្រូវដាក់ស្របពេលជាមួយគ្នា ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរដោយអនុវត្តតាមទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន ។

មាត្រា ១០.-

មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់មានភារកិច្ច ពិនិត្យ និងសម្រេចលើពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍របស់

សាមីខ្លួនបុរស និងនារី ក្នុងរយៈពេលយ៉ាងយូរ ០៣ថ្ងៃការងារ បន្ទាប់ពីបានទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងសំណុំឯកសារភ្ជាប់ ។

បន្ទាប់ពីពិនិត្យពាក្យសុំ និងសំណុំឯកសារភ្ជាប់របស់សាមីខ្លួនបុរស និងនារី បានត្រឹមត្រូវតាមគោលការណ៍ច្បាប់រួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវរៀបចំប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ដោយមានវត្តមានផ្ទាល់របស់សាមីខ្លួនបុរស និងនារី ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ។

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍នេះត្រូវបិទផ្សាយរយៈពេល១០ថ្ងៃ នៅស្ថានទូត ឬស្ថានតំណាងនៃប្រទេសសាមីខ្លួនជនបរទេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នៅលំនៅដ្ឋានអចិន្ត្រៃយ៍ និងនៅសាលាឃុំ សង្កាត់ នៃសាមីខ្លួនពលរដ្ឋខ្មែរ ស្របតាមការកំណត់ក្នុងបែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន ។ ផុតរយៈពេល១០ថ្ងៃ ប្រសិនគ្មានការប្តឹងតវ៉ាឬប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះ ទើបសាមីខ្លួនបុរស និងនារីអាចរៀបអាពាហ៍ពិពាហ៍បាន ។

**មាត្រា ១១.-**

អាពាហ៍ពិពាហ៍នឹងមានអនុភាពពេញលក្ខណៈច្បាប់បានលុះត្រាតែសាមីខ្លួនបុរស និងនារី ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍តាមរយៈការចុះបញ្ជីអាពាហ៍ពិពាហ៍ដោយសាមីខ្លួនផ្ទាល់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នៃឃុំ សង្កាត់ ដែលសាមីខ្លួនទាំងពីរបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ដោយនាំមកជាមួយនូវសាក្សីគ្រប់អាយុការចំនួន ០២រូបផង ស្របទៅតាមទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន ។

**មាត្រា ១២.-**

ក្រសួងមហាផ្ទៃត្រូវធ្វើសេចក្តីណែនាំដល់មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងអង្គភាពក្រោមឱវាទដែលពាក់ព័ន្ធ អំពីគំរូលិខិតស្នាម បែបបទ និងនីតិវិធីជាក់ស្តែងបន្ថែមទៀតទាក់ទងការសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិត្រូវធ្វើសេចក្តីណែនាំអំពីគំរូលិខិតស្នាម បែបបទ និងនីតិវិធីជាក់ស្តែងបន្ថែមទៀតទាក់ទងការសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេសជាមួយពលរដ្ឋខ្មែរ ។

## ជំពូកទី ៣
## អវសានប្បញ្ញត្តិ

**មាត្រា ១៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ ២០០៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ**

**ហោ ណាំហុង**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៤
- គ្រប់សាលាខេត្ត ក្រុង
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ :.០០៦.អាណន

រាជធានីភ្នំពេញ.ថ្ងៃទី១៤ ខែមករា ឆ្នាំ ២០០៩

# សេចក្តីណែនាំ
## ស្តីពី
## ការអនុវត្តអនុក្រឹត្យស្តីពីការកំណត់បែបបទ និងនីតិវិធី នៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរនិងជនបរទេស

យោងអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន

យោងអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស។

ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំដល់អង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ និង អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្នុងការអនុវត្តបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ដូចខាងក្រោម :

**១. អំពីភារកិច្ច**

**ក. ថ្នាក់ក្រសួង**

នាយកដ្ឋានរដ្ឋបាលទូទៅនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ជាសេនាធិការឱ្យក្រសួងលើការងារស្ថិតិ និងអត្រានុកូលដ្ឋាន និងមានភារកិច្ច :

- ចុះបញ្ជីសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនជនបរទេសដែលបានផ្ញើមកពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

- ជូនឯកសារសាមីខ្លួនជនបរទេសទៅអង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ ដើម្បីសហការផ្តល់ព័ត៌មានពីអត្តសញ្ញាណជនបរទេសនោះ

- ជូនដំណឹងអំពីការសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនជនបរទេស ទៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សាមី និងមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ និងជូនដំណឹង ព្រមទាំងប្រគល់សំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍ទៅសាមីខ្លួនជនបរទេស ក្នុងរយៈពេលយ៉ាងយូរ ០៥ ថ្ងៃការងារ ដើម្បីសាមីខ្លួនដាក់សំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ

- ពិនិត្យនីត្យានុកូលភាពលើសំណុំឯកសារដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ។

**ខ- ថ្នាក់រាជធានី ខេត្ត**

អភិបាលរាជធានី ខេត្ត ទទួលខុសត្រូវក្នុងការត្រួតពិនិត្យការអនុវត្តការងារស្ថិតិនិងអត្រានុកូលដ្ឋាននៅរាជធានី ខេត្តរបស់ខ្លួន ដោយមានការិយាល័យស្ថិតិនិងអត្រានុកូលដ្ឋាន នៃរាជធានី ខេត្ត ជាសេនាធិការ និងមានភារកិច្ចដូចខាងក្រោម :

- គាំទ្រ និងត្រួតពិនិត្យតាមដានការអនុវត្តការងារអត្រានុកូលដ្ឋាននៅក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់

- ផ្សព្វផ្សាយ និង ចលនាឱ្យមន្ទីរពាក់ព័ន្ធនានាជុំវិញរាជធានី ខេត្ត សហការផ្តល់ព័ត៌មានពីការអនុវត្តការងារអត្រានុកូលដ្ឋាននៅក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់

- បូកសរុបរបាយការណ៍ស្តីពីការអនុវត្តការងារអត្រានុកូលដ្ឋាននៅក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ផ្ញើមកក្រសួងមហាផ្ទៃ (នាយកដ្ឋានរដ្ឋបាលទូទៅ នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន) នៅរៀងរាល់ថ្ងៃទី ១៥ នៃខែបន្ទាប់ ។

**គ- ថ្នាក់ក្រុង ស្រុក ខណ្ឌ**

អភិបាលក្រុង ស្រុក ខណ្ឌ ទទួលខុសត្រូវក្នុងការត្រួតពិនិត្យការអនុវត្តការងារស្ថិតិ និងអត្រានុកូលដ្ឋាននៅក្រុង ស្រុក ខណ្ឌរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម :

- គាំទ្រ និងត្រួតពិនិត្យតាមដានការអនុវត្តការងារអត្រានុកូលដ្ឋាននៅឃុំ សង្កាត់

- ផ្សព្វផ្សាយ និងចលនាឱ្យការិយាល័យពាក់ព័ន្ធនានាជុំវិញក្រុង ស្រុក ខណ្ឌ សហការផ្តល់ព័ត៌មានពីការអនុវត្តការងារអត្រានុកូលដ្ឋាននៅឃុំ សង្កាត់

- បូកសរុបរបាយការណ៍ស្តីពីការអនុវត្តការងារអត្រានុកូលដ្ឋាននៅឃុំ សង្កាត់ ផ្ញើមករាជធានី ខេត្ត នៅរៀងរាល់ថ្ងៃទី ១០ នៃខែបន្ទាប់ ។

**ឃ- ថ្នាក់ឃុំ សង្កាត់**

ក្រុមប្រឹក្សាឃុំ សង្កាត់ ទទួលខុសត្រូវអំពីការងារអត្រានុកូលដ្ឋាននៅក្នុងដែនដីឃុំ សង្កាត់ ដែលខ្លួនគ្រប់គ្រង ។ មេឃុំ ចៅសង្កាត់ជាមន្ត្រីអត្រានុកូលដ្ឋាន ។

មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ក្រោយពីទទួលបាននូវសេចក្តីជូនដំណឹងពីក្រសួងមហាផ្ទៃ ស្តីពីការសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេសជាមួយពលរដ្ឋខ្មែរ និង បន្ទាប់ពីបានទទួលសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍ពីសាមីខ្លួនជនបរទេស និង ពីសាមីខ្លួនពលរដ្ឋខ្មែររួចហើយ មានភារកិច្ចដូចខាងក្រោម :

- ពិនិត្យ និង សម្រេចលើសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេស និង របស់ពលរដ្ឋខ្មែរយ៉ាងយូរក្នុងរយៈពេល០៣ថ្ងៃការងារ ។ ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងសំណុំឯកសារសាមីខ្លួនជាជនបរទេស

និងរបស់ពលរដ្ឋខ្មែរ ត្រូវដាក់ស្របពេលជាមួយគ្នាទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ពលរដ្ឋខ្មែរ ។

+ សំណុំឯកសារជនបរទេសមាន :

. ពាក្យសុំរៀបអាពាហ៍ពិពាហ៍ មានបិទរូបថតរបស់សាមីខ្លួនបុរស និងសាមីខ្លួននារី ទំហំ ៤ x ៦ ថតចំពីមុខ ក្នុងរយៈពេល ៣ខែចុងក្រោយ

. ឯកសារថតចម្លង នៃលិខិតឆ្លងដែនរបស់សាមីខ្លួនជនបរទេសមានទិដ្ឋាការចូលប្រទេសកម្ពុជា ដែលនៅមានសុពលភាព

. លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស

. លិខិតបញ្ជាក់សុខភាពចេញដោយសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា

. លិខិតថ្កោលទោសចេញដោយសមត្ថកិច្ចនៃប្រទេសសាមីខ្លួនជនបរទេស

. លិខិតបញ្ជាក់អំពីមុខរបរពិតប្រាកដរបស់សាមីខ្លួនជនបរទេស ដែលធានាដល់ជីវភាពរស់នៅចេញដោយសមត្ថកិច្ចនៃប្រទេសសាមីខ្លួនជនបរទេស

+ សំណុំឯកសារពលរដ្ឋខ្មែរមាន :

. ពាក្យសុំរៀបអាពាហ៍ពិពាហ៍ មានបិទរូបថតរបស់សាមីខ្លួនបុរស និងសាមីខ្លួននារី ទំហំ ៤ x ៦ ថតចំពីមុខ ក្នុងរយៈពេល ៣ខែចុងក្រោយ

. សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត

. លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ចេញដោយមេឃុំ ចៅសង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ( ករណីពោះម៉ាយ ឬមេម៉ាយដោយប្រពន្ធ ឬប្តីស្លាប់ត្រូវមានសំបុត្រមរណភាពរបស់សហព័ទ្ធ បើពោះម៉ាយឬមេម៉ាយដោយលែងលះត្រូវមានសាលក្រមពីសាលាដំបូង) ។

. លិខិតបញ្ជាក់សុខភាពចេញដោយមន្ទីរពេទ្យ ដែលទទួលស្គាល់ជាផ្លូវការពីក្រសួងសុខាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។

បើពិនិត្យឃើញឯកសារខាងលើមានលក្ខណៈត្រឹមត្រូវ ស្របតាមការកំណត់ក្នុងបែបបទ និងនីតិវិធីអត្រានុកូលដ្ឋានហើយ មន្ត្រីអត្រានុកូលដ្ឋានដោយមានវត្តមានផ្ទាល់របស់សាមីខ្លួនបុរស និងនារី ត្រូវចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ចំនួន ០៥ច្បាប់ ដោយមានបិទរូបថតសាមីខ្លួនបុរស និងនារី ទំហំ ៤ x ៦ ថតចំពីមុខ ក្នុងរយៈពេល ៣ខែចុងក្រោយ នៅខាងលើផ្នែកខាងស្តាំ សំរាប់ប្រើប្រាស់ដូចខាងក្រោម :

. ០១ច្បាប់ បិទផ្សាយជាសាធារណៈនៅលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ

. ០១ច្បាប់ បិទផ្សាយជាសាធារណៈនៅសាលាឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍សាមីខ្លួនពលរដ្ឋខ្មែរ

. ០១ច្បាប់ បិទផ្សាយជាសាធារណៈនៅស្ថានទូត ឬស្ថានតំណាង នៃប្រទេសសាមីខ្លួនជនបរទេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

. ០១ច្បាប់ រក្សាទុកនៅសាលាឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍សាមីខ្លួនពលរដ្ឋខ្មែរ

. ០១ច្បាប់ បិទផ្សាយជាសាធារណៈនៅលំនៅដ្ឋាន ឬទីកន្លែងស្នាក់នៅនៃសាមីខ្លួនជនបរទេស (ករណីជនបរទេសនោះ មានលំនៅដ្ឋាន ឬទីកន្លែងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា) ។

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍នេះត្រូវបិទផ្សាយរយៈពេល ១០ថ្ងៃ នៅទីកន្លែងដូចបានកំណត់ខាងលើ ។ ផុតរយៈពេល ១០ថ្ងៃ ប្រសិនបើគ្មានការប្តឹងតវ៉ា ឬប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះ ទើបសាមីខ្លួនបុរស និងនារីអាចរៀបអាពាហ៍ពិពាហ៍បាន ។

អាពាហ៍ពិពាហ៍នឹងមានអនុភាពពេញលក្ខណៈច្បាប់បានលុះត្រាតែសាមីខ្លួនបុរស និងនារីចុះកិច្ចសន្យាអាពាហ៍ពិពាហ៍តាមរយៈការចុះបញ្ជីអាពាហ៍ពិពាហ៍ ដោយសាមីខ្លួនផ្ទាល់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ ដែលសាមីខ្លួនទាំងពីរបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ដោយនាំមកជាមួយនូវសាក្សីគ្រប់អាយុការចំនួន ០២រូបផង ស្របទៅតាមទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន ។

- មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ក្រោយពីចុះបញ្ជីអាពាហ៍ពិពាហ៍តាមទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋានហើយ ត្រូវចេញសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមចំនួន ០១សន្លឹក និងចេញសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍តាមការស្នើសុំរបស់សាមីខ្លួន ដើម្បីយកទៅប្រើប្រាស់ ។

- ធ្វើរបាយការណ៍ជាបន្ទាន់ ផ្ញើមកក្រសួងមហាផ្ទៃ តាមរយៈក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត បន្ទាប់ពីបានចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស នីមួយៗរួចហើយ ដោយបញ្ជាក់អំពីលេខបញ្ជី លេខសៀវភៅ ថ្ងៃ ខែ ឆ្នាំចុះបញ្ជី ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងសញ្ជាតិរបស់សាមីខ្លួនបុរសនិងសាមីខ្លួននារី ។

- បូកសរុបរបាយការណ៍ស្តីពីការអនុវត្តការងារអត្រានុកូលដ្ឋាននៅឃុំ សង្កាត់ ផ្ញើមកសាលាក្រុង ស្រុក ខណ្ឌ នៅរៀងរាល់ថ្ងៃទី ០៥ នៃខែបន្ទាប់ ។

**២. <u>ចំពោះ និងការទទួលខុសត្រូវចំពោះមុខច្បាប់ ស្តីពីអត្រានុកូលដ្ឋាន</u>**

មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ មិនត្រូវអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរជាមួយជនបរទេសក្នុងករណីដូចខាងក្រោម :

ក- សំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនជនបរទេស ពុំបានចុះបញ្ជី និងពុំបានជូនដំណឹងពីការសុំរៀបអាពាហ៍ពិពាហ៍ពីក្រសួងមហាផ្ទៃ

ខ- សំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនជនបរទេស ឬរបស់សាមីខ្លួនពលរដ្ឋខ្មែរពុំបានបំពេញត្រឹមត្រូវតាមបែបបទ និងនីតិវិធីដែលបានកំណត់

គ- សាមីខ្លួនពលរដ្ឋខ្មែរពុំមានលំនៅដ្ឋានអចិន្ត្រៃយ៍នៅក្នុងឃុំ សង្កាត់ ក្នុងដែនដីដែលខ្លួនគ្រប់គ្រង

ឃ- សាមីខ្លួនពលរដ្ឋខ្មែរ និងជនបរទេសពុំទាន់គ្រប់អាយុដែលច្បាប់អនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍

ង- មានការប្តឹងតវ៉ា ឬប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះ ហើយមិនបានដោះស្រាយឱ្យបានចប់សព្វគ្រប់

មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវដូចខាងក្រោម :

ក- ត្រូវប្រើប្រាស់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋាន ដែលបោះពុម្ពតាមគំរូឯកភាពចេញដោយក្រសួងមហាផ្ទៃ និងអនុវត្តឱ្យបានត្រឹមត្រូវតាមបែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន អំពីការចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ការចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ ការចេញសំបុត្រអាពាហ៍ពិពាហ៍ និងការចេញសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍។

ខ- រាល់សំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ ក្រៅពីខ្ទង់សរសេរឈ្មោះជាអក្សរឡាតាំង គឺមិនអនុញ្ញាតឱ្យសរសេរភាសាបរទេសបញ្ចូលឡើយ

គ- រាល់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម និងសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទមិនអនុញ្ញាតឱ្យកោស ឆូត លុប ឬសរសេរជ្រៀតឡើយ។

៣. <u>**អំពីការបង់ថ្លៃក្រដាស និងថ្លៃតែមប្រើលើសំបុត្រអត្រានុកូលដ្ឋាន**</u>

ថ្លៃក្រដាសអត្រានុកូលដ្ឋាន និងតែមប្រើត្រូវអនុវត្តតាមអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការកំណត់ថ្លៃជាវក្រដាសអត្រានុកូលដ្ឋាន និងថ្លៃតែមប្រើសារពើពន្ធ ។

ទទួលបានសេចក្តីណែនាំនេះ ស្នើអង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ និងអាជ្ញាធររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ ចាត់ចែងផ្សព្វផ្សាយ និងមានវិធានការអនុវត្តឱ្យទទួលបានលទ្ធផលល្អ និងមានប្រសិទ្ធភាពខ្ពស់ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

<u>**ចម្លងជូន :**</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
  "ដើម្បីជូនជ្រាប"
- គ្រប់អង្គភាពចំណុះទីស្តីការក្រសួងមហាផ្ទៃ
- រាជធានីភ្នំពេញ គ្រប់ខេត្ត
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ចម/សាក.២/......

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យសុំរៀបអាពាហ៍ពិពាហ៍

APPLICATION FORM OF MARRIAGE

| រូបថត ៤ x ៦ សាមីខ្លួនប្រុស | រូបថត ៤ x ៦ សាមីខ្លួនស្រី |
|---|---|

ខ្ញុំបាទ នាងខ្ញុំឈ្មោះ ..............................

(Surname&Name) ..............................

ភេទ ......... សញ្ជាតិ ........................ ថ្ងៃខែឆ្នាំកំណើត ............................ ស្ថានភាពផ្ទាល់ខ្លួន ( នៅលីវឬពោះម៉ាយឬមេម៉ាយ ) ...............

(Sex) ......... (Nationality) ........................ (Date of Birth) ............................ (Marital Status) ..............................

ទីកន្លែងកំណើត ..............................

(Place of Birth) ..............................

លិខិតឆ្លងដែនលេខ ........................................ មុខរបរបច្ចុប្បន្ន ..............................

(Passport N°) ........................................ (Occupation) ..............................

ទីលំនៅបច្ចុប្បន្ន ..............................។

(Current Address) ..............................

ឪពុកឈ្មោះ ........................................ ថ្ងៃខែឆ្នាំកំណើត ............................ មុខរបរបច្ចុប្បន្ន ..............................

(Father's Name) ........................................ (Date of Birth) ............................ (Occupation) ..............................

ទីលំនៅបច្ចុប្បន្ន ..............................។

(Current Address)..............................

ម្តាយឈ្មោះ ........................................ ថ្ងៃខែឆ្នាំកំណើត ............................ មុខរបរបច្ចុប្បន្ន ..............................

(Mother's Name) ........................................ (Date of Birth) ............................ (Occupation) ..............................

ទីលំនៅបច្ចុប្បន្ន ..............................។

(Current Address) ..............................

**គោរពជូន** (To)

**មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់** ........................

(The registrar of the ........................ Commune/Sangkat)

**កម្មវត្ថុ** : សំណើសុំរៀបអាពាហ៍ពិពាហ៍

ខ្ញុំបាទ នាងខ្ញុំបានស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ.............................. ភេទ ....... ថ្ងៃខែឆ្នាំកំណើត ......................

(To request to marry with .............................. (Sex) .......... (Date of Birth) ..............................

មុខរបរបច្ចុប្បន្ន ........................................ ទីកន្លែងកំណើត ..............................

(Occupation) ........................................ (Place of Birth) ..............................

ទីលំនៅបច្ចុប្បន្នផ្ទះលេខ .............. ផ្លូវលេខ ............... ភូមិ .............................. ឃុំ សង្កាត់ ..............................

(Current Address) No ...................... (Street) ..................... (Village) .............................. (Commune/Sangkat) ..............................

ក្រុង ស្រុក ខណ្ឌ ........................................ រាជធានី ខេត្ត..............................។

(Municipality/District/Khan) ........................................ (Capital/ Province) ..............................

ខ្ញុំសូមសន្យាថា នឹងអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និង លិខិតបទដ្ឋានពាក់ព័ន្ធនានា នៃព្រះរាជាណាចក្រកម្ពុជា ។

(I pledge that I will abide by all the existing laws and regulations of the Kingdom of Cambodia).

អាស្រ័យហេតុនេះសូមមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ........................ មេត្តាអនុញ្ញាតឱ្យយើងខ្ញុំបានរៀបអាពាហ៍ពិពាហ៍ដោយអនុគ្រោះ ។

(Accordingly, please allow us to get married legally).

ធ្វើនៅ........................ថ្ងៃទី ......... ខែ ............ ឆ្នាំ២០០..

(Done on .............................. )

**ស្នាមមេដៃស្តាំ និងឈ្មោះសាមីខ្លួនជនបរទេស**

(Right thumbprint and name of the foreign applicant)

**សូមជូនភ្ជាប់មកជាមួយ** (Attached Document):

- ឯកសារថតចម្លងនៃលិខិតឆ្លងដែនមានទិដ្ឋាការចូលប្រទេសកម្ពុជា
  ( Copy of Passport and entry visa into Cambodia)
- លិខិតបញ្ជាក់ភាពនៅលីវឬមេម៉ាយឬពោះម៉ាយចំនួន ០១ច្បាប់
  (Certificate of Marital status)
- លិខិតបញ្ជាក់សុខភាពចំនួន ០១ច្បាប់ (Medical Certificate)
- លិខិតថ្កោលទោសចំនួន ០១ច្បាប់ (Criminal Record)
- លិខិតបញ្ជាក់ពីមុខរបរចំនួន ០១ច្បាប់ (Certificate of Profession)

អជ/សអ.១/......

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

| រូបថត ៤ x ៦ សាមីខ្លួនបុរស | រូបថត ៤ x ៦ សាមីខ្លួននារី |
|---|---|

## ពាក្យសុំរៀបអាពាហ៍ពិពាហ៍

ខ្ញុំបាទ នាងខ្ញុំឈ្មោះ .................................................. ជាអក្សរឡាតាំង ..................................................

ភេទ ....... សញ្ជាតិ ......... ថ្ងៃខែឆ្នាំកំណើត ......................... ស្ថានភាពផ្ទាល់ខ្លួន (នៅលីវ ឬពោះម៉ាយ ឬមេម៉ាយ) .........................

ទីកន្លែងកំណើត ..................................................................................................................................

លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ........................................ មុខរបរបច្ចុប្បន្ន ..................................................

ទីលំនៅបច្ចុប្បន្នផ្ទះលេខ ............... ផ្លូវលេខ ............. ភូមិ .................................. ឃុំ សង្កាត់ ..................................

ក្រុង ស្រុក ខណ្ឌ ........................................................... រាជធានី ខេត្ត ...............................................។

ឪពុកឈ្មោះ ................................................................ ជាអក្សរឡាតាំង ..................................................

ថ្ងៃខែឆ្នាំកំណើត .......................................................... មុខរបរបច្ចុប្បន្ន ..................................................

ទីលំនៅបច្ចុប្បន្ន ...............................................................................................................................។

ម្តាយឈ្មោះ ................................................................ ជាអក្សរឡាតាំង ..................................................

ថ្ងៃខែឆ្នាំកំណើត .......................................................... មុខរបរបច្ចុប្បន្ន ..................................................

ទីលំនៅបច្ចុប្បន្ន ...............................................................................................................................។

**គោរពជូន**

**មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ .....................**

**កម្មវត្ថុ** : សំណើសុំរៀបអាពាហ៍ពិពាហ៍

ដោយខ្ញុំបាទ នាងខ្ញុំបានស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ ..................................................

ជាអក្សរឡាតាំង ......................................... ភេទ .......... សញ្ជាតិ ................... ថ្ងៃខែឆ្នាំកំណើត ...................

លិខិតឆ្លងដែនលេខ ..................................... មុខរបរបច្ចុប្បន្ន .........................................................................

ទីកន្លែងកំណើត ..................................................................................................................................

ទីលំនៅបច្ចុប្បន្ន ...............................................................................................................................។

ខ្ញុំសូមសន្យាថា នឹងអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា នៃព្រះរាជាណាចក្រកម្ពុជា។

អាស្រ័យហេតុនេះ សូមមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ .................................... មេត្តាអនុញ្ញាតឱ្យយើងខ្ញុំទាំងពីរបាន រៀបអាពាហ៍ពិពាហ៍តាមសំណូមពរដោយអនុគ្រោះ។

ធ្វើនៅ......................ថ្ងៃទី ....... ខែ ........... ឆ្នាំ២០០..

**ស្នាមមេដៃស្តាំ និងឈ្មោះសាមីខ្លួនពលរដ្ឋខ្មែរ**

**សូមជូនភ្ជាប់មកជាមួយ :**

- សេចក្តីចម្លងសំបុត្រកំណើត ឬបញ្ជាក់កំណើត ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ចំនួន ០១ ច្បាប់
  (ករណីពោះម៉ាយឬមេម៉ាយដោយប្រពន្ធឬប្តីស្លាប់ ត្រូវមានសំបុត្រមរណភាពរបស់សហព័ទ្ធ បើពោះម៉ាយ ឬមេម៉ាយ ដោយការលែងលះ ត្រូវមានសាលក្រមពីសាលាដំបូង)
- លិខិតបញ្ជាក់សុខភាព ចំនួន ០១ ច្បាប់

(គំរូ)

*រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០០..*

**ជម្រាបមក**

**ឯកឧត្តមអភិបាលរាជធានី ខេត្ត** ......................

**<u>កម្មវត្ថុ</u>** : ការលើកស្នើសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេសឈ្មោះ...........................................................

**<u>យោង</u>** :
- អនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស
- សេចក្តីណែនាំលេខ...........សជណ ចុះថ្ងៃទី...... ខែ....... ឆ្នាំ២០០..... របស់ក្រសួងមហាផ្ទៃ ស្តីពីការអនុវត្តបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស
- លិខិតស្នើសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេសឈ្មោះ ....................................................... ចុះថ្ងៃទី ........ ខែ ........... ឆ្នាំ ២០០...

តបតាមកម្មវត្ថុ និងយោងខាងលើ ក្រសួងមហាផ្ទៃ ជំរាបមកឯកឧត្តមអភិបាល............... ជ្រាបថា ជនបរទេសឈ្មោះ....................................... ភេទ ...... សញ្ជាតិ .......... ថ្ងៃខែឆ្នាំកំណើត ..................... លិខិតឆ្លងដែនលេខ ......................... បានស្នើសុំរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ .................................. ភេទ ....... ថ្ងៃខែឆ្នាំកំណើត ............................. ទីលំនៅបច្ចុប្បន្នផ្ទះលេខ ......... ផ្លូវលេខ ..... ក្រុម ...... ភូមិ ............. ឃុំ សង្កាត់ .......................ក្រុង ស្រុក ខណ្ឌ ......................... រាជធានី ខេត្ត .................។

ក្រសួងមហាផ្ទៃ បានពិនិត្យ និងចុះបញ្ជី លើសំណុំឯកសារស្នើសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនជនបរទេសរួចរាល់ហើយ ។ ដូច្នេះ សាមីខ្លួនជនបរទេសត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ............................។

សេចក្តីដូចបានជំរាបខាងលើ សូមឯកឧត្តមអភិបាល ជ្រាបតាមការគួរ ។/

**ជ. រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**<u>ចម្លងជូន</u>** :
- ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- សាលាក្រុង ស្រុក ខណ្ឌ.........
  "ដើម្បីជ្រាប"
- សាលាឃុំ សង្កាត់.........
- សាមីខ្លួន
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី២៖
# ដីការសម្របសម្រួលកូន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូង** .....

**ដីកាសម្រេចលេខ:** ..............
ថ្ងៃទី ...... ខែ..... ឆ្នាំ ......

# ដីកាសម្រេចបង្កើតសុំកូនពេញលេញ

យើង ................................ ចៅក្រមនៃសាលាដំបូង ..................។

-បានឃើញ មាត្រា ៣ និងមាត្រាពាក់ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០១០។

-បានឃើញ មាត្រា ១០០៧ និងមាត្រាពាក់ព័ន្ធនៃក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧ ។

-បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ....... ចុះថ្ងៃទី ...... ខែ ...... ឆ្នាំ ....... ។

**អ្នកដាក់ពាក្យសុំ ៖**

១. ឈ្មោះ .................. ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ......... ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ............ ម្តាយឈ្មោះ .............. ។

២. ឈ្មោះ .................. ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ......... ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ............ ម្តាយឈ្មោះ .............. ។

**ឪពុកម្តាយបង្កើត ៖**

១. ឈ្មោះ .................. ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ......... ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ............ ម្តាយឈ្មោះ .............. ។

២. ឈ្មោះ .................. ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ......... ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ............ ម្តាយឈ្មោះ .............. ។

**កូនឈ្មោះ ៖** ................ ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ......... ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ........... ម្ដាយឈ្មោះ ............. ។

**ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ ៖** បង្កើតសុំកូនពេញលេញរវាងឈ្មោះ ក. ភេទ ... កើតថ្ងៃទី ... ខែ .... ឆ្នាំ ....... ឈ្មោះ ខ. ភេទ ... កើតថ្ងៃទី ... ខែ ... ឆ្នាំ ... ដែលមានឋានៈជាឪពុកម្ដាយចិញ្ចឹម និង ឈ្មោះ គ. ភេទ ... កើតថ្ងៃទី....... ខែ ....... ឆ្នាំ ........ ដែលមានឋានៈជាកូនសុំ។

## សំអាងហេតុ

យោងតាមលទ្ធផលនៃការសាកសួរសាមីភាគី និង ពិនិត្យភស្តុតាងដែលមាននៅក្នុងសំណុំរឿង ឃើញថា ៖

១. អ្នកដាក់ពាក្យសុំឈ្មោះ ក. ភេទប្រុស កើតនៅថ្ងៃទី .... ខែ ..... ឆ្នាំ......... ដោយមានសំបុត្រកំណើតលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ជាប្ដី និង ឈ្មោះ ខ. ភេទស្រី កើតថ្ងៃទី ... ខែ ... ឆ្នាំ ... គឺជាសហព័ទ្ធនឹងគ្នា ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ។ ឈ្មោះ គ. ភេទ ... កើតនៅថ្ងៃទី .... ខែ ... ឆ្នាំ .... ដោយមានសំបុត្រកំណើតលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ...។ អ្នកដាក់ពាក្យសុំឈ្មោះ ក. មានអាយុ ... និង ឈ្មោះ ខ. មានអាយុ ... ពោលគឺមានអាយុលើសឈ្មោះ គ. លើសពី ២០ ឆ្នាំ។ ដូច្នេះ អ្នកដាក់ពាក្យសុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដើម្បីបង្កើតសុំកូនពេញលេញ តាមមាត្រា ១០០៨ មាត្រា ១០០៩ និង មាត្រា ១០១០ នៃក្រមរដ្ឋប្បវេណី។

២. ឈ្មោះ ង. និង ឈ្មោះ ច. ត្រូវជាឪពុកម្ដាយបង្កើតរបស់ឈ្មោះ គ. បានយល់ព្រមឱ្យឈ្មោះ គ. ទៅឈ្មោះ ក. និង ឈ្មោះ ខ. ចិញ្ចឹមធ្វើជាកូនសុំពេញលេញ ដោយសារតែពួកខ្លួនមិនមានលទ្ធភាពសមរម្យក្នុងការចិញ្ចឹមបីបាច់ថែរក្សាឈ្មោះ គ.។

៣. បន្ទាប់ពីឈ្មោះ ក. និង ឈ្មោះ ខ. បានសាកល្បងចិញ្ចឹមឈ្មោះ គ. អស់រយៈពេល ... កន្លងមក ឃើញថា ឈ្មោះ ក. និង ឈ្មោះ ខ. បានរស់នៅចុះសម្រុងជាមួយនឹងឈ្មោះ គ.។

៤. មានស្ថានភាពគ្រប់គ្រាន់ដែលជាមូលដ្ឋានក្នុងការបង្កើតសុំកូនពេញលេញ សមស្របទៅតាមផលប្រយោជន៍កូន។

៥. យោងតាមមាត្រា ២២ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ប្រាក់ប្រដាប់ក្ដីគឺជាបន្ទុករបស់អ្នកដាក់ពាក្យសុំ។

## សេចក្ដីសម្រេចបញ្ចប់

១. បង្កើតសុំកូនពេញលេញ រវាងឈ្មោះ ក. ភេទ ... កើតថ្ងៃទី... ខែ ..... ឆ្នាំ ...... ឈ្មោះ ខ. ភេទ ... កើតថ្ងៃទី ... ខែ ... ឆ្នាំ ... ដែលមានឋានៈជាឪពុកម្ដាយចិញ្ចឹម និង ឈ្មោះ គ. ភេទ ... កើតថ្ងៃទី....... ខែ ....... ឆ្នាំ ........ ដែលមានឋានៈជាកូនសុំ។

២. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់អ្នកដាក់ពាក្យសុំ។

**ចៅក្រម**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូង ......**

**ដីកាសម្រេចលេខ:** ..............
ថ្ងៃទី...... ខែ...... ឆ្នាំ......

# ដីកាសម្រេចបង្កើតសុំកូនធម្មតា

យើង ...................................... ចៅក្រមនៃសាលាដំបូង ..................។

-បានឃើញ មាត្រា ៣ និងមាត្រាពាក់ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១០/ ០១៣ ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០១០។

-បានឃើញ មាត្រា ១០២០ និងមាត្រាពាក់ព័ន្ធនៃក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧ ។

-បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ....... ចុះថ្ងៃទី ...... ខែ ...... ឆ្នាំ ....... ។

**អ្នកដាក់ពាក្យសុំ ៖**

១. ឈ្មោះ ................. ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ........ ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ........... ម្តាយឈ្មោះ ............. ។

២. ឈ្មោះ ................. ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ........ ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ........... ម្តាយឈ្មោះ ............. ។

**ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ ៖** បង្កើតសុំកូនធម្មតារវាងឈ្មោះ **ក.** ភេទ ...... កើតថ្ងៃទី.... ខែ ..... ឆ្នាំ ....... ដែលមានឋានៈជាម្តាយចិញ្ចឹម និង ឈ្មោះ **ខ.** ភេទ ... កើតថ្ងៃទី........ ខែ ........ ឆ្នាំ ......... ដែលមានឋានៈជាកូនសុំ។

## សំអាងហេតុ

យោងតាមលទ្ធផលនៃការសាកសួរសោមីភាគី និង ពិនិត្យភស្តុតាងដែលមាននៅក្នុងសំណុំរឿង ឃើញថា ៖

១. អ្នកដាក់ពាក្យសុំឈ្មោះ ក. ជាស្ត្រីមេម៉ាយ កើតនៅថ្ងៃទី .... ខែ ..... ឆ្នាំ......... ដោយមានសំបុត្រកំណើតលេខ .... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ពោលគឺមានអាយុ ..... បានព្រមព្រៀងបង្កើតសុំកូនធម៌តា ជាមួយនឹងឈ្មោះ ខ. នៅ លីវ ដែលកើតនៅថ្ងៃទី .... ខែ ... ឆ្នាំ .... ដោយមានសំបុត្រកំណើតលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ...។ អ្នកដាក់ពាក្យសុំឈ្មោះ ខ. មានអាយុតិចជាងអ្នកដាក់ពាក្យសុំឈ្មោះ ក. ហើយក៏មិនមែនជាបុព្វញាតិរបស់អ្នកដាក់ពាក្យសុំឈ្មោះ ក. ដែរ។

២. អ្នកដាក់ពាក្យសុំឈ្មោះ ក. និង អ្នកដាក់ពាក្យសុំឈ្មោះ ខ. មានឆន្ទៈពិតប្រាកដក្នុងការបង្កើតទំនាក់ទំនងជាម្ដាយ និងកូន។

៣. អ្នកដាក់ពាក្យសុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីបង្កើតសុំកូនធម៌តាបាន តាមមាត្រា ១០២០ នៃក្រមរដ្ឋប្បវេណី។

៤. យោងតាមមាត្រា ២២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ប្រាក់ប្រដាប់ក្តីគឺជាបន្ទុករបស់អ្នកដាក់ពាក្យសុំ។

## សេចក្តីសម្រេចបញ្ចប់

១. បង្កើតសុំកូនធម៌តា រវាងឈ្មោះ ក. ភេទ ... កើតថ្ងៃទី.... ខែ ..... ឆ្នាំ ........ ដែលមានឋានៈជាម្ដាយចិញ្ចឹម និង ឈ្មោះ ខ. ភេទ ... កើតថ្ងៃទី........ ខែ ........ ឆ្នាំ ......... ដែលមានឋានៈជាកូនសុំ។

២. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់អ្នកដាក់ពាក្យសុំ។

**ចៅក្រម**

# ឧបសម្ព័ន្ធទី៣៖
# នីតិវិធីមុខពេល
# រៀបអាពាហ៍ពិពាហ៍ និងក្រោយពេល
# រៀបអាពាហ៍ពិពាហ៍

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត.................................
ក្រុង ស្រុក ខណ្ឌ..............................
ឃុំ សង្កាត់.....................................

លេខ .............................................
សៀវភៅកំណើតលេខ ........................
ឆ្នាំ..............................................

# សំបុត្រកំណើត

<table>
<tr><td colspan="2">នាមត្រកូល</td><td colspan="2"></td><td rowspan="2">ភេទ</td></tr>
<tr><td colspan="2">នាមខ្លួនទារក</td><td colspan="2"></td></tr>
<tr><td rowspan="2">ជាអក្សរឡាតាំង</td><td>នាមត្រកូល</td><td colspan="3"></td></tr>
<tr><td>នាមខ្លួនទារក</td><td colspan="3"></td></tr>
<tr><td colspan="2">សញ្ជាតិ</td><td colspan="3"></td></tr>
<tr><td colspan="2">ថ្ងៃ ខែ ឆ្នាំកំណើត</td><td colspan="3"></td></tr>
<tr><td colspan="2">ទីកន្លែងកំណើត<br>ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ<br>រាជធានី ខេត្ត ប្រទេស</td><td colspan="3">..............................................<br>..............................................</td></tr>
<tr><td colspan="2">ឪពុក ម្ដាយទារក</td><td>ឪពុក</td><td colspan="2">ម្ដាយ</td></tr>
<tr><td colspan="2">នាមត្រកូល និង នាមខ្លួន</td><td></td><td colspan="2"></td></tr>
<tr><td colspan="2">ជាអក្សរឡាតាំង</td><td></td><td colspan="2"></td></tr>
<tr><td colspan="2">សញ្ជាតិ</td><td></td><td colspan="2"></td></tr>
<tr><td colspan="2">ថ្ងៃ ខែ ឆ្នាំកំណើត</td><td></td><td colspan="2"></td></tr>
<tr><td colspan="2">ទីកន្លែងកំណើត<br>ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ<br>រាជធានី ខេត្ត ប្រទេស</td><td>..............................<br>..............................</td><td colspan="2">..............................<br>..............................</td></tr>
<tr><td colspan="2">ទីលំនៅពេលទារកកើត</td><td colspan="3"></td></tr>
</table>

ធ្វើនៅ...............................ថ្ងៃទី.........ខែ............ឆ្នាំ..............

**មន្ត្រីអត្រានុកូលដ្ឋាន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង.......................................
ស្រុក ខណ្ឌ.......................................
ឃុំ សង្កាត់.......................................

# សេចក្តីចម្លងសំបុត្រកំណើត

| ចម្លងសំបុត្រកំណើតចេញពី | | សៀវភៅកំណើត<br>លេខ | សំបុត្រកំណើត<br>លេខ...........ចុះថ្ងៃទី.......ខែ..........ឆ្នាំ......... |
|---|---|---|---|
| នាមត្រកូល | | | ភេទ |
| នាមខ្លួនទារក | | | |
| ជាអក្សរឡាតាំង | នាមត្រកូល | | |
| | នាមខ្លួនទារក | | |
| សញ្ជាតិ | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | |
| ទីកន្លែងកំណើត<br>ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | | ..............................<br>.............................. | |

| ឪពុក ម្តាយទារក | ឪពុក | ម្តាយ |
|---|---|---|
| នាមត្រកូល និង នាមខ្លួន | | |
| ជាអក្សរឡាតាំង | | |
| សញ្ជាតិ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| ទីកន្លែងកំណើត<br>ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | ..............................<br>.............................. | ..............................<br>.............................. |
| ទីលំនៅពេលទារកកើត | | |

ធ្វើនៅ...........................ថ្ងៃទី........ខែ.......... ឆ្នាំ.............

មន្ត្រី ..................................

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានី/ខេត្ត..................
ក្រុង/ស្រុ/កខណ្ឌ..............
ឃុំ/សង្កាត់......................
លេខ............................

| |
|---|
| រូបថត<br>៤x៦ |

## លិខិតបញ្ជាក់
## ភាពនៅលីវ មេម៉ាយ ឬពោះម៉ាយ
## សូមបញ្ជាក់ថា

ឈ្មោះ........................... ភេទ....... មុខរបរ............ សញ្ជាតិ.......... កើតថ្ងៃទី....... ខែ....... ឆ្នាំ............ ទីកន្លែងកំណើត ភូមិ........... ឃុំ/សង្កាត់............. ក្រុង/ស្រុក/ខណ្ឌ........... ខេត្ត/រាជធានី............. ។

- ឪពុកឈ្មោះ........................ អាយុ.......ឆ្នាំ មុខរបរ............ ថ្ងៃខែឆ្នាំកំណើត......................
- ម្ដាយឈ្មោះ........................ អាយុ.......ឆ្នាំ មុខរបរ............ ថ្ងៃខែឆ្នាំកំណើត......................

ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ.......... ផ្លូវ.......... ក្រុមទី........ ភូមិ........... ឃុំ/សង្កាត់............. ក្រុង/ស្រុក/ខណ្ឌ.............. ខេត្ត/រាជធានី................ ។ មានស្ថានភាពផ្ទាល់ខ្លួនបច្ចុប្បន្ន............. ពិតប្រាកដមែន ។

លិខិតបញ្ជាក់នេះ ចេញឱ្យសាមីជនដើម្បីយកទៅប្រើប្រាស់................................។
(លិខិតបញ្ជាក់នេះ មានសុពលភាពរយៈពេល ០៣ខែ គិតចាប់ពីថ្ងៃចុះហត្ថលេខាតទៅ)

ថ្ងៃ................... ខែ.......... ឆ្នាំ......... ត្រីស័ក ព.ស ២៥......
..............., ថ្ងៃទី....... ខែ........... ឆ្នាំ............
មេឃុំ/ចៅសង្កាត់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំបញ្ជាក់

**ភាពនៅលីវ ភាពពោះម៉ាយ ភាពមេម៉ាយ**

ខ្ញុំបាទ នាងខ្ញុំឈ្មោះ-------------------- ភេទ------- សញ្ជាតិ------- កើតនៅថ្ងៃ------- ទី------ ខែ----------- ឆ្នាំ-------- នៅភូមិ------------------- ឃុំ សង្កាត់--------------------- ក្រុង ស្រុក ខណ្ឌ---------------- រាជធានី ខេត្ត ---------------- មុខរបរបច្ចុប្បន្ន--------------------- ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ------- ផ្លូវលេខ-------- ក្រុម------ ភូមិ------------ ឃុំ សង្កាត់----------- ក្រុង ស្រុក ខណ្ឌ--------------- រាជធានី ខេត្ត ---------------។

**គោរពជូន**

**មេឃុំ ចៅសង្កាត់**-------------------------

<u>**កម្មវត្ថុ**</u> ៖ សំណើសុំលិខិតបញ្ជាក់ភាព------------------------------ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ សូមជម្រាបលោក លោកស្រីមេឃុំ ចៅសង្កាត់ មេត្តាជ្រាបថា បច្ចុប្បន្ន ខ្ញុំបាទ នាងខ្ញុំ មានស្ថានភាពផ្ទាល់ខ្លួន----------------------- ហើយមានបំណងរៀបអាពាហ៍ពិពាហ៍ ជាមួយឈ្មោះ--------------- ភេទ---------- ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ------ ផ្លូវលេខ---------ក្រុម---------- ភូមិ------------------------ ឃុំ សង្កាត់---------------------- ក្រុង ស្រុក ខណ្ឌ------------------------- រាជធានី ខេត្ត ----------------------។

អាស្រ័យហេតុនេះ សូមលោក លោកស្រីមេឃុំ ចៅសង្កាត់ មេត្តាចេញលិខិតបញ្ជាក់ឱ្យខ្ញុំបាទ នាងខ្ញុំ ដើម្បីអាចរៀបអាពាហ៍ពិពាហ៍បាន ដោយអនុគ្រោះ។

ដើម្បីជាសក្ខីភាពនៃការអះអាងខាងលើ ខ្ញុំបាទ នាងខ្ញុំ សូមផ្តិតស្នាមមេដៃស្តាំ ទុកជា ភស្តុតាង។

ធ្វើនៅថ្ងៃទី------ ខែ----------- ឆ្នាំ--------

<u>សូមជូនភ្ជាប់ជាមួយនូវ</u> ៖

**ស្នាមមេដៃសាមីខ្លួន**

– ------------------------------

– ---------------------------

ឈ្មោះ ------------

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្ត ក្រុង ...........................**
**រដ្ឋបាល ក្រុង ស្រុក ខណ្ឌ ......................**
**រដ្ឋបាល ឃុំ សង្កាត់ ...............................**
**លេខ ......................................**

| រូបថត ៤x៦ |
|---|

**លិខិតបញ្ជាក់**

**យើងមេឃុំ/ចៅសង្កាត់..........................**

**ស្រុក/ខណ្ឌ ................ ខេត្ត/ក្រុង ........................**

**សូមបញ្ជាក់ថា**

សូមបញ្ជាក់ថាឈ្មោះ .................... ភេទ ...... សញ្ជាតិ ........ កើតនៅថ្ងៃទី ...................... ពិតជាប្រជាពលរដ្ឋស្នាក់នៅផ្ទះលេខ .......... ភូមិ ........... ឃុំ/សង្កាត់ ...................... ស្រុក/ខណ្ឌ .................... ខេត្ត ក្រុង ............................ ពិតប្រាកដមែន។

- កាន់សៀវភៅស្នាក់នៅលេខ ........................ ចុះថ្ងៃទី ...... ខែ ........... ឆ្នាំ ២០២......
- កាន់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរលេខ ........................ ចុះថ្ងៃទី ...... ខែ ........... ឆ្នាំ ២០......
- ដែលមានអ្នកធានាឈ្មោះ ................................ ភេទ ......... សញ្ជាតិ .......... កើតនៅថ្ងៃទី ......................
- កាន់សៀវភៅស្នាក់នៅលេខ ................................ ចុះថ្ងៃទី ...... ខែ ........... ឆ្នាំ ២០២......
- កាន់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរលេខ ............................... ចុះថ្ងៃទី ...... ខែ ........... ឆ្នាំ ២០......ត្រូវជា ............................................ របស់សាម៉ីខ្លួនស្នាក់នៅផ្ទះលេខ ............. ភូមិ .................... ឃុំ/សង្កាត់ .............................. ស្រុក/ខណ្ឌ .............................. ខេត្ត ក្រុង ............................

លិខិតនេះចេញជូនសាម៉ីខ្លួនសម្រាប់យកទៅប្រើប្រាស់ក្នុងការបំពេញសំណុំលិខិតដើម្បី ...... ......................................................................................... ។

*ថ្ងៃ .................................. ខែ.......... ឆ្នាំ......... .........ស័ក ព.ស២៥៦....*

.................... ថ្ងៃទី ......... ខែ........... ឆ្នាំ២០២២

**មេឃុំ/ចៅសង្កាត់**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង ......................
ស្រុក ខណ្ឌ ......................
ឃុំ សង្កាត់ ......................
លេខ ......................

# បណ្ណប្រកាសអាពាហ៍ពិពាហ៍

| អំពីសាមីខ្លួន | ខាងប្រុស | ខាងស្រី |
|---|---|---|
| នាមត្រកូល និង នាមខ្លួន | | |
| ជាអក្សរឡាតាំង | | |
| សញ្ជាតិ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| ទីកន្លែងកំណើត | | |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន | | |
| រយៈពេលប្តឹងជំទាស់ | | |
| នាមត្រកូល និងនាមខ្លួនឪពុក | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន | | |
| នាមត្រកូល និងនាមខ្លួនម្តាយ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន | | |

បណ្ណប្រកាសអាពាហ៍ពិពាហ៍នេះ ត្រូវបិទផ្សាយជាសាធារណៈ នៅថ្ងៃទី.............. ខែ.......................... ឆ្នាំ................... ។

ធ្វើនៅ.......................... ថ្ងៃទី........... ខែ................. ឆ្នាំ............

មន្ត្រីអត្រានុកូលដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង ....កំពង់ស្ពឺ..
ស្រុក ខណ្ឌ...ឧដុង្គ.......
ឃុំ សង្កាត់...ជើងរាស់.......
លេខ..............................

# ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍

| អំពីសាមីខ្លួន | ខាងប្រុស | ខាងស្រី |
|---|---|---|
| នាមត្រកូល និង នាមខ្លួន | | |
| ជាអក្សរឡាតាំង | | |
| សញ្ជាតិ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| ទីកន្លែងកំណើត | | |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន | | |
| រយៈពេលប្តឹងជំទាស់ | | |
| នាមត្រកូល និង នាមខ្លួនឪពុក | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន | | |
| នាមត្រកូល និង នាមខ្លួនម្តាយ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន | | |

ធ្វើនៅ.......................ថ្ងៃទី.........ខែ...........ឆ្នាំ.............

**មន្ត្រីអត្រានុកូលដ្ឋាន**

**ខេត្ត ក្រុង** (១)........................................ **លេខ** (៤)....................................................

**ស្រុក ខណ្ឌ** (២)...................................... **សៀវភៅអាពាហ៍ពិពាហ៍លេខ** (៥)............

**ឃុំ សង្កាត់** (៣)...................................... **ឆ្នាំ** (៦)..........................................................

## បញ្ជីអាពាហ៍ពិពាហ៍សំរាប់ជនបរទេស និង ជនអន្តោប្រវេសន្តស្របច្បាប់

| **អំពីប្តី ប្រពន្ធ** | | **ប្តី** | | **ប្រពន្ធ** | |
|---|---|---|---|---|---|
| នាមត្រកូល (៧) | | | | | |
| នាមខ្លួន (៨) | | | | | |
| ជាអក្សរឡាតាំង (៩) | នាមត្រកូល | | | | |
| | នាមខ្លួន | | | | |
| សញ្ជាតិ (១០) | | | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | | | | | |
| ទីកន្លែងកំណើត (១២) | | | | | |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៣) | | | | | |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៤) | | | | | |
| ទីលំនៅឯបរទេស (១៥) | | | | | |
| លិខិតឆ្លងដែនលេខ មានសុពលភាពត្រឹមថ្ងៃ ខែ ឆ្នាំ (១៦) | | | | | |
| ទិដ្ឋាការ ឬលិខិតអនុញ្ញាតអោយស្នាក់នៅកម្ពុជាលេខ ថ្ងៃ ខែឆ្នាំ (១៧) | | | | | |
| ចុះបញ្ជីអាពាហ៍ពិពាហ៍លើកទី (១៨) | | | | | |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ (១៩) | | | | | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ (២០) | | | | | |
| លេខ និង ថ្ងៃ ខែ ឆ្នាំ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ (២១) | | | | | |
| **អំពីឪពុក ម្តាយ** | | **ខាងប្តី** | | **ខាងប្រពន្ធ** | |
| នាមត្រកូល និង នាមខ្លួនឪពុក (២២) | | (២៣) | រស់ ឬ ស្លាប់ | | រស់ ឬ ស្លាប់ |
| ជាអក្សរឡាតាំង (២៤) | | | | | |
| សញ្ជាតិ (២៥) | | | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៦) | | | | | |
| មុខរបរបច្ចុប្បន្ន (២៧) | | | | | |
| ទីលំនៅបច្ចុប្បន្ន (២៨) | | | | | |
| នាមត្រកូល និង នាមខ្លួនម្តាយ (២៩) | | (៣០) | រស់ ឬ ស្លាប់ | | រស់ ឬ ស្លាប់ |
| ជាអក្សរឡាតាំង (៣១) | | | | | |
| សញ្ជាតិ (៣២) | | | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (៣៣) | | | | | |
| មុខរបរបច្ចុប្បន្ន (៣៤) | | | | | |
| ទីលំនៅបច្ចុប្បន្ន (៣៥) | | | | | |
| **អំពីសាក្សី** | | **សាក្សី** | | **សាក្សី** | |
| នាមត្រកូល និង នាមខ្លួន (៣៦) | | (៣៧) | ភេទ | | ភេទ |
| ជាអក្សរឡាតាំង (៣៨) | | | | | |
| សញ្ជាតិ (៣៩) | | | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (៤០) | | | | | |
| មុខរបរបច្ចុប្បន្ន (៤១) | | | | | |
| ទីលំនៅបច្ចុប្បន្នន (៤២) | | | | | |
| លេខអត្តសញ្ញាណប័ណ្ណ (៤៣) | | | | | |

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋាន ឱ្យអ្នកដែលមកសុំ ជននោះ និង មន្ត្រីអត្រានុកូលដ្ឋាននោះនឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

(៤៥) ធ្វើនៅ.................... ថ្ងៃទី.......... ខែ................ ឆ្នាំ...............

(៤៤) **ស្នាមមេដៃស្តាំ**

ប្តី ប្រពន្ធ សាក្សី សាក្សី

(៤៦) **មន្ត្រីអត្រានុកូលដ្ឋាន**

(៤៧) ហត្ថលេខា និងត្រា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង..............................
ស្រុក ខណ្ឌ..............................
ឃុំ សង្កាត់..............................

លេខ..............................
សៀវភៅអាពាហ៍ពិពាហ៍លេខ..............................
ឆ្នាំ..............................

# សំបុត្រអាពាហ៍ពិពាហ៍

| អំពីប្ដី ប្រពន្ធ | | ប្ដី | ប្រពន្ធ |
|---|---|---|---|
| នាមត្រកូល | | | |
| នាមខ្លួន | | | |
| ជាអក្សរឡាតាំង | នាមត្រកូល | | |
| | នាមខ្លួន | | |
| សញ្ជាតិ | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | |
| ទីកន្លែងកំណើត<br>ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | | | |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ | | | |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ | | | |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ | | | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ | | | |
| អំពីឪពុក ម្ដាយ | | ខាងប្ដី | ខាងប្រពន្ធ |
| នាមត្រកូល និង នាមខ្លួនឪពុក | | | |
| ជាអក្សរឡាតាំង | | | |
| សញ្ជាតិ | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | |
| នាមត្រកូល និង នាមខ្លួនម្ដាយ | | | |
| ជាអក្សរឡាតាំង | | | |
| សញ្ជាតិ | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | |

ធ្វើនៅ.............................. ថ្ងៃទី.......... ខែ.......... ឆ្នាំ..........

**មន្ត្រីអត្រានុកូលដ្ឋាន**

# ឧបសម្ព័ន្ធទី៤៖
# នីតិវិធីនៃការលែងលះ និងសាលក្រម
# លែងលះ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ការិយាល័យចុះឈ្មោះ និងរដ្ឋបាល សាលាដំបូងខេត្តកំពត
លេខ: [redacted]
ថ្ងៃទី [redacted] ឆ្នាំ ២០១៩
ម៉ោង [redacted] នាទី

## <u>ពាក្យបណ្តឹងលែងលះ</u>

<u>**ដើមចោទ**</u> ៖ [redacted] កើតថ្ងៃទី [redacted] ខែ [redacted] ឆ្នាំ [redacted] ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ កាន់អត្តសញ្ញាណបណ្ណលេខ: [redacted] មានលំនៅដ្ឋានភូមិ [redacted] ឃុំ [redacted] ស្រុក [redacted] ខេត្ត [redacted] ក្រជា ប្តី។ [redacted]

<u>**ចុងចម្លើយ**</u> ៖ លោកស្រី [redacted] កើតថ្ងៃទី [redacted] ខែមេសា ឆ្នាំ [redacted] ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ មានលំនៅដ្ឋាននៅភូមិ [redacted] ឃុំ [redacted] ស្រុក [redacted] ខេត្ត [redacted] ក្រជា ប្រពន្ធ។

បណ្តឹងលេខ [redacted]
ចុះថ្ងៃទី..3....ខែ..11....ឆ្នាំ២០១៩
ជូនទៅ [redacted]

### <u>**សូមគោរពជូន**</u>

### **ឯកឧត្តមប្រធានសាលាដំបូងខេត្តកំពត**

<u>**កម្មវត្ថុ**</u> ៖ សុំតុលាការចេញសាលក្រមសម្រេចអោយខ្ញុំបាទសុំលែងលះពីឈ្មោះ [redacted] តាមច្បាប់ ។

- សុំឲខ្ញុំបាទមានសិទ្ធអំណាចមេបាគ្រប់គ្រងកូនចំនួន ០១ នាក់ឈ្មោះ [redacted] ភេទប្រុស អាយុ ០៧ ឆ្នាំ ។
- សុំបែងចែកទ្រព្យសម្បត្តិរួមដែលជាប្រភេទដីលំនៅដ្ឋានមានទីតាំងស្ថិតនៅភូមិ [redacted] ឃុំ [redacted] ស្រុក [redacted] ខេត្តកំពត។
- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចុងចម្លើយ។
- <u>**យោង**</u> ៖ សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី [redacted] ខែ [redacted] ឆ្នាំ ២០១៤ ។
  សំបុត្រកំណើតកូនចុះថ្ងៃទី [redacted] ខែ [redacted] ឆ្នាំ ២០១៥។
  កិច្ចស្យាលក់ដីផ្តាច់ចុះថ្ងៃទី [redacted] ខែ [redacted] ឆ្នាំ ២០១៨។

តបតាមកម្មវត្ថុ និង យោងខាងលើខ្ញុំបាទ សូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា ៖ នៅថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៨ ខ្ញុំបាទ និង ឈ្មោះ [redacted] បានចុះសំបុត្រអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ប៉ុន្តែនៅក្នុងចំណងអាពាហ៍ពិពាហ៍នេះ ខ្ញុំបាទ និង ភាគីចុងចម្លើយរស់នៅមិនចុះសំរុងនឹងគ្នាព្រោះភាគីខាងស្រីតែងតែលួចក្បត់ខ្ញុំម្តងហើយម្តងទៀតហើយពួកយើងមានកូនចំនួន ០២ នាក់ខ្ញុំបាទសុំអំណាចមេបាលើកូនចំនួន ០១ នាក់ឈ្មោះ [redacted] ភេទប្រុស អាយុ ០៧ ឆ្នាំ នឹងសុំបែងចែកទ្រព្យសម្បត្តិរួមដីចំនួន ០១ កន្លែង ស្ថិតនៅភូមិ ស្លុកផ្លក ឃុំ ទទុង ស្រុកដងទង់ ខេត្តកំពត ជាពីរចំណែកស្មើគ្នា។ មូលហេតុដែលខ្ញុំបាទសុំលែងលះជាមួយឈ្មោះ [redacted] ភេទស្រី អាយុ ៣៨ ឆ្នាំ ដោយសារការរស់នៅជាមួយគ្នាជាប្តីប្រពន្ធតែងតែមានភាពរកាំរកូស និងរស់នៅមិនចុះសម្រុងនិងគ្នាទើបហេតុនេះដែលបណ្តាលឲ្យកខ្ញុំអស់មនោសញ្ចេតនារស់នៅជាមួយគ្នាតទៅទៀត។

ក្នុងពាក្យបណ្តឹងសុំលែងលះនេះ ខ្ញុំបាទសូមសំណូមពរ សុំអោយ **ឯកឧត្តមប្រធាន** ចេញសាលក្រមសម្រេចសេចក្តី អោយខ្ញុំលែងលះពីឈ្មោះ [redacted] តាមច្បាប់ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាជ្រាប និង ចេញសាលក្រមសេចក្តីសម្រេចការប្តឹង សុំរបស់ខ្ញុំបាទ តាមនីតិវិធីច្បាប់ដោយក្តីអនុគ្រោះបំផុត ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ថ្ងៃ ០៧ កើត ខែកត្តិក ឆ្នាំខាល ត្រីស័ក ព.ស២៥៦៥

ធ្វើនៅកំពត, ថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០២២

**ស្នាមម្រាមដៃ**



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពត
សំណុំរឿងរដ្ឋប្បវេណី

# ដីកាកោះ

យើង ម៉ែន វណ្ណៈ អនុប្រធាន និងជាចៅក្រមនៃសាលាដំបូងខេត្តកំពត ។
អញ្ជើញឈ្មោះ ភេទស្រី កើតថ្ងៃទី ខែមេសា ឆ្នាំ១៩៩៩ ជនជាតិខ្មែរ ជាចុងចម្លើយ
ទីលំនៅបច្ចុប្បន្ននៅភូមិ ឃុំ ស្រុក ខេត្តកំពត ។

| | |
|---|---|
| សញ្ញាណនៃរឿងក្តី និងភាគី | -សំណុំរឿងរដ្ឋប្បវេណីលេខ : ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២<br>-កម្មវត្ថុ : សុំលែងលះ<br>-ដើមចោទ : ឈ្មោះ ភេទប្រុស កើតឆ្នាំ ជនជាតិខ្មែរ<br>-ចុងចម្លើយ : ឈ្មោះ ភេទស្រី កើតឆ្នាំ ជនជាតិខ្មែរ |
| កាលបរិច្ឆេទ និង ទីកន្លែងដែលត្រូវបង្ហាញខ្លួន | ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង ១០:០០នាទីព្រឹក<br>បន្ទប់ អនុប្រធានតុលាការនៃសាលាដំបូងខេត្តកំពត (ខ) ។ |
| ប្រភេទនៃតំណាក់កាលនៃនីតិវិធី | -ដើម្បីចូលរួមធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល |
| ប្រភេទនៃឯកសារដែលយកមកជាមួយ សំគាល់ដោយសញ្ញាណ | -ឯកសារស្តីឯកសារស្តីពីចំណុចនៃការសាកសួរ<br>-ឯកសារស្តីពីចំណុចនៃការធ្វើកោសល្យវិច័យ |
| ទណ្ឌកម្មជាអាទិ៍ ក្នុងករណីដែលមិនបង្ហាញខ្លួនដោយមូលហេតុត្រឹមត្រូវ | -បើដើមចោទមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវច្រានចោលការទាមទាររបស់ដើមចោទនោះសាលក្រមកំបាំងមុខតាមមាត្រា២០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។<br>-បើដើមចោទមិនបង្ហាញខ្លួននៅកាលបរិច្ឆេទ លើកទី១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេតុលាការត្រូវបញ្ឈប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយភ្លាមៗហើយកំណត់នូវកាលបរិច្ឆេទលើកទី១ នៃការទាញហេតុផលដោយផ្ទាល់មាត់តាមមាត្រា២០១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ |
| សូមបង្ហាញខ្លួនដូចដែលបានបង្ហាញខាងលើនេះ ។ | |

ថ្ងៃព្រហស្បតិ៍ ០៨កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦
កំពត, ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តកំពត
សំណុំរឿងរដ្ឋប្បវេណី

# <u>លិខិតអញ្ជើញ</u>

យើង ម៉ែន វណ្ណៈ អនុប្រធាន និងជាចៅក្រមនៃសាលាដំបូងខេត្តកំពត ។

-បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែវិច្ឆិកា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកំពត ។

-បានឃើញ ពាក្យសុំតំណាងដោយអាណត្តិ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០២២ ។

-បានឃើញ លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២២ ។

សូមអញ្ជើញលោកស្រីមេធាវី អត្តលេខ : ាសមាជិកនៃ ក្រុមហ៊ុន ដែលមានការិយាល័យស្ថិតនៅអគារលេខ : ផ្លូវលេខ ភូមិ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយឈ្មោះ

ឲ្យចូលទៅកាន់សាលាដំបូងខេត្តកំពត នាថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង ១០:០០ នាទីព្រឹក បន្ទប់អនុប្រធានតុលាការនៃសាលាដំបូងខេត្តកំពត (ខ) ។

ដើម្បីចូលរួមធ្វើ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។

សាមីខ្លួនត្រូវអញ្ជើញមកឲ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងក្នុងរឿងខាងលើមកជាមួយផងប្រសិនបើមាន ។

ថ្ងៃព្រហស្បតិ៍ ០៨កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

កំពត ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២

បានទទួល

ថ្ងៃទី......ខែ.........ឆ្នាំ........

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពត**

*សំណុំរឿងរដ្ឋប្បវេណីលេខ:* [redacted]
*ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២*
*សាលក្រមរដ្ឋប្បវេណីលេខ:* [redacted]
*ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៣*

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពត

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៣ នៅសាលសវនាការសាលាដំបូងខេត្តកំពត ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

លោក [redacted] អនុប្រធានសាលាដំបូងខេត្តកំពត

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពត

**គូភាគី:**

-ដើមចោទ: ឈ្មោះ [redacted] ភេទប្រុស កើតឆ្នាំ [redacted] ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ឃុំ [redacted] ស្រុក [redacted] ខេត្តកំពត ។

ដោយមានលោក វណ្ណ សុប៊ុនថន អត្តលេខ: ២៣៦៥ ជាមេធាវីតំណាងដោយអាណត្តិ ។

-ចុងចម្លើយ: ឈ្មោះ [redacted] ភេទស្រី កើតឆ្នាំ [redacted] ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ឃុំ [redacted] ស្រុកដងទង់ ខេត្តកំពត ។

ដោយមានលោក [redacted] អត្តលេខ: [redacted] និងលោកស្រី [redacted] អត្តលេខ [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

**អង្គហេតុ និងចំណុចវិវាទ**

**ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ:**

ក.សុំលែងលះពីចុងចម្លើយឈ្មោះ [redacted]

ខ.សុំសិទ្ធិអំណាចមេបាគ្រប់គ្រងកូនចំនួន ០១នាក់ឈ្មោះ       ភេទប្រុស អាយុ ៧ឆ្នាំ ។

គ.សុំបែងចែកទ្រព្យសម្បត្តិរួមដែលជាប្រភេទដីលំនៅដ្ឋាន ទីតាំងស្ថិតនៅភូមិស្តុកឡុក ឃុំទទុង ស្រុកដងទង់ ខេត្តកំពត ។

ឃ.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

**អង្គហេតុចាំបាច់នៃការលែងលះ:**

-ដោយមូលហេតុ ការរស់នៅជាមួយគ្នាពុំមានភាពចុះសម្រុង និងអស់មនោសញ្ចេតនាជាប្តីប្រពន្ធតទៅទៀត ។

**អង្គហេតុដែលជាមូលហេតុនៃការលែងលះ:**

ដើមចោទ និងចុងចម្លើយឈ្មោះ       បានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវ មានសំបុត្រអាពាហ៍ពិពាហ៍លេខ:   ២ ចុះថ្ងៃទី   ខែកក្កដា ឆ្នាំ២០១៤ ។ ក្នុងអំឡុងពេលរស់នៅជាមួយគ្នា មានកូនចំនួន ០២នាក់ មានឈ្មោះ       ភេទប្រុស អាយុ ៧ឆ្នាំ និងឈ្មោះ       ភេទស្រី អាយុ ៣ឆ្នាំ ។ ក្នុងចំណងអាពាហ៍ពិពាហ៍នេះ ដើមចោទ និងឈ្មោះ       មានទ្រព្យសម្បត្តិរួម ជាដី ០១កន្លែង ស្ថិតនៅភូមិស្តុកឡុក ឃុំទទុង ស្រុកដងទង់ ខេត្តកំពត ។ មូលហេតុដែលដើមចោទសុំលែងលះជាមួយឈ្មោះ       ដោយសារការរស់នៅជាមួយគ្នាជាប្តីប្រពន្ធតែងតែមានភាពរកាំរកូស និងរស់នៅមិនចុះសម្រុងនឹងគ្នា ព្រមទាំងអស់មនោសញ្ចេតនាក្នុងការរស់នៅជាមួយគ្នាបន្តទៅទៀត ។

**នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់**

**ក.សេចក្តីថ្លែងការណ៍របស់ដើមចោទ និងមេធាវីតំណាងដោយអាណត្តិ**

-ដើមចោទឈ្មោះ       បានថ្លែងការណ៍ថា: នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ខ្លួន និងចុងចម្លើយបានឯកភាពគ្នាលើគ្រប់ចំណុចអស់ហើយ ដូចជា: ឯកភាពក្នុងការលែងលះ សិទ្ធិអំណាចមេបាលើកូន ដោយខ្លួនជាអ្នកមានសិទ្ធិអំណាចមេបាលើកូនឈ្មោះ       ភេទប្រុស និងទ្រព្យសម្បត្តិរួម គឺប្រគល់ទៅឱ្យកូនស្រីឈ្មោះ       ។ ចំពោះទ្រព្យសម្បត្តិរួមនេះ ខ្លួនស្នើសុំឱ្យតុលាការបញ្ជាក់ថាពិតជាប្រគល់ទៅឱ្យកូនស្រីឈ្មោះ       ទើបខ្លួនសុខចិត្តប្រគល់ឱ្យ ។

-មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ       បានថ្លែងការណ៍ថា: ខ្លួនសូមរក្សាសេចក្តីថ្លែងការណ៍ ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល កាលពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០២៣ ទុកនៅដដែល ។ កាលពីនីតិវិធីត្រៀម គូភាគីបានឯកភាពគ្នាគ្រប់ចំណុចអស់ហើយ ដូចជា: ឯកភាពក្នុងការលែងលះ សិទ្ធិអំណាចមេបាលើកូន និងការ

បែងចែកទ្រព្យសម្បត្តិរួម (ទ្រព្យសម្បត្តិរួមគូភាគីឯកភាពប្រគល់ទៅឱ្យកូនស្រីឈ្មោះ ) ។

**ខ.សេចក្តីថ្លែងការណ៍របស់ចុងចម្លើយ និងមេធាវីតំណាងដោយអាណត្តិ**

-ចុងចម្លើយឈ្មោះ បានថ្លែងការណ៍ថា: ខ្លួនសូមឯកភាពតាមការលើកឡើងរបស់ដើមចោទ ។

-មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ បានថ្លែងការណ៍ថា: ពួកខ្លួនឯកភាពតាមការលើកឡើងរបស់កូនក្តី និងសំណូមពរឱ្យដើមចោទ បង្ករភាពងាយស្រួលដល់ការចូលជួប សួរសុខទុក្ខ និងប្រាស្រ័យទាក់ទងជាមួយកូនប្រុសផង ។

**ចំណុចចចខាង**: គ្មាន

**ចំណុចដែលគ្មានចចខាង**: ឯកភាពលែងលះ សិទ្ធិអំណាចមេបា ការបែងចែកទ្រព្យសម្បត្តិរួម និងការទទួលបន្ទុកលើបំណុលរួម

## សំអាងហេតុ

### តាមលទ្ធផលនៃការសាកសួរសាមីភាគី

### និងការពិនិត្យភស្តុតាងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា:

ក.តាមការទទួលស្គាល់របស់គូភាគី ឃើញថា ពួកគេបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតាមប្រពៃណី និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវ តាមរយៈសំបុត្រអាពាហ៍ពិពាហ៍លេខ: ៤២ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ចេញដោយមន្ត្រីអត្រានុកូលដ្ឋាន ឃុំទទុង ដូច្នេះ តុលាការនឹងលើកយកមកពិចារណា និងសម្រេចលើចំណុចប្តឹងសុំលែងលះតាមពាក្យបណ្តឹងរបស់ដើមចោទដោយផ្អែកតាមក្រមរដ្ឋប្បវេណី ។

ខ.តាមសេចក្តីថ្លែងការណ៍របស់ដើមចោទថា ខ្លួនប្តឹងសុំលែងលះពីចុងចម្លើយដោយហេតុថា ការរស់នៅជាមួយគ្នាមានភាពមិនចុះសម្រុង និងអស់មនោសញ្ចេតនាជាប្តីប្រពន្ធតទៅទៀត ។ ម្យ៉ាងទៀត តាមសេចក្តីថ្លែងការណ៍របស់ដើមចោទ និងចុងចម្លើយនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា គូភាគីបានឯកភាពគ្នាក្នុងការលែងលះ ដូច្នេះ គប្បីតុលាការពិចារណា និងសម្រេចឱ្យគូភាគីលែងលះពីគ្នា ស្របតាមបញ្ញត្តិមាត្រា ៩៧៨ និងមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី ។

គ.តាមការទទួលស្គាល់របស់គូភាគី និងសំបុត្រកំណើតលេខ: ៣ ចុះថ្ងៃទី ខែឧសភា ឆ្នាំ២០១៥ និងសំបុត្រកំណើតលេខ: ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៩ តុលាការមានជំនឿថា ក្នុងចំណងអាពាហ៍ពិពាហ៍នេះ គូភាគីពិតជាមានកូនចំនួន ០២នាក់ រួមមានឈ្មោះ ភេទប្រុស កើតថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ និងឈ្មោះ ភេទស្រី កើតថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩ ប្រាកដមែន ។

ឃ.នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា ដើមចោទ និងចុងចម្លើយ បានឯកភាពគ្នា ដោយឱ្យដើមចោទឈ្មោះ ជាអ្នកមានសិទ្ធិអំណាចមេបាលើកូនឈ្មោះ ភេទប្រុស និងចុងចម្លើយឈ្មោះ ជាអ្នកមានសិទ្ធិអំណាចមេបាលើកូនឈ្មោះ ភេទស្រី ។ ដោយហេតុថា គូភាគីបានព្រមព្រៀងគ្នាចំពោះអ្នកមានសិទ្ធិអំណាចមេបារួចហើយ តប្បីតុលាការពិចារណា និងសម្រេចតាមការព្រមព្រៀងនេះ ។

ង.ផ្អែកតាមសេចក្តីថ្លែងការណ៍របស់គូភាគី នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា ដើមចោទ និងចុងចម្លើយបានពិភាក្សា និងព្រមព្រៀងគ្នាបែងចែកទ្រព្យសម្បត្តិរួម មានដីទំហំ ម៉ែត្រការ៉េ និងផ្ទះទំហំ ៦ម៉ែត្រ គុណនឹង ១១ម៉ែត្រ ទីតាំងស្ថិតនៅភូមិស្លុកក្លុក ឃុំទទុង ស្រុកដងទង់ ខេត្តកំពត ដោយគូភាគីសុខចិត្តប្រគល់ទៅឱ្យកូនស្រីឈ្មោះ វ៉ុង ដូអឹ ។ តប្បីតុលាការសម្រេចតាមការព្រមព្រៀងនេះ ។

ច.ផ្អែកតាមសេចក្តីថ្លែងការណ៍របស់គូភាគី នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា គូភាគីបានពិភាក្សា និងបែងចែកការទទួលបន្ទុកសងបំណុលរួមរួចរាល់ហើយ ដោយដើមចោទជាអ្នកទទួលបន្ទុកសងបំណុលរួមសរុបចំនួន ៣៥.០០០ដុល្លារអាមេរិក ដែលបានខ្ចីពីធនាគារប្រៃសណីយ៍កម្ពុជានោះ ហេតុនេះតប្បីតុលាការសម្រេចតាមការព្រមព្រៀងនេះ ។

ឆ.ចំពោះប្រាក់ប្រដាប់ក្តី ត្រូវអនុវត្តតាមបញ្ញត្តិមាត្រា ៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**សេចក្តីសម្រេចបញ្ចប់**

១.ទទួលស្គាល់ការទាមទាររបស់ដើមចោទឈ្មោះ តាមពាក្យបណ្តឹងចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២ ។

**២.ផ្តាច់ចំណងអាពាហ៍ពិពាហ៍**រវាងដើមចោទឈ្មោះ និងចុងចម្លើយឈ្មោះ ចាប់ពីពេលនេះតទៅ ។

**៣.ប្រគល់សិទ្ធិអំណាចមេបាៈ**

ក.កូនឈ្មោះ ភេទប្រុស កើតឆ្នាំ២០១៥ ទៅឱ្យដើមចោទឈ្មោះ គ្រប់គ្រង រហូតដល់ពេលកូននេះបានដល់នីតិភាព ។

ខ.កូនឈ្មោះ ភេទស្រី កើតឆ្នាំ២០១៩ ទៅឱ្យចុងចម្លើយឈ្មោះ គ្រប់គ្រង រហូតដល់ពេលកូននេះបានដល់នីតិភាព ។

ភាគីដែលមិនមានអំណាចមេបា មានសិទ្ធិចូលជួប សួរសុខទុក្ខ និងប្រាស្រ័យទាក់ទងជាមួយកូនបាន ដូចមានបញ្ញត្តិក្នុងមាត្រា ១០៤០ ដល់មាត្រា ១០៤២ នៃក្រមរដ្ឋប្បវេណី ។

៤.ប្រគល់ ដីទំហំ ៤៣៥ម៉ែត្រការ៉េ និងផ្ទះទំហំ ៦ម៉ែត្រ គុណនឹង ១១ម៉ែត្រ ទីតាំងស្ថិតនៅភូមិស្តុកឡក ឃុំទទុង ស្រុកដងទង់ ខេត្តកំពត ទៅឱ្យឈ្មោះ ភេទស្រី កើតឆ្នាំ២០១៩ ប៉ុន្តែដោយសារឈ្មោះ ជាអនីតិជន ទ្រព្យសម្បត្តិនេះ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ចុងចម្លើយឈ្មោះ ជាបណ្តោះអាសន្ន រហូតដល់ពេលឈ្មោះ បានដល់នីតិភាព ។

៥.បង្គាប់ឱ្យដើមចោទឈ្មោះ ទទួលបន្ទុកសងបន្តនូវប្រាក់កម្ចីពីធនាគារប្រៃសណីយ៍កម្ពុជា សរុបចំនួន ៣៥.០០០ (សាមសិបប្រាំពាន់) ដុល្លារអាមេរិក ។

៦.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់គូភាគីម្នាក់ពាក់កណ្តាល ។

សាលក្រមនេះបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈ ចំពោះមុខគូភាគី ទុកសិទ្ធិឱ្យប្តឹងឧបាស្រ័យតាមកំណត់ច្បាប់ ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា:

---

-បានចម្លងត្រឹមត្រូវតាមច្បាប់ដើម-

ថ្ងៃពុធ ៤កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ខេត្តកំពត ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣

**បានឃើញ**

**ក្រឡាបញ្ជី**

# សាលក្រមទី២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្ត
បន្ទាយមានជ័យ

សំណុំរឿងរដ្ឋប្បវេណី
លេខ
ចុះថ្ងៃទី ២០១៨
សាលក្រម
លេខ: ( )
ចុះថ្ងៃទី ២០១៨

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តបន្ទាយមានជ័យ

កាលបរិច្ឆេទបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ ២០១៨។

កាលបរិច្ឆេទប្រកាសសាលក្រម : ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨

## ចៅក្រម

លោក **ជួន វណ្ណា** ចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ

## ក្រឡាបញ្ជី

លោក **ទៀង ដារណា** ក្រឡាបញ្ជីសាលាដំបូងខេត្តបន្ទាយមានជ័យ

## សមាសភាពដែលបានបង្ហាញខ្លួន

-ដើមចោទឈ្មោះ ភេទស្រី ថ្ងៃខែឆ្នាំកំណើត ជាតិខ្មែរ មុខរបរ កម្មករទីលំនៅបច្ចុប្បន្នភូមិ២ សង្កាត់ ក្រុង ខេត្ត ។

-ចុងចម្លើយឈ្មោះ ភេទប្រុស ថ្ងៃខែឆ្នាំកំណើត មុខរបរកម្មករ ទីលំនៅបច្ចុប្បន្ននៅភូមិ២ សង្កាត់ ង ខេត្ត

## កម្មវត្ថុនៃបណ្តឹង

ខ្លឹមសារសាលក្រមដែលទាមទារដោយភាគី:

ក-ដើមចោទទាមទារអោយតុលាការចេញសាលក្រម:

១-សុំលែងលះពីចុងចម្លើយឈ្មោះ

២-សុំបែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែកស្មើគ្នា

៣-សុំអំណាចមេបាលើកូនប្រុសម្នាក់

៤-សុំអាហារកិច្ចចិញ្ចឹមកូនផ្តាច់ ៥,០០០(ប្រាំពាន់)ដុល្លាអាមេរិក

៥-សុំរ៉ាប់រងប្រាក់ពន្ធ។

ខ-ចុងចម្លើយទាមទារអោយតុលាការចេញសាលក្រម: លែងលះ និងបែងចែកទ្រព្យសម្បត្តិរួម។

## អង្គហេតុ និងចំណុចវិវាទ

ក-អំពីដំណើរនៃរឿងក្តី:

ដើមចោទឈ្មោះ បានដាក់ពាក្យប្តឹងសុំលែងលះពីចុងចម្លើយឈ្មោះ ដោយមូលហេតុថា: តាំងពីរស់នៅជាមួយចុងចម្លើយតែងតែមានរឿងរកាំរកូសជាមួយគ្នាជារឿយៗ ចុងចម្លើយចេះតែ គំរាមសម្លាប់ខ្លួនជារឿយៗពេលខឹងម្តងៗ ហើយសព្វថ្ងៃវាងខ្លួន និងចុងចម្លើយបានរស់នៅបែកលំនៅសង្វាសគ្នាអស់រយៈពេល៥ខែមកហើយ ដោយសារខ្លាចមានគ្រោះថ្នាក់ដោយប្រការផ្សេងៗ ដូច្នេះហើយធ្វើអោយខ្លួនអស់មនោសញ្ចេតនារួមរស់ជាមួយគ្នាទើបដាក់ពាក្យសុំលែងលះតាមច្បាប់។

-អង្គហេតុដែលមានវិវាទ: លែងលះ, ការបែងចែកទ្រព្យសម្បត្តិរួម

-អង្គហេតុដែលគ្មានវិវាទ: គូភាគីបានរៀបអាពាហ៍ពិពាហ៍តាមច្បាប់, បែងចែកអំណាចមេបា

ខ-ការអះអាងរបស់ភាគី:

-ក្នុងពេលទាញហេតុផលដោយផ្ទាល់មាត់ដើមចោទឈ្មោះ បានធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួននៅតែប្តឹងសុំអោយតុលាការចេញសាលក្រមសម្រេចអោយខ្លួនបានលែងលះ ពីចុងចម្លើយឈ្មោះ ដដែល ហើយទ្រព្យសម្បត្តិរួមខ្លួនសុំចែកជាពីរចំណែកស្មើគ្នា។ ដីសង់ផ្ទះម្តាយចុងចម្លើយចែកអោយខ្លួន និងប្តីកាន់កាប់រស់នៅ។ ចំពោះផ្ទះដែលសង់នៅលើដីសរុបអស់ប្រាក់ ៧,៥០០(ប្រាំពីរពាន់ប្រាំរយ)ដុល្លាអាមេរិក នៅពុំទាន់បានគិតពីតម្លៃជាងនៅឡើយទេ។ ចំពោះថ្លៃជាងទើបតែអោយបាន ២០០(ពីររយ)ដុល្លាអាមេរិក នៅជំពាក់ថ្លៃជាងចំនួន១,៩០០(មួយពាន់ប្រាំបួនរយ)ដុល្លាអាមេរិក ទៀត ខ្លួនសុំអោយចុងចម្លើយជួយសងថ្លៃជាង ម្នាក់ពាក់កណ្តាល។ ដើម្បីកុំអោយមានរឿងវែងឆ្ងាយ ខ្លួនសុំអោយចុងចម្លើយបង់ផ្តាច់ទាំងប្រាក់អាហារកិច្ច,ប្រាក់ទ្រព្យរួម,ប្រាក់បំណុលជាងសរុបចំនួន ៧,០០០(ប្រាំពីរពាន់)ដុល្លាអាមេរិក។ ចំពោះម៉ូតូខ្លួនបានទិញពីប្អូនថ្លៃរួចហើយតម្លៃ ៥០០(ប្រាំរយ)ដុល្លាអាមេរិក។

-ចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនសុំឯកភាពលែងលះ និងអំណាចមេបា។ ចំណែកទ្រព្យសម្បត្តិដែលដើមចោទរៀបរាប់ គឺខ្លួនមិនឯកភាពតាមទេ ពីព្រោះដីនេះគឺដីរបស់ម្តាយខ្លួន ដែលបានអោយខ្លួន និងប្រពន្ធរស់នៅជាបណ្តោះអាសន្ន។ ចំពោះអាហារកិច្ចខ្លួនសុំចិញ្ចឹមកូនក្នុងមួយខែ ២០០,០០០(ម្ភៃម៉ឺន)រៀល រឿងដើមចោទសុំប្រាក់ផ្តាច់ទាំងប្រាក់អាហារកិច្ច, ប្រាក់ទ្រព្យរួម, ប្រាក់ជំពាក់ជាងសរុបចំនួន ៧,០០០(ប្រាំពីរពាន់)ដុល្លាអាមេរិកនោះ ខ្លួនសុំបដិសេធ តែដើម្បីកុំអោយវែងឆ្ងាយខ្លួនសុំបង់អោយដើមចោទផ្តាច់ចំនួន ១,៥០០(មួយពាន់ប្រាំ)ដុល្លាអាមេរិក។

-សេចក្តីបំភ្លឺរបស់សាក្សីខាងដើមចោទឈ្មោះ .. បានបញ្ជាក់ថា ដីដែលកូនសង់ផ្ទះនៅ សព្វថ្ងៃគឺខាងជន្លងខ្លួនបានប្រគល់ឲ្យកូនកាន់កាប់ទាំងពីរនាក់ប្តីប្រពន្ធ។ បន្ទាប់ពីបានដីហើយទើបខ្លួន បានចាត់ចែងធ្វើផ្ទះឲ្យកូន ហើយប្រាក់ដែលយកមកសាងសង់ផ្ទះនោះ ខ្លួនមិនបានដឹងទេ ខ្លួនដឹងតែថ្លៃជាង សរុបអស់ប្រាក់ចំនួន ២,១០០(ពីរពាន់មួយរយ)ដុល្លាអាមេរិក ទើបតែសងជាងបាន ២០០(ពីរយ)ដុល្លាអាមេរិក តែប៉ុណ្ណោះ ហើយនៅជំពាក់ប្រាក់ថ្លៃជាងចំនួន ១,៩០០(មួយពាន់ប្រាំបួនរយ)ដុល្លាអាមេរិកទៀត។

-សេចក្តីបំភ្លឺរបស់សាក្សីខាងចុងចម្លើយឈ្មោះ បានបញ្ជាក់ថា ខ្លួនបានប្រគល់ដីទៅឲ្យកូនទាំងពីរមែន តែគ្រាន់តែប្រគល់ឲ្យរស់នៅជាបណ្តោះអាសន្នតែប៉ុណ្ណោះ បើកូនលែងលះគ្នាខ្លួននឹងដកហូតយកដីនោះមកវិញ។ ខ្លួនបានឲ្យលុយកូនធ្វើផ្ទះចំនួន ៣,៥០០(បីពាន់ប្រាំរយ)ដុល្លាអាមេរិក ហើយថ្លៃធ្វើអស់ប៉ុន្មានទៀតក៏មិនដឹងដែរ។

-សេចក្តីបំភ្លឺរបស់សាក្សីឈ្មោះ បានបញ្ជាក់ថា ខ្លួនបានលក់ម៉ូតូទៅឲ្យបងថ្លៃខ្លួន ឈ្មោះ លឹម ស្រីយ៉ាន ក្នុងតំលៃ ៥០០(ប្រាំរយ)ដុល្លាអាមេរិក ហើយបានទទួលប្រាក់នោះរួចរាល់។

## សំអាងហេតុ

-តាមលទ្ធផលនៃការសាកសួរភាគី ក្នុងពេលធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា : ដើមចោទ និងចុងចម្លើយបានរួមរស់ជាមួយគ្នាក្នុងឆ្នាំ ព្រមទាំងបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់។

-ក្នុងពេលត្រៀមទាញហេតុផល និងពេលទាញហេតុផលដោយផ្ទាល់មាត់ដើមចោទ និងចុងចម្លើយបាន ព្រមព្រៀងគ្នាលើចំណុចលែងលះ និងអំណាចមេបា។ តុលាការគប្បីសម្រេចតាមការព្រមព្រៀងរបស់សហភាគីទ្វេ។

-ការទាមទារអាហារកិច្ចចិញ្ចឹមកូនផ្តាច់ចំនួន ៥,០០០(ប្រាំពាន់)ដុល្លាអាមេរិក របស់ដើមចោទ ហើយចុងចម្លើយសុំបង់អាហារកិច្ចចិញ្ចឹមកូនចំនួន ២០០,០០០(ម្ភៃម៉ឺន)រៀល ក្នុងមួយខែនោះ តុលាការគប្បីពិចារណាសម្រេចតាមលទ្ធភាពរបស់ភាគី ។

-ក្នុងពេលត្រៀមទាញហេតុផល និងពេលទាញហេតុផលដោយផ្ទាល់មាត់ ដើមចោទ និងចុងចម្លើយ មិនឯកភាពគ្នាលើទ្រព្យសម្បត្តិរួម ដោយដើមចោទអះអាងថា អោយតុលាការសម្រេចចែកទ្រព្យសម្បត្តិរួមជាពីរ ចំណែកស្មើគ្នា និងបានលើកឡើងថា ខ្លួនក៏បានចំណាយប្រាក់មួយចំនួនក្នុងការសាងសង់ផ្ទះដែរ រីឯចុងចម្លើយបានអះអាងថា ខ្លួនសុខចិត្តប្រគល់ប្រាក់ចំនួន ១,៥០០(មួយពាន់ប្រាំរយ)ដុល្លាអាមេរិក អោយទៅដើមចោទ។ ឃើញថាសេចក្ដីថ្លែងការណ៍អំពីថ្លៃចេញសាងសង់ផ្ទះនេះ គឺមិនមានភស្តុតាងច្បាស់លាស់ អំពីតំលៃនៃថ្លៃនោះទេ តុលាការគប្បីពិចារណាសម្រេចផ្អែកលើកស្តុតាងជាក់ស្ដែង។

-កូនឈ្មោះ ភេទប្រុស កើតថ្ងៃខែឆ្នាំ គូភាគីបានព្រមព្រាងគ្នា ប្រគល់អំណាចមេបាទៅឲ្យដើមចោទ។ គប្បីតុលាការសម្រេចតាមការព្រមព្រាងរបស់ភាគី។

-ចំពោះទ្រព្យសម្បត្តិដែលជាដី ដែលភាគីដើមចោទបានអះអាងថា ម្ដាយខាងចុងចម្លើយបានប្រគល់មកឲ្យពួកខ្លួនរស់នៅកាន់កាប់ទាំងពីនោក់នោះ គឺមិនមានភស្តុតាងជាលិខិតឯកសារណាដែលធ្វើឲ្យតុលាការជឿ បានឡើយ ហើយផ្ទុយទៅវិញម្ដាយរបស់ចុងចម្លើយបានបញ្ជាក់ថា បានប្រគល់ទៅភាគីរស់នៅមែន តែប្រគល់ឲ្យរស់នៅបណ្ដោះអាសន្នតែប៉ុណ្ណោះ នឹងដកហូតយកមកវិញនៅពេលដែលភាគីលែងលះគ្នា។ ដូច្នេះដីនេះ ជាដីរបស់ម្ដាយចុងចម្លើយ គឺមិនមែនជាដីរួមរបស់គូភាគីនោះទេ គប្បីតុលាការមិនពិចារណាសម្រេចអំពីដី ដែលមិនមែនជាទ្រព្យរួមរបស់ភាគីឡើយ។

-ប្រាក់ប្រដាប់ក្ដីដើមចោទសុខចិត្តទទួលរ៉ាប់រង។

## សេចក្ដីសម្រេចបញ្ចប់

១/អោយដើមចោទឈ្មោះ ភេទស្រី ថ្ងៃខែឆ្នាំកំណើត និងចុងចម្លើយឈ្មោះ ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ាចុងចម្លើយលែងលះគ្នាចាប់ពីពេលនេះតទៅ។

២/អោយដើមចោទឈ្មោះ ដែលមានអត្តសញ្ញាណដូចខាងលើ មានអំណាចមេបាលើ កូនម្នាក់ឈ្មោះ ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ាមការព្រមព្រៀងរបស់គូភាគី ។

៣/ទុកសិទ្ធអោយឪពុកទៅសួរសុខទុក្ខកូនបានតាមមាត្រា ៩៧៨,៩៧៩, ១០៣៧ នៃក្រមរដ្ឋប្បវេណី។ មាតាបិតាត្រូវបំពេញសិទ្ធ និងករណីកិច្ចអប់រំថែទាំចិញ្ចឹមកូនអោយបានល្អ។

៤/អោយចុងចម្លើយឈ្មោះ ដែលមានអត្តសញ្ញាណដូចខាងលើ បង់អាហារកិច្ចចិញ្ចឹមកូន ចំនួន ២០០,០០០(ម្ភៃម៉ឺន)រៀល ក្នុងមួយខែអោយទៅដើមចោទសំរាប់ការចិញ្ចឹមកូន រហូតដល់កូនមានវ័យនីតិភាព។

៥/ប្រគល់ផ្ទះមួយល្វែងសង់អំពីថ្មប្រក់ស័ង្កសីទំហំ ៥ម៉ែត្រ គុណ ១៦ម៉ែត្រ លើដីដែលជាកម្មសិទ្ធរបស់ម្ដាយចុងចម្លើយ ស្ថិតនៅភូមិ២ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ អោយទៅចុងចម្លើយឈ្មោះ កាន់កាប់ជាកម្មសិទ្ធចាប់ពីសាលក្រមចូលជាស្ថាពរតទៅ។

៦/ប្រគល់ម៉ូតូមួយគ្រឿងម៉ាកឌ្រីមសង់ ២០១៥ ពណ៌ខ្មៅ ស្លាកលេខ ប.ជ ១២៧៥ ទៅឲ្យដើមចោទ ឈ្មោះ ចាប់ពីសាលក្រមចូលជាស្ថាពរតទៅ។

៧/បង្គាប់អោយចុងចម្លើយឈ្មោះ ដែលមានអត្តសញ្ញាណដូចខាងលើ ប្រគល់ប្រាក់ចំនួន ២,០០០ (ពីរពាន់)ដុល្លាអាមេរិក ទៅឲ្យដើមចោទឈ្មោះ . ចាប់ពីសាលក្រមចូលជាស្ថាពរតទៅ។

៨/បង្គាប់អោយដើមចោទឈ្មោះ និងចុងចម្លើយឈ្មោះ រួមគ្នាសងបំណុល (ម្នាក់ពាក់កណ្ដាល ជាង)ចំនួន ១,៩០០(មួយពាន់ប្រាំបួនរយ)ដុល្លាអាមេរិក ម្នាក់ពាក់កណ្ដាល ។

៩/ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ។

១០/សាលក្រមនេះធ្វើការទាញហេតុផលដោយផ្ទាល់មាត់ និងបានប្រកាសជាសាធារណៈបើកសិទ្ធិប្ដឹង ឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

ថ្ងៃច័ន្ទ ១០កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅបន្ទាយមានជ័យ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨

**ចៅក្រម**

ជួន_ចន្ទ្រា